**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université royale de droit et des sciences Economiques

Royal University of Law and Econimics

**សារណាបញ្ចប់ការសិក្សា**

# ការរលត់នៃបណ្តឹងអាជ្ញា

ស្រាវជាវចាប់ពីថ្ងៃទី ២៣ ខែមិនា ឆ្នាំ ២០២២ ដល់ ថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០២២


រៀបរៀងដោយនិស្សិតឈ្មោះ:

**កញ្ញា ហេង សុខា**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី **២២**

សាស្ត្រាចារ្យណែនាំ:

**លោក រុន ពណ្ណារិទ្ធ**

ឆ្នាំចូលសិក្សា **២០១៨**

ឆ្នាំសរសេរសារណា **២០២២**

# សេចក្តីថ្លែងអំណរគុណ

**នាងខ្ញុំ ឈ្មោះ ហេង សុខា ជានិស្សិតផ្នែកនីតិសាស្ត្រនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំសិក្សា ២០១៨ ដល់ ២០២២ជំនាន់ទី២២។**

ជាដំបូងនាងខ្ញុំ សូមសម្តែងកតញ្ញូ និង ដឹងគុណដល់ជ្រាលជ្រៅដែលមិនអាចកាត់ថ្លៃបានចំពោះលោកអ្នកមានគុណទាំងពីរពោលគឺលោកឪពុក **ប្រេះ ឈុនហេង** និង អ្នកម្តាយ **នី លាងខឹម** ដែលបានផ្តល់នូវកំណើតដល់រូបនាងខ្ញុំ និង បានចិញ្ចឹមបីបាច់ ថែរក្សា ផ្គត់ផ្គង់ អប់រំទូន្មានប្រៀនប្រដៅ ផ្តល់ដំបូន្មានល្អៗ ព្រមទាំងផ្តល់កម្លាំងចិត្តនិងកម្លាំងកាយដោយមិនគិតពីការនឿយហត់របស់លោកតាំងពី នាងខ្ញុំនៅកុមារភាពរហូតឈានដល់បញ្ចប់ការសិក្សាបរិញ្ញាបត្រប្រកបដោយជោគជ័យ។ ជាពិសេសនាងខ្ញុំសូមធ្វើការគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅអនេកដល់បងស្រី បងប្រុសរបស់នាងខ្ញុំដែលលោកទាំងពីរបានមើលថែទាំនិងផ្គត់ផ្គង់ឧបត្ថម្ភគាំទ្រនូវផ្នែកសម្ភារ: និង ស្មារតីដល់ នាងខ្ញុំ ក្នុងការសិក្សារៀនសូត្ររហូតដល់បញ្ចប់ថ្នាក់បរិញ្ញាបត្រប្រកបដោយរលូន ។ នាងខ្ញុំសូមធ្វើការគោរពដឹងគុណទីជាបំផុត និង ពុំអាចកាត់ថ្លៃបានឡើយរាល់សកម្មភាពដែលអ្នកមានគុណទាំងអស់មានចំពោះនាងខ្ញុំ។

នាងខ្ញុំសូមថ្លែងអំណរគុណ ដល់ **ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ថ្នាក់ដឹកនាំ គណៈគ្រប់គ្រង និង លោក លោកស្រី សាស្ត្រាចារ្យ** នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ចដែលធ្វើការយកចិត្តទុកដាក់ក្នុងការអប់រំផ្តល់ចំណេះដឹង និងសីលធម៌ដល់នាងខ្ញុំអស់រយៈពេលបួនឆ្នាំកន្លងមក។

ជាពិសេសនាងខ្ញុំ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតដល់លោកសាស្ត្រាចារ្យ **រុន ពណ្ណារិទ្ធ** លោកជាសាស្ត្រាចារ្យណែនាំដែលបានឆ្លៀតឱកាសដ៏មានតម្លៃ ក្នុង ការបង្ហាត់បង្រៀនផ្តល់ការណែនាំតម្រង់ទិសដល់រូបនាងខ្ញុំហើយបានផ្តល់អនុសាសន៍ល្អៗ ដើម្បីកែលម្អចំណុចខ្វះខាតទាំងឡាយក្នុងការសរសេរសារណាបញ្ចប់ការសិក្សានេះ។

ជាចុងក្រោយនាងខ្ញុំសូមប្រសិទ្ធពរជ័យ សិរីមង្គល វិបុលសុខ មហាប្រសើរ បួងសួង ដល់វត្ថុស័ក្តសិទ្ធក្នុងលោកនេះមេត្តាថែរក្សាដល់ អ្នកមានគុណទាំងពីរ បងប្រុស បងស្រី ឯកឧត្តមសាកលវិទ្យាធិការ ឯកឧត្តមសាកលវិទ្យាធិការរង ព្រឹទ្ធបុរស ថ្នាក់ដឹកនាំ គណៈគ្រប់គ្រងនិងលោក លោកស្រី សាស្ត្រាចារ្យទាំងអស់និងមិត្តនិស្សិតសូមប្រកបដោយជោគជ័យគ្រប់ភារកិច្ចនិងសូមទទួលបានពុទ្ធពរទាំងបួនគឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លាឃ្លាតឡើយ។

## អំណរគុណ

ជាបឋមនាងខ្ញុំ **ហេង សុខា** សូមធ្វើការស្វាគមន៍ចំពោះប្រិយមិត្តអ្នកអានគ្រប់រូបជាពិសេសសិស្ស និស្សិតជាទីរាប់អាននិងសាស្ត្រាចារ្យជាទីគោរព ។ ក្រោយពីបានសិក្សាអស់រយៈពេល៤ឆ្នាំផ្នែកនីតិសាស្ត្រមក **"នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច"** នាងខ្ញុំពិតជាមានកិត្តិយស យ៉ាងក្រៃលែងដែលសាកលវិទ្យាល័យបានផ្តល់ឱកាសឲ្យរូបនាងខ្ញុំ ក្នុងសិក្សាស្រាវជ្រាវរៀបចំចងក្រងនូវសារណាដើម្បីបញ្ចប់ការសិក្សាបរិញ្ញាបត្រនីតិសាស្ត្ររបស់នាងខ្ញុំ។

ក្នុងការសិក្សាបរិញ្ញាបត្រនីតិសាស្ត្រ នាងខ្ញុំ បានចាប់អារម្មណ៍នឹងមុខវិជ្ជានីតិវិធីព្រហ្មទណ្ឌដោយសារតែនាងខ្ញុំយល់ឃើញថានីតិវិធីព្រហ្មទណ្ឌគឺជាមុខវិជ្ជាមួយដ៏សំខាន់ក្នុងការអនុវត្តច្បាប់នៅកម្ពុជា ។ ដំណើរការនៃការអនុវត្តច្បាប់ព្រហ្មទណ្ឌ គឺជា ចំណុចដ៏ចម្បងមួយព្រោះប្រៀបដូចជាកញ្ចក់ដែលនឹងបង្ហាញពីការគោរពសិទ្ធមនុស្សក្នុងរឿងក្តីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាស្របតាមនីតិសិទ្ធិមនុស្សអន្តរជាតិ ។ ហេតុនេះហើយ នាងខ្ញុំបានសម្រេចចិត្តធ្វើការជ្រើសរើសប្រធានបទ " **ការរលត់នៃបណ្តឹងអាជ្ញា**" ដែលស្ថិតនៅក្នុងមុខវិជ្ជានីតិវិធីព្រហ្មទណ្ឌ ហើយមាន លោកសាស្ត្រាចារ្យណែនាំ **រុន ពណ្ណារិទ្ធ** ។ នាងខ្ញុំយល់ឃើញថាប្រធានបទនេះ គឺជា ចំណុចមួយដែលបានផ្តល់នូវចំណេះដឹងដ៏សំខាន់មួយពីការមិនអាចចាប់ផ្តើមបណ្តឹងអាជ្ញា ឬ បញ្ឈប់បណ្តឹងអាជ្ញាដែលខុសពីដំណើរការធម្មតានៃរឿងក្តីព្រហ្មទណ្ឌ ។ នេះហើយជាចំណុចពិសេសដែលធ្វើឲ្យនាងខ្ញុំចាប់អារម្មណ៍នឹងចង់សិក្សាស្រាវជ្រាវបន្ថែមឲ្យកាន់តែស៊ីជម្រៅពាក់ព័ន្ធនឹងប្រធានបទនេះ ។ នាងខ្ញុំសង្ឃឹមថាប្រធានបទនេះនឹងជួយជាចំណែកក្នុងការស្រាវជ្រាវដល់ សិស្ស និស្សិតជំនាន់ក្រោយៗ ដើម្បី ជួយជាចំណែកក្នុងការកសាងចំណេះដឹង និង ស្មារតី ។ ក្រោយពីការសិក្សាប្រធានបទនេះហើយនាងខ្ញុំប្តេជ្ញាថានឹងប្រើប្រាស់ចំណេះដឹងនេះឲ្យបានជាប្រយោជន៍ដល់ខ្លួន និង ដល់សង្គមជាតិនៅពេលអនាគត។

ទោះបីជានាងខ្ញុំបានខិតខំក្នុងការសិក្សាស្រាវជ្រាវ ត្រួតពិនិត្យ កែតម្រូវយ៉ាងណាក៏សារណានេះនៅតែមានចំណុចខ្វះខាតផ្នែកខ្លឹមសារនិងផ្នែកអក្ខរាវិរុទ្ធជាក់ជាមិនខាន ។ ដូច្នេះ ហើយនាងខ្ញុំសូមធ្វើការលំអោនកាយសូមការអធ្យាស្រ័យ និង សូមអភ័យទោសពីសំណាក់លោក លោកស្រី សាស្ត្រាចារ្យ និង សិស្សនិស្សិត អ្នកអានគ្រប់មជ្ឈដ្ឋាន ។ នាងខ្ញុំនឹងរង់ចាំទទួលនូវមតិរិះគន់និងកែតម្រូវ ក្នុងន័យស្ថាបនា និង កែលម្អនូវសមិទ្ធផលមួយនេះឲ្យកាន់តែប្រសើរឡើងនិងសូមគោរពអរគុណចំពោះមតិរិះគន់កែលម្អ។

ជាទីបញ្ចប់នេះ នាងខ្ញុំ សូមគោរពជូនពរដល់អស់ លោក លោកស្រី សាស្ត្រាចារ្យ និង សិស្សនិស្សិត មិត្តអ្នកអានគ្រប់រូបឲ្យជួបប្រទះតែពុទ្ធពរទាំង៤ប្រការ គឺ **អាយុ វណ្ណៈ សុខៈ ពលៈ** និង ជៀសឆ្ងាយពីជម្ងឺកាចសាហាវទាំងពួង ។

# មាតិកា ទំព័រ

**សេចក្តីផ្តើម** ........ **១**

១. លំនាំបញ្ហានៃការស្រាវជ្រាវ ........ ១

២. ចំណោទបញ្ហានៃការស្រាវជ្រាវ ........ ២

៣. គោលបំណងនៃការស្រាវជ្រាវ ........ ៣

៤. ទំហំនិងដែនកំណត់នៃការស្រាវជ្រាវ ........ ៣

៥. សារៈសំខាន់នៃការស្រាវជ្រាវ ........ ៣

៦. វិធីសាស្ត្រស្រាវជ្រាវ ........ ៤

៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ ៤

**ជំពូកទី១: សញ្ញាណទូទៅនៃបណ្តឹងអាជ្ញា**

**ផ្នែកទី១៖សញ្ញាណទូទៅនៃបណ្តឹងអាជ្ញា** ........ **៦**

១.១ និយមន័យបណ្តឹងអាជ្ញា ........ ៦

១. ២ និយមន័យបណ្តឹងរដ្ឋប្បវេណី ........ ៧

១. ៣ ការប្រៀបធៀបបណ្តឹងអាជ្ញានិងបណ្តឹងរដ្ឋប្បវេណី ........ ៩

**ផ្នែកទី២៖លក្ខខណ្ឌនៃការដាក់ពាក្យបណ្តឹង** ........ **១១**

២.១ បុគ្គល ........ ១១

២.២ អត្ថិភាពនៃបទល្មើស ........ ១២

២.៣ ព្យសនកម្មនៃបទល្មើស ........ ១២

**ផ្នែកទី៣៖ បណ្តឹងអាជ្ញា** ........ **១២**

៣.១ ការដាក់ពាក្យបណ្តឹងឲ្យមានចលនា ........ ១២

៣.១.១ អយ្យការ ........ ១៣

៣.១. ២ ជនរងគ្រោះ ........ ១៣

៣.១.៣ ដោយមន្ត្រីរាជការឬភ្នាក់ងារសាធារណៈ.....................................................................................១៤
៣. ២. ជម្រើសនៃការចោទប្រកាន់.....................................................................................................១៥
៣.៣ ការបើកការស៊ើបសួរ ...........................................................................................................១៥
៣.៤ ការបញ្ជូនទៅជំនុំជម្រះផ្ទាល់ ..................................................................................................១៦
៣.៥ នីតិវិធីចូលបង្ហាញខ្លួនភ្លាម.................................................................................................... ១៧
៣.៦. សេចក្តីសម្រេចព្រះរាជអាជ្ញានៃចំណាត់ការ(គោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់)...១៨
៣.៧. ការដាក់បណ្តឹងអាជ្ញាឲ្យមានចលនាដោយជនរងគ្រោះ ......................................................១៩

## ជំពូកទី២: មូលហេតុនៃការរលត់បណ្តឹងអាជ្ញា

**ផ្នែកទី១៖មូលហេតុនៃការរលត់បណ្តឹងអាជ្ញាទូទៅ ........................................................ ២១**
១.១. មរណភាពនៃជនល្មើស ...................................................................................................... ២១
១.២. ការផុតអាជ្ញាយុកាល .........................................................................................................២២
១.២.១ ប្រភេទនៃអាជ្ញាយុកាល ...............................................................................................២២
១.២.១.១.អាជ្ញាយុកាលនៃបទល្មើស.......................................................................................២២
១.២.១.២ អាជ្ញាយុកាលនៃទោស..............................................................................................២៣
១.២.២ បទល្មើសដែលមិនអាចរួចផុតពីអាជ្ញាយុកាល.............................................................២៣
១.២.២.១ បទឧក្រិដ្ឋប្រល័យពូជសាសន៍................................................................................ ២៤
១.២.២.២ បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ................................................................................... ២៤
១.២.២.៣ បទឧក្រិដ្ឋសង្គ្រាម ................................................................................................... ២៥
១.២.៣ អាជ្ញាយុកាលនៃបណ្តឹងរដ្ឋប្បវេណី ............................................................................. ២៦
១.៣ ការលើកលែងទោសជាទូទៅ.................................................................................................. ២៦
១.៣.១ និយមន័យនៃលើកលែងទោស ......................................................................................២៧
១.៣.២ លក្ខខណ្ឌនៃការលើកលែងទោសរបស់ទណ្ឌិត ...............................................................២៧
១.៣.២.១ លក្ខខណ្ឌទូទៅនៃការបន្ធូរបន្ថយទោសនិងការលើកលែងទោសចោល ................២៧
១.៣.២.២ ការបន្ធូរបន្ថយទោស និង ការលើកលែងទោសដោយសារតែហេតុផលមនុស្សធម៌ ២៨
១.៣.២.៣ លក្ខខណ្ឌដោយឡែកនៃការលើកលែងទោសចោល ......................................... ២៨
១.៣.៣ ពិធីបុណ្យដែលអាចស្នើសុំការបន្ធូរបន្ថយទោសនិងការលើកលែងទោស...................... ២៨

១.៣.៤ អានុភាពនៃការលើកលែងទោសជាទូទៅ ............................................................ ២៩
១.៣.៥ អានុភាពនៃការលើកលែងទោសជាទូទៅ ចំពោះ ការទាមទារសំណងរបស់ជនរងគ្រោះ .. ២៩
១.៤ និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ ...................................................................... ៣០
១.៥. អាជ្ញាអស់ជំនុំ ................................................................................... ៣១
១.៥.១ ប្រភេទនៃអាជ្ញាអស់ជំនុំ ........................................................................ ៣២
**ផ្នែកទី២៖ មូលហេតុផ្សេងទៀតនៃការរលត់បណ្តឹងអាជ្ញា ...................................... ៣២**
២.១ ការសម្របសម្រួលជាមួយរដ្ឋ .................................................................... ៣២
២.២ ការដកពាក្យបណ្តឹង ដែលជា លក្ខខណ្ឌចាំបាច់ក្នុងការចោទប្រកាន់ជាបទព្រហ្មទណ្ឌ ........... ៣៤
២.៣. ការបង់ប្រាក់ពិន័យសុប្បប្រាក់ពិន័យសម្របសម្រួល ........................................... ៣៤

## ជំពូកទី៣ៈអានុភាពនិងនីតិវិធីនៃការរលត់បណ្តឹងអាជ្ញា

**ផ្នែកទី១៖ការតម្កល់រឿងទុកឥតចាត់ការ .......................................................... ៣៦**
១.១ សញ្ញាណទូទៅនៃការតម្កល់រឿងទុកឥតចាត់ការ ............................................ **៣៦**
១.១.១ អត្ថន័យនៃការតម្កល់រឿងទុកឥតចាត់ការ ..................................................... ៣៦
១.១.២ អាជ្ញាធរក្នុងការតម្កល់រឿងទុកឥតចាត់ការ ................................................... ៣៧
១.២ មូលហេតុនៃការតម្កល់រឿងទុកឥតចាត់ការ ..................................................... ៣៨
១.២.១ តម្កល់រឿងទុកឥតចាត់ការចំពោះអំពើមិនមែនជាបទល្មើស ................................ ៣៨
១.២.១.១ កង្វះធាតុផ្សំនៃបទល្មើស ................................................................... ៣៩
១.២.១.២ អវត្តមាននៃបទល្មើស ........................................................................ ៤០
១.២.២ ការតម្កល់រឿងទុកឥតចាត់ការចំពោះអំពើជាបទល្មើស ..................................... ៤១
១.២.២.១ មូលហេតុគតិយុត្ត ........................................................................... ៤២
១.២.២.២ ការចោទប្រកាន់មិនផ្តល់ផលប្រយោជន៍ ...................................................... ៤៦
១.៣ អានុភាពនិងនីតិវិធីនៃការតម្កល់រឿងទុកឥតចាត់ការ ............................................ ៤៧
១.៣.១ នីតិវិធីនៃការតម្កល់រឿងទុកឥតចាត់ការ ........................................................ ៤៧
១.៣.១.១ ការស្រាវជ្រាវ ................................................................................... ៤៧
១.៣.១.២ ការសម្រេចតម្កល់រឿងទុកឥតចាត់ការ ........................................................ ៤៧
១.៣.១.៣ ការជូនដំណឹង .................................................................................. ៤៨

១.៣.២ អានុភាពនៃការតម្កល់រឿងទុកឥតចាត់ការ ....................................................... ៤៨

១.៣.៣ យន្តការប្រឆាំងនឹងការតម្កល់រឿងទុកឥតចាត់ការ ............................................ ៤៨

**ផ្នែកទី២៖ នីតិវិធីនៃការរលត់បណ្តឹងអាជ្ញាក្នុងដំណាក់កាលការស៊ើបសួរ ឬ ដំណាក់កាលការជំនុំជម្រះ............................................................................................................. ៤៩**

២.១ សញ្ញាណទូទៅនៃដំណាក់កាលការស៊ើបសួរ.............................................................៤៩

២.១.១ យុត្តាធិការស៊ើបសួរ .........................................................................................៤៩

២.១.១.១ ការបើកការស៊ើបសួរ .....................................................................................៥០

២.១.១.២ កិច្ចស៊ើបសួរ ...............................................................................................៥០

២.១.១.៣ អំណាចរបស់ចៅក្រមស៊ើបសួរ...........................................................................៥១

២.១.១.៤ ការបិទកិច្ចស៊ើបសួរ.......................................................................................៥១

២.២ សញ្ញាណទូទៅនៃដំណាក់កាលការជំនុំជម្រះ.............................................................. ៥២

២.២.១ យុត្តាធិការជំនុំជម្រះ......................................................................................... ៥២

២.២.១.១ របៀបប្តឹងទៅតុលាការ .................................................................................. ៥៣

២.២.១.២ សិទ្ធិអំណាចចៅក្រមជំនុំជម្រះ ........................................................................ ៥៣

២.២.១.៣ ការពិភាក្សាដេញដោល ...................................................................................៥៤

២.២.១.៤ ការប្រកាសសាលក្រម.......................................................................................៥៤

២.៣. នីតិវិធីការរលត់បណ្តឹងអាជ្ញានៅក្នុងដំណាក់កាលការស៊ើបសួរ ឬ ដំណាក់កាលការជំនុំជម្រះដោយសារមរណភាពជនល្មើស...........................................................................................៥៥

២.៣.១ ដីកាលើកលែងចោទប្រកាន់..................................................................................៥៦

២.៣.២ ដីកាសម្រេចរលត់បណ្តឹងអាជ្ញា.............................................................................. ៥៧

២.៣.៣.សមត្ថកិច្ចរបស់តុលាការព្រហ្មទណ្ឌពីសេចក្តីសម្រេចដែលមិនអាចសម្រេចបានដោយសារតែមរណភាពជនជាប់ចោទ ...........................................................................................៥៨

**សេចក្តីសន្និដ្ឋាន..................................................................................................... ៦០**

**អនុសាសន៍............................................................................................................ ៦២**

**គន្ថនិទ្ទេស**

**បញ្ជីឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

ក្នុងនាមជានីតិរដ្ឋ ប្រទេសកម្ពុជាបានប្រកាន់ខ្ជាប់យកច្បាប់ជាគោលដូចមានចែងក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣ ត្រង់មាត្រា ១ កថាខណ្ឌ ១ ដែលបានចែងពីខ្លឹមសារថាព្រះមហាក្សត្រទ្រង់ប្រតិបត្តិតាមរដ្ឋធម្មនុញ្ញ និង តាមលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ។ ក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបានទទួលស្គាល់ និង គោរពសិទ្ធិមនុស្សដូចបានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ហើយនិង កតិកាសញ្ញា ព្រមទាំងអនុសញ្ញា ទាំងឡាយដែលទាក់ទងនឹងសិទ្ធិមនុស្ស សិទ្ធិនារី និង សិទ្ធិកុមារ ។ តាមរយៈការទទួលស្គាល់កតិកាសញ្ញាទាំងនេះប្រទេសកម្ពុជាត្រូវតែគោរពសិទ្ធិមនុស្សដែលមាននៅក្នុងច្បាប់ជាតិ និង ច្បាប់អន្តរជាតិដូចមានចែងក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាក្នុងមាត្រា ៣១ នៃច្បាប់នេះ ។ ដោយឡែកក្នុងនាមជារដ្ឋភាគីមួយនៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សដែលបានចែងពីសិទ្ធិបុគ្គលក្នុងការរស់រានមានជីវិត សេរីភាពនិងសន្តិសុខផ្ទាល់ខ្លួន ហើយគ្មានជនណាម្នាក់ត្រូវបានផ្តន្ទាទោសពីបទល្មើសព្រហ្មទណ្ឌដោយការប្រព្រឹត្ត ឬ បានភ្លាំងភ្លាត់ប្រព្រឹត្តដែលអំពើនោះមិនបានចែងក្នុងច្បាប់ជាតិ ឬ អន្តរជាតិឡើយ ។ តាមខ្លឹមសារនេះគឺ បានន័យថាប្រទេសកម្ពុជាត្រូវតែគោរពតាមគោលការណ៍នីត្យានុកូលភាពដែលជាកត្តាមួយចាំបាច់ក្នុងការកំណត់បាននូវបទល្មើសព្រហ្មទណ្ឌហេតុនេះហើយ ទើបព្រះរាជាណាចក្រកម្ពុជាបានចងក្រងក្រមព្រហ្មទណ្ឌដែលត្រូវបានសភាអនុម័តក្នុងឆ្នាំ២០០៩ ។ ទន្ទឹមនឹងមានក្រមព្រហ្មទណ្ឌសម្រាប់កំណត់បទល្មើសព្រហ្មទណ្ឌរួចហើយ ក៏នៅតែមិនទាន់គ្រប់គ្រាន់នោះទេ ទាល់តែមានច្បាប់មួយដែលធានាថារាល់ដំណើរការនៃបណ្តឹងអាជ្ញាដែលប្រព្រឹត្តឡើងនៅក្នុង ដំណាក់កាលទាំងបួននៃនីតិវិធីព្រហ្មទណ្ឌប្រកបដោយ យុត្តិធម៌ពោលគឺមានសមធម៌ និង សច្ចធម៌ក្នុងការកំណត់អត្ថិភាពនៃបទល្មើសព្រហ្មទណ្ឌនោះគឺលុះត្រាតែមានក្រមនីតិវិធីព្រហ្មទណ្ឌបន្ថែមទៀត ។ ដោយឡែកក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាត្រូវបានសភាអនុម័តកាលពីថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០០៧ នាសម័យប្រជុំរដ្ឋសភាលើកទី៦នីតិកាលទី៣ ។

នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌបានចែងពី គោលបំណងនៃក្រមនេះយ៉ាងច្បាស់លាស់នោះគឺ មានគោលបំណងកំណត់វិធានទាំងឡាយដែលត្រូវគោរព និង ត្រូវប្រព្រឹត្តតាមដោយហ្មត់ចត់ក្នុងការកំណត់ឲ្យច្បាស់នូវអត្ថិភាពនៃបទល្មើសព្រហ្មទណ្ឌ ។ ការកំណត់នូវអត្ថិភាពបទល្មើសព្រហ្មទណ្ឌមួយនោះគឺត្រូវចាប់ផ្តើមឡើងតាមរយៈបណ្តឹងអាជ្ញា ។ ហេតុនេះហើយបណ្តឹងអាជ្ញាពិតជាមានសារៈសំខាន់ណាស់ព្រោះជាការចាប់ផ្តើមឡើងដើម្បីទាមទារយុត្តិធម៌ក្នុងការគ្រប់គ្រងរដ្ឋ និង សង្គមដែលមានគោលដៅអនុវត្ត និង ផ្តន្ទាទោសដោយអំណាច

សាធារណៈចំពោះបទល្មើសដែលកើតមានឡើង ។ បណ្តឹងអាជ្ញាជាគន្លឹះចម្បងក្នុងការដឹងឮ និង បើកដំណើរការនៃការកំណត់វត្តមាននៃបទល្មើសក្នុងសង្គម ប៉ុន្តែផ្ទុយមកវិញ មានករណីនៃបណ្តឹងអាជ្ញាខ្លះត្រូវបានរលត់ទៅវិញ ។ បណ្តឹងអាជ្ញាត្រូវបានរលត់ដោយមានមូលហេតុមួយចំនួនដែលមានលក្ខណៈស្មុគស្មាញក្នុងការសិក្សាដែលជាផ្នែកចម្បងមួយនៃវិស័យគតិយុត្តកម្ពុជា ហើយម្យ៉ាងទៀតការរលត់បណ្តឹងអាជ្ញានៅតែជាចម្ងល់ដែលមិនទាន់បកស្រាយអោយបានច្បាស់លាស់ថា ការរលត់បណ្តឹងអាជ្ញាមានមូលហេតុបែបណា ហើយការរលត់បណ្តឹងអាជ្ញានាំឲ្យមានអានុភាពក្នុងការរលត់បណ្តឹងរដ្ឋប្បវេណីពិតប្រាកដដែរឬទេ ហើយមានអានុភាព និង នីតិវិធីបែបណាវិញនៅពេលរលត់បណ្តឹងអាជ្ញានៅក្នុងពេលដែលដំណើរការរឿងក្តីព្រហ្មទណ្ឌ ។ ដោយហេតុនេះហើយទើបប្រធានបទនេះតម្រូវឲ្យមានការសិក្សាស្រាវជ្រាវឲ្យបានច្បាស់លាស់ និង ធ្វើការសិក្សាលើរលត់បណ្តឹងអាជ្ញាបន្ថែមទៀត។

តាមការយល់ឃើញខាងលើនេះទើប នាងខ្ញុំ សម្រេចចិត្តធ្វើការសិក្សាស្រាវជ្រាវលើប្រធានបទនេះក្នុងសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្ររបស់នាងខ្ញុំ ដើម្បី ជាទុនក្នុងការទទួលបានចំណេះដឹងបន្ថែមទៀតលើប្រធានបទនេះហើយក៏ជាចំណែកមួយ ក្នុង ការចូលរួមកសាងប្រទេសជាតិតាមរយៈការលើកស្ទួយអំណាននៃវិស័យយុត្តិធម៌នៅប្រទេសកម្ពុជាក្នុងគោលដៅចែករំលែកជា ចំណេះដឹង ជូនចំពោះសំណាក់មិត្តនិស្សិត មិត្តអ្នកសិក្សាស្រាវជ្រាវ រួមទាំងបងប្អូនជនរួមជាតិទាំងឡាយដែលមាន គោលបំណង និង ចំណាប់អារម្មណ៍សិក្សាបន្ថែមលើប្រធានបទនេះក្នុងកម្មវត្ថុ ដើម្បីទទួលបាន ចំណេះដឹង បទពិសោធន៍ សម្រាប់ជាទុនសិក្សាក្នុងបច្ចុប្បន្ន និង អនាគត។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ដើម្បីជាភាពងាយស្រួលក្នុងការសិក្សាលើប្រធានបទការរលត់នៃបណ្តឹងអាជ្ញានេះ យើងគួរគប្បី សិក្សាលើចំណុច សំខាន់ ៗ មួយចំនួនក្នុងប្រធានបទនេះ ។ ហើយចំណុចសំខាន់ក្នុងការសិក្សាស្រាវជ្រាវលើប្រធានបទការរលត់នៃបណ្តឹងអាជ្ញាមានដូចជា:

- តើអ្វីទៅជាបណ្តឹងអាជ្ញានិងបណ្តឹងរដ្ឋប្បវេណី?
- តើមានមូលហេតុអ្វីខ្លះដែលនាំឲ្យរលត់បណ្តឹងអាជ្ញា?
- តើការរលត់នៃបណ្តឹងអាជ្ញាមានអានុភាព និង នីតិវិធីយ៉ាងដូចម្តេច?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវប្រធានបទនេះគឺមានគោលបំណងយ៉ាងមោះមុតក្នុងការប្រើប្រាស់ ដើម្បី ក្លាយជាផលប្រយោជន៍ដល់បុគ្គលគ្រប់រូបដែលមានគោលបំណងសិក្សា ឬ យកទៅអនុវត្តក្នុងនីតិវិធីនៃប្រព័ន្ធតុលាការពាក់ព័ន្ធនឹងប្រធានបទការរលត់នៃបណ្តឹងអាជ្ញា ។ នាងខ្ញុំ មានក្តីរំពឹងថាប្រធានបទនេះនឹងអាចឲ្យអ្នកសិក្សា និង បុគ្គលដែលចង់សិក្សាពីការរលត់នៃបណ្តឹងអាជ្ញា ហើយមានចម្ងល់ពាក់ព័ន្ធពីមូលហេតុនៃការរលត់បណ្តឹងអាជ្ញា នីតិវិធី និង អានុភាពនៃការរលត់បណ្តឹងអាជ្ញារួមទាំងហេតុផលដែលប្រទេសកម្ពុជាសម្រេចអនុវត្តប្រព័ន្ធច្បាប់ការរលត់នៃបណ្តឹងអាជ្ញានេះ ។ ប្រធានបទខាងលើធ្វើឲ្យ នាងខ្ញុំ សង្ឃឹមថានឹងជួយជាគន្លឹះសំខាន់ក្នុងការអនុវត្តច្បាប់នៃប្រទេសកម្ពុជារួមទាំងជួយដល់ប្រជាជនឲ្យយល់កាន់តែច្បាស់ពីការអនុវត្ត និង នីតិវិធីនៃការអនុវត្តច្បាប់ក្នុងប្រព័ន្ធតុលាការនៃព្រះរាជាណាចក្រកម្ពុជា។

## ៤. ទំហំនិងដែនកំណត់នៃការស្រាវជ្រាវ

ទំហំ និង ដែនកំណត់នៃការសិក្សាស្រាវជ្រាវនៃប្រធានបទសារណាខាងលើនេះនាងខ្ញុំនឹងបង្ហាញពីសញ្ញាណទូទៅនៃបណ្តឹងអាជ្ញា ដែលជា មូលដ្ឋានគ្រឹះក្នុងការស្វែងយល់ពី ការរលត់បណ្តឹងអាជ្ញា មូលហេតុនៃការរលត់បណ្តឹងអាជ្ញា អានុភាព និង នីតិវិធីការរលត់បណ្តឹងអាជ្ញាដែលបានអនុវត្តក្នុងករណីបណ្តឹងអាជ្ញាត្រូវបានរលត់ក្នុងដំណាក់កាលអយ្យការ ឬ ដំណាក់កាលការស៊ើបសួរ ឬ ដំណាក់កាលការជំនុំជម្រះ ។ ចំពោះការសិក្សាស្រាវជ្រាវនេះនាងខ្ញុំនឹងផ្តោតសំខាន់ លើ ការរលត់បណ្តឹងអាជ្ញាដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចយុត្តាធិការសាលាដំបូងតែប៉ុណ្ណោះ ។

សម្រាប់ឯកសារគោលនាងខ្ញុំសិក្សាដោយផ្អែកលើ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា និង បទដ្ឋានគតិយុត្តជាតិ និងអន្តរជាតិមួយចំនួនដែលពាក់ព័ន្ធនឹងប្រធានបទនេះរួមទាំងឯកសារសំខាន់ ៗ ផ្សេងទៀត ដូចជា សៀវភៅដែលរៀងរៀងដោយសាស្ត្រាចារ្យ អត្ថបទច្បាប់ផ្សេងៗ និង ការសាកសួរពីសាស្ត្រាចារ្យ បុគ្គលមានបទពិសោធន៍ និង ចំណេះដឹងនៅក្នុងវិស័យច្បាប់ផងដែរ។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

កិច្ចការស្រាវជ្រាវ ការរលត់នៃបណ្តឹងអាជ្ញាមានគុណតម្លៃដោយផ្តល់នូវចំណេះដឹង និង ពុទ្ធិ ចំពោះនិស្សិត និង អ្នកសិក្សាស្រាវជ្រាវជំនាន់ក្រោយឲ្យយល់កាន់តែច្បាស់នូវបណ្តឹងអាជ្ញា ការរលត់នៃបណ្តឹងអាជ្ញា មូលហេតុនៃការរលត់បណ្តឹងអាជ្ញា អានុភាព និង នីតិវិធីនៃបណ្តឹងអាជ្ញា និង ទិដ្ឋភាពជាក់ស្តែងដែលកើតមានឡើងក្នុងការរលត់បណ្តឹងអាជ្ញា។ លើសពីនេះទៅទៀតការសិក្សាស្រាវជ្រាវនេះបានផ្តល់នូវការអភិវឌ្ឍន៍ចំណេះដឹង ដល់នាង

ខ្ញុំឲ្យយល់កាន់តែច្បាស់លើច្បាប់ព្រហ្មទណ្ឌដែលរួមទាំងក្រមនីតិវិធីព្រហ្មទណ្ឌ និង ក្រមព្រហ្មទណ្ឌដែលបានជួយឲ្យនាងខ្ញុំបានសិក្សាបន្ថែមយ៉ាងស៊ីជម្រៅលើសពីការសិក្សានៅក្នុងសាកលវិទ្យាល័យ ។ ថ្វីត្បិតតែការសិក្សានេះមានប្រធានបទពាក់ព័ន្ធនឹងរដ្ឋធម្មនុញ្ញ និង ក្រមនីតិវិធីព្រហ្មទណ្ឌជាគោលចម្បង ប៉ុន្តែបានធ្វើឲ្យនាងខ្ញុំព្យាយាមសិក្សាបន្ថែមលើច្បាប់ដោយឡែក ដើម្បី ស្វែងយល់ពីរបបគតិយុត្តដែលបានកំណត់ក្នុងច្បាប់ ជាការឆ្លុះបញ្ចាំងការអនុវត្តនៃនីតិវិធីព្រហ្មទណ្ឌ និង ច្បាប់ដោយឡែកដែលជារបបគតិយុត្តមានឋានានុក្រមក្រោមរដ្ឋធម្មនុញ្ញដែលត្រូវបានអនុវត្តក្នុងប្រទេសកម្ពុជា ។ ហេតុនេះសាធារណជននឹងបានស្វែងយល់យ៉ាងស៊ីជម្រៅពីគោលការណ៍នៃបណ្តឹងអាជ្ញា និង ការរលត់នៃបណ្តឹងអាជ្ញាដែលមានចែងក្នុងរដ្ឋធម្មនុញ្ញដែលនាំឲ្យក្រមនីតិវិធីព្រហ្មទណ្ឌ និង ច្បាប់ដោយឡែកត្រូវអនុលោមតាមច្បាប់កំពូលនៃប្រទេសកម្ពុជា។

## ៦. វិធីសាស្ត្រស្រាវជ្រាវ

ខ្លឹមសារ និង ឯកសាររួមទាំងព័ត៌មានទាំងឡាយដែលយកមកចងក្រងសារណានេះឆ្លងកាត់តាមការស្រាវជ្រាវដូចខាងក្រោម:

- ការស្រាវជ្រាវសៀវភៅច្បាប់ដែលខ្លួនមានតាមបណ្ណាល័យ និង ប្រព័ន្ធអ៊ីនធើណិត
- ការស្រាវជ្រាវពីច្បាប់ដូចជា រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧ ក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ច្បាប់ជាតិ និង ច្បាប់អន្តរជាតិជាច្រើនដូចមានក្នុងផ្នែកឯកសារយោងស្រាប់ ។
- សិក្សាស្រាវជ្រាវពីសៀវភៅ និង ឯកសារដែលរៀបរៀងដោយសាស្ត្រាចារ្យច្បាប់ និង អ្នកមានវិជ្ជាជីវៈច្បាប់ដូចជាមេធាវី ចៅក្រម ព្រះរាជអាជ្ញា សារណារបស់សិស្សច្បង។ ជាពិសេសសិក្សាពីសៀវភៅ និង ឯកសារជាច្រើនទៀតដែលរៀបរៀងពីសំណាក់បុគ្គលជាទីគោរពជាច្រើនរូបទៀត ដែល សុទ្ធសឹងតែជាបុគ្គលគំរូ និង កសាងសមិទ្ធផលជាច្រើនក្នុងវិស័យគតិយុត្តនៅកម្ពុជាក្នុងការចងក្រង សៀវភៅ និង ឯកសារច្បាប់ជាច្រើនជាក់ស្តែងដូចជា ឯកឧត្តម ហ៊ី សោភា ឯកឧត្តម កើត រិទ្ធ លោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និង លោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត ជាដើម។
- ការសាកសួរដោយផ្ទាល់ពីសាស្ត្រាចារ្យផ្នែកច្បាប់ និង អ្នកមានបទពិសោធន៍ក្នុងវិស័យច្បាប់ ។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ខ្លឹមសារនៃការស្រាវជ្រាវត្រូវបានបែងចែកជាបីជំពូកមានដូចខាងក្រោម:

- **សេចក្តីផ្តើម**

- **ជំពូកទី១ សញ្ញាណទូទៅនៃបណ្តឹងអាជ្ញា**
- **ជំពូកទី២ មូលហេតុនៃការរលត់បណ្តឹងអាជ្ញា**
- **ជំពូកទី៣ អានុភាពនិងនីតិវិធីនៃការរលត់បណ្តឹងអាជ្ញា**

# ជំពូកទី១: សញ្ញាណទូទៅនៃបណ្ដឹងអាជ្ញា

## ផ្នែកទី១៖សញ្ញាណទូទៅនៃបណ្ដឹងអាជ្ញា

នៅពេលមានបទល្មើសព្រហ្មទណ្ឌកើតឡើងនាំឲ្យកើតមាននូវបណ្ដឹងអាជ្ញា ដែលមានអង្គការអយ្យការជាម្ចាស់នៃបណ្ដឹងអាជ្ញា ។ បទល្មើសព្រហ្មទណ្ឌគឺជា អំពើខ្លះរបស់រូបវន្តបុគ្គល ឬ នីតិបុគ្គលដែលបង្កចលាចលដល់សង្គម ។ បទល្មើសព្រហ្មទណ្ឌត្រូវបានចាត់ថ្នាក់ជាបីគឺ បទឧក្រិដ្ឋ បទមជ្ឈិម និង បទលហុ។[1] ដើម្បីអាចធ្វើការចោទប្រកាន់ទៅលើបុគ្គលណាម្នាក់ឲ្យទទួលខុសត្រូវព្រហ្មទណ្ឌក៏ត្រូវពិនិត្យទៅលើ កត្តារួមផ្សំនៃបទល្មើសដែលជាសំអាងផ្នែកនៃគតិយុត្តសម្រាប់ធ្វើការចោទប្រកាន់ដែល រួមមាន នីត្យានុកូលភាពនៃទោស ធាតុសត្យានុម័តនៃបទល្មើស ធាតុអត្តនោម័តនៃបទល្មើស ។[2] ហេតុនេះក្នុងការចោទប្រកាន់បុគ្គលណាម្នាក់ឲ្យទទួលខុសត្រូវព្រហ្មទណ្ឌត្រូវពិនិត្យទៅលើ ធាតុនីត្យានុកូលនៃទោសដែលសំដៅលើបទល្មើសនោះ មានចែងក្នុងបទប្បញ្ញត្តិព្រហ្មទណ្ឌជាធរមាន ។ ចំពោះធាតុសត្យានុម័តនៃបទល្មើសគឺជាផ្នែកខាងក្រៅនៃបទល្មើសរួមមានបណ្ដាសញ្ញាដែលជានិមិត្តរូបនៃបទល្មើសហើយបានស្ដែងចេញមកក្នុងលោកសម្ភារៈ ។ ចំណែកឯធាតុអត្តនោម័តនៃបទល្មើស គឺ សំដៅទៅលើកិរិយាផ្លូវចិត្តរបស់ជនល្មើសដែលសំដៅលើចេតនាក្នុងប្រព្រឹត្តអំពើបង្កគ្រោះថ្នាក់ដល់សង្គម ។ ដើម្បីកំណត់បានថាបុគ្គលម្នាក់បានប្រព្រឹត្តបទល្មើសឬទេ ហើយអំពើនោះប្រព្រឹត្តឡើងដោយចេតនា ឬ អចេតនា គឺទាល់តែការពិនិត្យទៅលើអត្ថិភាពនៃបទល្មើសដែលត្រូវចាប់ផ្ដើមឡើងតាមរយៈបណ្ដឹងអាជ្ញា និង បណ្ដឹងរដ្ឋប្បវេណី។ តើអ្វីទៅជាបណ្ដឹងអាជ្ញា ? តើអ្វីទៅជាបណ្ដឹងរដ្ឋប្បវេណី ?

### ១.១ និយមន័យបណ្ដឹងអាជ្ញា

អ្វីទៅជាបណ្ដឹងអាជ្ញា?

បណ្ដឹងអាជ្ញា និង បណ្ដឹងរដ្ឋប្បវេណីជាបណ្ដឹងពីរផ្សេងគ្នា ។

បណ្ដឹងអាជ្ញា គឺជា បណ្ដឹងមួយដែលមានគោលបំណងដ៏សំខាន់ក្នុងការពិនិត្យអត្ថិភាពនៃបទល្មើស និង បង្ហាញឲ្យឃើញពិរុទ្ធភាពនៃជនល្មើស និង ផ្ដន្ទាទោសជនល្មើសស្របតាមច្បាប់កំណត់ ។ ហើយអង្គអយ្យការគឺជាម្ចាស់បណ្ដឹងអាជ្ញា[3] ។ បណ្ដឹងអាជ្ញា គឺជា បណ្ដឹងមួយដែលត្រូវបានអនុវត្តលើគ្រប់រូបវន្តបុគ្គល នីតិបុគ្គល

[1] មាត្រា២នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[2] លោកមេធាវី មួន សៀងលី, វិទ្យាសាស្ត្រគតិយុត្តក្នុងការកំណត់បទល្មើស, រាជធានីភ្នំពេញ, ចុះថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ២០១៥

[3] លោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធនិងលោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត, វាក្យសព្ទគតិយុត្តក្នុងនីតិព្រហ្មទណ្ឌ ( ដកស្រង់ចេញពីនីតិព្រហ្មទណ្ឌនិងនីតិគ្រួសារ ) ឆ្នាំ២០១៧

ដោយឥតប្រកាន់នូវ ពូជសាសន៍ ពណ៌សម្បុរ ភេទ ជំនឿ សាសនា និន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន និង ស្ថានភាពផ្សេងទៀត ។[4] ពាក្យថារូបវន្តបុគ្គល គឺជា ពលរដ្ឋម្នាក់ ៗ ដែលមានសមត្ថភាពក្នុងការទទួលសិទ្ធិនិងកាតព្វកិច្ច ។ ចំណែកពាក្យនីតិបុគ្គល គឺជា បុគ្គលដែលបានកើតឡើងដោយសារការរួមប្រមូលផ្តុំនៃរូបវន្តបុគ្គល ឬ ជារូបវន្តបុគ្គលរួមក្រុមដែលបង្កើតបានជាអង្គការសង្គមណាមួយដូចជា ក្រុមហ៊ុន សមាគម ក្នុងទិសដៅអ្វីមួយ ។[5] ហេតុនេះមានន័យថា បណ្តឹងអាជ្ញាអាចត្រូវបានអនុវត្តលើគ្រប់បុគ្គល ទាំងបុគ្គលនោះប្រព្រឹត្តឡើងដោយខ្លួនឯង ឬ ប្រព្រឹត្តឡើងក្នុងនាមតំណាងស្ថាប័នណាមួយគឺត្រូវតែទទួលខុសត្រូវលើអំពើល្មើសនោះដោយមិនអាចលើកលែងបានដោយសារតែស្ថានភាព ឬ ឋានៈសង្គមនោះឡើយ ។ គោលការណ៍នៃការទទួលខុសត្រូវព្រហ្មទណ្ឌត្រូវធ្វើឡើងលុះត្រា បុគ្គលនោះបានប្រព្រឹត្តអំពើល្មើសដោយផ្ទាល់ខ្លួនតែប៉ុណ្ណោះ ។ ពោលគឺ បុគ្គលម្នាក់មិនត្រូវបានផ្តន្ទាទោសដោយសារទង្វើរបស់អ្នកដទៃ ឬ ទទួលខុសត្រូវព្រហ្មទណ្ឌជំនួសបុគ្គលផ្សេងឡើយ នេះជាគោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ។[6] ចំណែកនីតិបុគ្គលត្រូវតែទទួលខុសត្រូវបទល្មើសព្រហ្មទណ្ឌដែលបានប្រព្រឹត្តលើកលែងតែរដ្ឋចេញអាចត្រូវបានប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌពីបទល្មើសដែលប្រព្រឹត្តដោយអង្គការ ឬ អ្នកតំណាងរបស់ខ្លួនដើម្បីជាផលប្រយោជន៍របស់នីតិបុគ្គលនោះ ។ ម្យ៉ាងទៀត ការទទួលខុសត្រូវរបស់នីតិបុគ្គលនោះរួចហើយ មិនមែនលើកលែងនូវការទទួលខុសត្រូវព្រហ្មទណ្ឌរបស់រូបវន្តបុគ្គលក្នុងអំពើដដែលនោះទេ។[7]

ដូចនេះបណ្តឹងអាជ្ញា គឺ មានតំណាងអយ្យការដែលជាម្ចាស់នៃបណ្តឹងអាជ្ញា ឬ មានសមត្ថកិច្ចលើបណ្តឹងអាជ្ញានោះហើយបណ្តឹងអាជ្ញាកើតមានឡើង ដើម្បី ពិនិត្យអត្ថិភាពនៃបទល្មើសដែលអ្នកទទួលខុសត្រូវបទល្មើសព្រហ្មទណ្ឌអាចជារូបវន្តបុគ្គល ឬជា នីតិបុគ្គល។

## ១. ២ និយមន័យបណ្តឹងរដ្ឋប្បវេណី

តើអ្វីទៅជាបណ្តឹងរដ្ឋប្បវេណី?

បណ្តឹងរដ្ឋប្បវេណីគឺជាបណ្តឹងមួយ ដែលធ្វើឡើងដោយជនរងគ្រោះក្នុងគោលបំណងឲ្យមានការជួសជុលខូចខាតដែលបានបណ្តាលមកពីអំពើល្មើសដល់ ភាគីរងគ្រោះ ហើយក្នុងកម្មវត្ថុធ្វើឲ្យអ្នករងគ្រោះបានទទួល

[4] មាត្រា៣នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[5] លោកសាស្ត្រាចារ្យ អម សុផាណារ៉ាត, នីតិរដ្ឋប្បវេណី នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំសិក្សា២០១៨ ដល់២០១៩

[6] មាត្រា២៤នៃក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩

[7] មាត្រា៤២នៃក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩

សំណងជម្ងឺចិត្តធូនល្មមនឹងព្យសនកម្មដែលខ្លួនបានទទួល ។[8] នៅពេលមានបទល្មើសកើតឡើងដែលអាចបង្ក ជាព្យសនកម្មដល់អ្នករងគ្រោះ ហើយអ្នករងគ្រោះអាចដាក់ពាក្យប្ដឹងសាមញ្ញបាន ប៉ុន្តែ បណ្ដឹងសាមញ្ញនោះគ្មាន អានុភាពនាំឲ្យមានការចោទប្រកាន់ជាបទព្រហ្មទណ្ឌនោះឡើយ ។ ម្យ៉ាងទៀតប្រសិនបើការដាក់ពាក្យបណ្ដឹង មិនមានចម្លើយ ឬ ត្រូវបានតម្កល់ទុកឥតចាត់ការដោយព្រះរាជអាជ្ញា ជនរងគ្រោះអាចធ្វើការប្ដឹងទៅកាន់ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍បានក្នុងកំឡុងពេល ២ខែ គិតចាប់ពីថ្ងៃដែលបានទទួលដំណឹងពីព្រះរាជ អាជ្ញាក្នុងការតម្កល់រឿងទុកឥតចាត់ការ ។[9]

នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាបានអនុញ្ញាតឲ្យជនរងគ្រោះនៃបទឧក្រិដ្ឋ ឬ បទ មជ្ឈិមអាចដាក់ពាក្យប្ដឹងដោយតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនៅចំពោះមុខចៅក្រមស៊ើបសួរ ។ ពាក្យបណ្ដឹង នេះដោយមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីមានអានុភាពប្ដឹងដល់ចៅក្រមស៊ើបសួរអំពីបណ្ដឹងអាជ្ញាក្នុង លក្ខខណ្ឌដែលបញ្ញត្តិដោយមាត្រា ១៣៩ ( បានបញ្ជូនបណ្ដឹងទៅព្រះរាជអាជ្ញា ) និងមាត្រា១៤០ ( ការបង់ប្រាក់ តម្កល់ទុក )។ ក្នុងនោះយុត្តាធិការព្រហ្មទណ្ឌក៏អាចទទួលពាក្យបណ្ដឹងពី មន្ត្រីរាជការ ឬ ភ្នាក់ងារសាធារណៈដទៃ ទៀតដែលច្បាប់ដោយឡែកបានប្រគល់អំណាចឲ្យផងដែរ ។[10]

ក្រោយពីព្រះរាជអាជ្ញាបានឃើញពាក្យប្ដឹងដោយមានការតាំងខ្លួនជា ដើមបណ្ដឹងរដ្ឋប្បវេណី ព្រះរាជអាជ្ញា ត្រូវប្ដឹងទៅចៅក្រមស៊ើបសួរតាមដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ។ ហើយដីកាសន្និដ្ឋានបញ្ជូនរឿងនេះ អាចធ្វើឡើងប្រឆាំងនឹងអញ្ញាតជន ទោះបីជា បណ្ដឹងមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីដែលចោទទៅ លើឈ្មោះបុគ្គលម្នាក់ ឬ ច្រើននាក់ក៏ដោយ ។[11] ជនរងគ្រោះនៃបទល្មើសអាចជួសជុលព្យសនកម្មទាល់តែជា ផលវិបាកនៃបទល្មើស ជាព្យសនកម្មផ្ទាល់ខ្លួន បានកើតឡើង និង នៅក្នុងពេលបច្ចុប្បន្ន ។ ព្យសនកម្មអាចជា ព្យសនកម្មខាងសម្ភារៈ ខាងរូបកាយ ខាងផ្លូវចិត្ត ។[12]

ដូចនេះបណ្ដឹងរដ្ឋប្បវេណី គឺជា បណ្ដឹងមួយដែលជនរងគ្រោះនៃបទឧក្រិដ្ឋ និង បទមជ្ឈិម ធ្វើឡើងដើម្បី ទាមទារឲ្យមានការជួសជុលព្យសនកម្មដែលធ្វើឡើងចំពោះមុខចៅក្រមស៊ើបសួរដោយតាំងខ្លួនជា ដើមបណ្ដឹង រដ្ឋប្បវេណី ឬ ជនរងគ្រោះអាចដាក់ពាក្យបណ្ដឹងសាមញ្ញដែលមិនមានអានុភាពចោទប្រកាន់ជាបទល្មើស

---

[8] លោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និង លោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត, នីតិវិធីព្រហ្មទណ្ឌ , សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិង វិទ្យាសាស្ត្រសេដ្ឋកិច្ចឆ្នាំសិក្សា២០១៣ដល់២០១៤

[9] រៀបរៀងដោយលោកស្រី ឌី លីឡានិងលោក ខាន់ សុខា , នីតិវិធីព្រហ្មទណ្ឌ

[10] មាត្រា៦នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[11] មាត្រា១៣៩នៃនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[12] មាត្រា១៣នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

ព្រហ្មទណ្ឌទេ ។ ហើយបណ្ដឹងនេះអាចធ្វើឡើងបានដោយអ្នកតំណាងស្របច្បាប់ដែលបានកំណត់ ។ ហើយជនរងគ្រោះអាចទាមទារឲ្យមានការជួសជុលព្យសនកម្មបានទាល់តែអំពើនោះស្របតាមលក្ខខណ្ឌនៃ មាត្រា ១៣ ក្រមនីតិវិធីព្រហ្មទណ្ឌ។

## ១. ៣ ការប្រៀបធៀបបណ្ដឹងអាជ្ញានិងបណ្ដឹងរដ្ឋប្បវេណី

បណ្ដឹងអាជ្ញា និង បណ្ដឹងរដ្ឋប្បវេណីកើតចេញពីអង្គហេតុតែមួយដូចគ្នា ។ ទោះបីជាយ៉ាងណាអំពើខ្លះនាំឲ្យកើតបណ្ដឹងអាជ្ញាតែប៉ុណ្ណោះ ហើយក៏មិននាំឲ្យកើតជាបណ្ដឹងរដ្ឋប្បវេណីនោះទេ ផ្ទុយមកវិញអំពើខ្លះនាំឲ្យកើតបណ្ដឹងរដ្ឋប្បវេណីតែប៉ុណ្ណោះ ។ យ៉ាងណាក៏ហុសជាមូលដ្ឋាននាំឲ្យកើត បណ្ដឹងរដ្ឋប្បវេណី និង បណ្ដឹងអាជ្ញា ។ [13] បណ្ដឹងអាជ្ញា និង បណ្ដឹងរដ្ឋប្បវេណី អាចត្រូវបានធ្វើឡើងចំពោះមុខសាលាជម្រះក្ដីព្រហ្មទណ្ឌក្នុងពេលជាមួយគ្នា ។ បណ្ដឹងរដ្ឋប្បវេណីក៏អាចត្រូវធ្វើចំពោះមុខសាលាជម្រះក្ដីរដ្ឋប្បវេណី ក្នុងករណីដែលបណ្ដឹងរដ្ឋប្បវេណីត្រូវបានព្យួរទុកសិន ដរាបណាមិនទាន់មានសេចក្ដីសម្រេចជាស្ថាពរត្រូវបានប្រកាសលើបណ្ដឹងអាជ្ញា ។[14] ការជួសជុលព្យសនកម្មនៃបទល្មើស ចំពោះ ជនរងគ្រោះបានទាល់តែពិនិត្យជាមុនសិន ចំពោះធាតុផ្សំនៃបទល្មើសព្រហ្មទណ្ឌហើយត្រូវបានប្រកាសថា ជនជាប់ចោទត្រូវមានពិរុទ្ធភាពជាមុនសិន ។[15]

បណ្ដឹងអាជ្ញា និង បណ្ដឹងរដ្ឋប្បវេណីជាបណ្ដឹងពីរផ្សេងគ្នាដែលអាចធ្វើការកត់សម្គាល់ភាពខុសគ្នាដោយមើលទៅលើ គោលបំណង មូលដ្ឋានច្បាប់ ប្រភេទ ទណ្ឌកម្ម ភាគីនៃបណ្ដឹង ។[16]

- គោលបំណង: បណ្ដឹងអាជ្ញាមានបំណងជួសជុលការខូចខាតសណ្ដាប់ធ្នាប់សង្គម និង ផ្ដន្ទាទោសរាល់ការរំលោភលើច្បាប់ព្រហ្មទណ្ឌ ។ ចំណែកបណ្ដឹងរដ្ឋប្បវេណីវិញ ជាបណ្ដឹងដែលមានបំណងត្រឹមការជួសជុលព្យសនកម្មផ្ទាល់ខ្លួនដែលបានកើតឡើងចំពោះជនរងគ្រោះ ។
- មូលដ្ឋានផ្អែកច្បាប់:បណ្ដឹងអាជ្ញាមានមូលដ្ឋានផ្អែកច្បាប់ផ្អែកលើក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ ស្របតាមគោលការណ៍នីត្យានុកូលភាពនៃទោស និង បទល្មើស ។

[13] លោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និងលោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត, នីតិវិធីព្រហ្មទណ្ឌ , សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ចឆ្នាំ សិក្សា២០១៣ដល់២០១៤

[14] មាត្រា២២នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[15] មាត្រា២៣នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[16] លោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និង លោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត, នីតិវិធីព្រហ្មទណ្ឌ , សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ចឆ្នាំសិក្សា២០១៣ដល់២០១៤ ទំព័រទី២ដល់ទំព័រទី៣

ចំណែកបណ្តឹងរដ្ឋប្បវេណីមានមូលដ្ឋានលើក្រមរដ្ឋប្បវេណីដែលមានចែងពីអំពើអនីត្យានុកូលត្រង់គន្ថីទី៥ កិច្ចសន្យាសំខាន់ៗ និង អំពើអនីត្យានុកូល ត្រង់ជំពូកទី ១៦ ដែលចែងពីអំពើអនីត្យានុកូលនៃក្រមរដ្ឋប្បវេណី។[17] អំពើអនីត្យានុកូលគឺជាអំពើដែលបំពានដោយខុសច្បាប់លើសិទ្ធិ ឬ ផលប្រយោជន៍អ្នកដទៃដោយកំហុសចេតនា ឬ អចេតនា។[18]

- ប្រភេទៈ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបានចែងថា មានតែអង្គការអយ្យការទេ ដែលមានសិទ្ធិធ្វើបណ្តឹងអាជ្ញា ។[19] ហេតុនេះហើយ អង្គការអយ្យការជាម្ចាស់បណ្តឹងអាជ្ញា ដែលនាំឲ្យ បណ្តឹងអាជ្ញាមិនអាចធ្វើការលះបង់ដោយការដកពាក្យបណ្តឹងរបស់ជនរងគ្រោះនោះទេ ។ ការដកពាក្យបណ្តឹងរបស់ជនរងគ្រោះមិនអាចបញ្ឈប់ ឬ ព្យួរការអនុវត្តនៃបណ្តឹងអាជ្ញាបានទេ ។ ប៉ុន្តែលើកលែងក្នុងករណីបណ្តឹងអាជ្ញានោះ ដែលជា លក្ខខណ្ឌចាំបាច់នៃការចោទប្រកាន់ជាបទល្មើសព្រហ្មទណ្ឌ [20] ។ ចំណែកឯបណ្តឹងរដ្ឋប្បវេណី គឺជា បណ្តឹងដែលស្ថិតនៅក្នុងនីតិបេតិកភណ្ឌឯកជនរបស់ជនរងគ្រោះដែលអាចលះបង់ ឬ ដកពាក្យបណ្តឹងបានដូចមានចែងក្នុងមាត្រា ២៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌដែលចែងពីការលះបង់ និង ការដកពាក្យប្តឹងរបស់ជនរងគ្រោះ[21] ។
- ទណ្ឌកម្ម: បណ្តឹងអាជ្ញានាំមកនូវការដាក់ពិន័យជាប្រាក់ និង ដាក់ពន្ធនាគារដែលសមស្របទៅតាមភាពធ្ងន់ធ្ងរនៃកំហុស ។រីឯ បណ្តឹងរដ្ឋប្បវេណីវិញអាចឈានទៅដល់ការបង់សងជម្ងឺចិត្តដោយពុំគិតពីភាពធ្ងន់ធ្ងរនៃកំហុសតែគិតពីព្យសនកម្មដែលកើតមានឡើងទៅវិញ ។
- ភាគីនៃបណ្តឹង: នៅក្នុងបណ្តឹងអាជ្ញាភាគីនៃបណ្តឹង គឺជា អយ្យការ ជនជាប់ចោទ ឬ ជនត្រូវចោទ ។ នៅក្នុងបណ្តឹងរដ្ឋប្បវេណីជនរងគ្រោះជាអ្នកតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី រីឯ ភាគីម្ខាងទៀតជាជនជាប់ចោទ ឬ សន្តតិជននៃជនជាប់ចោទ ឬ អ្នកទទួលខុសត្រូវរដ្ឋប្បវេណី។

ដូចនេះហើយបណ្តឹងអាជ្ញា ឬ បណ្តឹងព្រហ្មទណ្ឌមានលក្ខណៈខុសគ្នានឹងបណ្តឹងរដ្ឋប្បវេណីមានដូចជាគោលបំណងនៃបណ្តឹង មូលដ្ឋានច្បាប់ ប្រភេទ ទណ្ឌកម្ម ភាគីនៃបណ្តឹង ។

[17] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧គន្ថីទី៥ ជំពូកទី១៦ ទំព័រទី២៦២ដល់ទំព័រទី២៧១

[18] សទ្ធានុក្រមផ្នែករដ្ឋប្បវេណីឆ្នាំ២០០៧ទំព័រទី២៩

[19] មាត្រា១៣១ថ្មី(មាត្រា១១២ចាស់)នៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣

[20] មាត្រា៨នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[21] មាត្រា២៥នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

# ផ្នែកទី២៖លក្ខខណ្ឌនៃការដាក់ពាក្យបណ្ដឹង

## ២.១ បុគ្គល

ការដាក់ពាក្យបណ្ដឹងព្រហ្មទណ្ឌទៅកាន់ស្ថាប័នតុលាការចាំបាច់ត្រូវការលក្ខខណ្ឌមួយចំនួនដែលតម្រូវឲ្យគោរពតាម ដើម្បី ឲ្យបណ្ដឹងនោះត្រូវបានទទួលយកហើយស្របច្បាប់ក្នុងការឲ្យតុលាការយករឿងក្ដីយកមកដោះស្រាយ ។ ក្នុងនោះដែលវត្តមាននៃបុគ្គល គឺជា លក្ខខណ្ឌចាំបាច់គឺត្រូវមានបុគ្គលដែលដាក់ពាក្យបណ្ដឹង និង បុគ្គលដែលត្រូវបានគេធ្វើការចោទប្រកាន់ ។[22] ជនដែលប្រព្រឹត្តបទល្មើស និង ជនរងគ្រោះអាចជានីតិបុគ្គល ឬ អាចជារូបវន្តបុគ្គល ។ រូបវន្តបុគ្គលគឺជា បុគ្គលដែលមានលក្ខណៈសម្បត្តិអាចក្លាយជាប្រធាននៃសិទ្ធិ និង កាតព្វកិច្ច ប៉ុន្តែ នីតិបុគ្គលក៏មានសិទ្ធិនេះដែរ ។ ស្របតាមច្បាប់បុគ្គលម្នាក់មានសមត្ថភាពក្នុងការទទួលសិទ្ធិនៅពេលចាប់កំណើតហើយបាត់បង់សិទ្ធិនេះនៅពេលទទួលមរណភាព ។ ផ្ទុយមកវិញច្បាប់ក៏បានចែងពីការផ្ដល់ឲ្យទារកដែលមានកំណើតមានសមត្ថភាពទទួលបាននូវសិទ្ធិមួយចំនួន ក្នុងការទាមទារសំណងនៃការខូចខាតដែលកើតចេញពីអំពើអនីត្យានុកូលបានក្រោយពីខ្លួនបានចាប់កំណើត ។ មានន័យថាទារកអាចអនុវត្តនូវសិទ្ធិរបស់ខ្លួនក្រោយពីពេលដែលខ្លួនបានចាប់កំណើតក្នុងការទាមទារខូចខាតនោះ ដែលជាសំណងរដ្ឋប្បវេណីតាមរយៈអ្នកតំណាងដែលច្បាប់បានកំណត់ ។[23]

យ៉ាងណាវិញក៏មានលក្ខខណ្ឌមួយចំនួនដែលបុគ្គលមិនទទួលខុសត្រូវព្រហ្មទណ្ឌដែលរួមមាន អនីតិជនដែលមានអាយុក្រោម ១៤ឆ្នាំ បុគ្គលដែលកើតមានវិបល្លាសស្មារតី ការអនុញ្ញាតដោយច្បាប់ ឬ អាជ្ញាធរ ការការពារស្របច្បាប់ ស្ថានភាពចាំបាច់ អានុភាពនៃកម្លាំង ឬ ការបង្ខំ។[24]

## ២.២ អត្ថិភាពនៃបទល្មើស

ប្រសិនបើមិនមានបទល្មើសនាំឲ្យមិនមានបណ្ដឹងអាជ្ញាកើតឡើងនោះទេ។តាមគោលការណ៍អនីត្យានុកូល គឺមានតែអំពើដែលមានចែងក្នុងបទប្បញ្ញត្តិព្រហ្មទណ្ឌប៉ុណ្ណោះ ទើបអាចផ្ដន្ទាទោសព្រហ្មទណ្ឌបាន ។ ហើយមានតែទោសចែងក្នុងបទប្បញ្ញត្តិព្រហ្មទណ្ឌប៉ុណ្ណោះ ទើបត្រូវបានផ្ដន្ទាទោសព្រហ្មទណ្ឌ [25] ។ គោលការណ៍នេះ

---

[22] និស្សិត ឃន ប៉េងឡុងនិង ឈឺន សុវណ្ណនារាជ សាស្រ្តាចារ្យណែនាំ លោក ជួន ប៊ុនធី , សារណាបញ្ចប់ការសិក្សាលំហូរនីតិវិធីនៃបណ្ដឹងព្រហ្មទណ្ឌឆ្នាំ២០២១

[23] សៀវភៅក្រមរដ្ឋប្បវេណីភាគ ១ បោះពុម្ពនៅក្នុងខែមីនាឆ្នាំ ២០១២ ទំព័រទី ១៥ និងទំព័រទី ១៦

[24] ឯកឧត្តម កើត រិទ្ធ សិក្ខាសាលាស្ដីពីការផ្សព្វផ្សាយក្រមព្រហ្មទណ្ឌប្រធានបទគោលការណ៍ទូទៅទាក់ទងនឹងការទទួលខុសត្រូវព្រហ្មទណ្ឌ

[25] មាត្រា៣នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

ហៅថា គ្មានបទល្មើស គ្មានទោសបើគ្មានច្បាប់ចែង ។ ម្យ៉ាងទៀតការកើតមាននូវអត្ថិភាពបទល្មើសទាល់តែអំពើនោះត្រូវបានស្តែងឡើងមកខាងក្រៅ ប្រសិនបើគ្រាន់តែជាបំណងដែលស្ថិតនៅក្នុងអារម្មណ៍របស់ពួកគេនៅឡើយបំណងនោះមិនអាចបង្កជាអន្តរាយណាមួយដល់សង្គមឡើយ ។ បទល្មើសគឺជា អំពើរបស់មនុស្សជាអង្គមានលក្ខណៈឯកភាពគ្មានរវាងការវិវឌ្ឍន៍ផ្លូវចិត្តនៃជនដែលបានប្រព្រឹត្តអំពើល្មើស និង រួមផ្សំបណ្តាលកត្តាស្តែងឡើងខាងក្រៅដែលអាចដឹងតាមរយៈវិញ្ញាណ ។ អំពើបទល្មើសជាក់ស្តែងតែងតែចាប់ផ្តើមពីផ្នែកសត្យានុម័តនៅពេលកំណត់បានថាអំពើនោះមានសញ្ញានៃផ្លូវចិត្តសិក្សាលើផ្នែកកិរិយាផ្លូវចិត្តរបស់បុគ្គលនោះ។[26]

### ២.៣ ព្យសនកម្មនៃបទល្មើស

ជនល្មើសត្រូវទទួលខុសត្រូវនូវអំពើរបស់ខ្លួនដែលបានបង្កជាព្យសនកម្មដល់ជនរងគ្រោះ ។ ព្យសនកម្មអាចជាព្យសនកម្មផ្នែកសម្ភារៈ ខាងរូបកាយ ឬ ខាងផ្លូវចិត្ត[27]។ ព្យសនកម្មផ្នែកសម្ភារៈរួមបញ្ចូលទាំងការខាតបង់ទ្រព្យសម្បត្តិ និង ចំណូល ។ ព្យសនកម្មរូបកាយ គឺជា ការខូតខាត ឬ ធ្វើឲ្យមានរបួសស្នាម ធ្វើឲ្យបាក់ខូតរាងកាយមនុស្សទោះជាស្រាល ឬ ធ្ងន់ក៏ដោយ ។ ព្យសនកម្មនេះគេអាចវាយតម្លៃតាមរយៈភ្ជាប់ជាមួយថ្លៃឯកសារថ្លៃចំណាយនានា ឬ លិខិតបញ្ជាក់ពីអ្នកជំនាញបានដើម្បីឲ្យតុលាការធ្វើការវាយតម្លៃបាន ។ ព្យសនកម្មផ្លូវចិត្តអាចរួមបញ្ចូលទាំងវិបល្លាសស្មារតី ឬ ជម្ងឺផ្លូវចិត្ត ឬ សតិអារម្មណ៍លើផ្លូវចិត្តរបស់ជនរងគ្រោះ ដូចជា ជម្ងឺបាក់ស្បាតជាដើម ។

## ផ្នែកទី៣៖ បណ្តឹងអាជ្ញា

### ៣.១ ការដាក់ពាក្យបណ្តឹងឲ្យមានចលនា

ការដាក់ពាក្យបណ្តឹងឲ្យមានចលនា គឺជា ការចោទប្រកាន់បទល្មើស ។ ការចោទប្រកាន់ពីបទព្រហ្មទណ្ឌនិង សុំឲ្យអនុវត្តច្បាប់ចំពោះមុខយុត្តាធិការស៊ើបសួរ និង យុត្តាធិការជំនុំជម្រះ ។ ហើយបណ្តឹងអាជ្ញានេះត្រូវបានចោទប្រកាន់ដោយ អង្គការអយ្យការ ជនរងគ្រោះដែលជាដើមបណ្តឹងរដ្ឋប្បវេណី ឬ ដោយមន្ត្រីរាជការ ឬ ភ្នាក់ងារសាធារណៈ។

---

[26] ឯកឧត្តម ហ៊ី សោភា, សៀវភៅនីតិព្រហ្មទណ្ឌទំព័រទី ៥៧

[27] អ៊ីណូម៉ាកា , នីតិវិធីព្រហ្មទណ្ឌស្តីពីការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីតាមផ្លូវអន្តរាគមន៍ ( ការផ្សព្វផ្សាយរបស់សមាគមត្រាជូ ) ខែ សីហា ២០១៦

### ៣.១.១ អយ្យការ

តំណាងអយ្យការ គឺជា ស្ថាប័នគោលដែលអាចដាក់ពាក្យបណ្តឹងអាជ្ញាឲ្យមានចលនាបាន ។ បណ្តឹងអាជ្ញាត្រូវបានអនុវត្តក្នុងនាមជាផលប្រយោជន៍ទូទៅដោយអយ្យការ។[28]

ព្រះរាជអាជ្ញាមានអំណាចក្នុងដឹកនាំ និង សម្របសម្រួលសកម្មភាពរបស់មន្ត្រី និង ភ្នាក់ងារនគរបាលយុត្តិធម៌ទាំងអស់នៅក្នុងសមត្ថកិច្ចនៃដែនដីរបស់ខ្លួន ហើយម្យ៉ាងទៀត ព្រះរាជអាជ្ញាអាចប្រើប្រាស់អំណាចទាំងនោះឲ្យដល់មន្ត្រីនគរបាលយុត្តិធម៌ក្នុងការស៊ើបអង្កេត ។[29] លក្ខខណ្ឌក្នុងការចោទប្រកាន់ព្រះរាជអាជ្ញាមិនអាចធ្វើការចោទប្រកាន់បានទេ ប្រសិនបើយល់ឃើញថាពុំទាន់មានភស្តុតាងគ្រប់គ្រាន់ក្នុងការចោទប្រកាន់នៅឡើយ ។ [30] ព្រះរាជអាជ្ញាអាចសម្រេចធ្វើការចោទប្រកាន់បទល្មើសព្រហ្មទណ្ឌ ក្រោយពីពេលដែលមានការស៊ើបអង្កេតបឋម ឬ បង្គាប់ឲ្យមានការស្រាវជ្រាវបន្ថែម ។[31]

### ៣.១. ២ ជនរងគ្រោះ

ការដាក់ពាក្យបណ្តឹងអាជ្ញាឲ្យមានចលនាដោយជនរងគ្រោះក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានចែងក្នុងមាត្រា ៥ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៅចំពោះមុខចៅក្រមស៊ើបសួរ ហើយ បណ្តឹងនោះមានអានុភាពចំពោះមុខចៅក្រមស៊ើបសួរទាល់មាន ការបញ្ជូនបណ្តឹងទៅព្រះរាជអាជ្ញាតាមមាត្រា ១៣៩ និង ការបង់ប្រាក់តម្កល់ទុកក្នុងមាត្រា ១៤០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។ [32] ក្នុងក្រមនីតិវិធីព្រហ្មទណ្ឌបានចែងពី ជនរងគ្រោះអាចដាក់ពាក្យបណ្តឹងសាមញ្ញផងដែរ ។

ការធ្វើបណ្តឹងរដ្ឋប្បវេណីចាំបាច់ត្រូវមានអ្នកតំណាងស្របច្បាប់កាលណាបើជនរងគ្រោះ គឺជា អនីតិជន ឬ ជនស្ថិតនៅក្រោមរបបច្បាប់ការពារដែលរួមមានជនស្ថិតនៅក្រោមអាណាព្យាបាលទូទៅ ឬ ជនស្ថិតនៅក្រោមហិតូបត្ថម្ភ ។[33] ដោយឡែកក្នុងករណីដែលជនរងគ្រោះបានបាត់បង់ជីវិតនោះសិទ្ធិវន្តនៃជនរងគ្រោះអាចផ្តើមធ្វើ ឬ បន្តនៃបណ្តឹងរដ្ឋប្បវេណីបាន ។[34]

---

[28] មាត្រា៤នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[29] មាត្រា៣៧នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ កថាខណ្ឌទី១និងទី២

[30] លោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និងលោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត , នីតិវិធីព្រហ្មទណ្ឌ , សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំសិក្សា ២០១៣ ដល់ ២០១៤ ទំព័រទី២៥

[31] មាត្រា៤០នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧កថាខណ្ឌទី២

[32] មាត្រា៥នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧

[33] មាត្រា១៥នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[34] មាត្រា១៦នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

ក្រៅពីបុគ្គលដែលកំណត់ខាងលើ ហើយច្បាប់ក៏បានអនុញ្ញាតសកម្មភាពបណ្តឹងរដ្ឋប្បវេណីជំនួសជនរងគ្រោះបានដែលរួមមាន :

- សមាគមប្រយុទ្ធប្រឆាំងនឹងអំពើហិង្សាខាងផ្លូវភេទ អំពើហិង្សាក្នុងគ្រួសារ អំពើហិង្សាប្រឆាំងនឹងកុមារ ។[35]
- សមាគមប្រយុទ្ធប្រឆាំងនឹងការចាប់ពង្រត់ ការជួញដូរមនុស្ស និង ការធ្វើអាជីវកម្មផ្លូវភេទ។[36]
- សមាគមប្រយុទ្ធប្រឆាំងនឹងការប្រកាន់ពូជសាសន៍ និង ការរើសអើង។[37]

ចុងចម្លើយនៃបណ្តឹងរដ្ឋប្បវេណីអាចធ្វើការប្រឆាំងនឹងជនទាំងអស់ដែលត្រូវជួសជុលព្យសនកម្មដែលមកពីបទល្មើស រួមមាន ចារី សហចារីនៃបទល្មើស អ្នកផ្តើមគំនិត អ្នកសមគំនិត អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ។[38]

### ៣.១.៣ ដោយមន្ត្រីរាជការឬភ្នាក់ងារសាធារណៈ

មន្ត្រីរាជការ ឬ ភ្នាក់ងារសាធារណៈអាចធ្វើបណ្តឹងអាជ្ញាបានដែលច្បាប់ដោយឡែកបានប្រគល់អំណាចឲ្យ។[39] ជាក់ស្តែងនៅក្នុងមាត្រា ១៣៤ នៃច្បាប់ស្តីពីសារពើពន្ធ អំណាចក្នុងការចោទប្រកាន់បទល្មើសព្រហ្មទណ្ឌបានកំណត់ពីការប្តឹងចោទប្រកាន់ និង ការទាមទារដាក់ទោសចំពោះបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារត្រូវធ្វើឡើងដោយអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារដោយមានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។[40]

ដូចនេះហើយបណ្តឹងអាជ្ញាត្រូវបានដាក់ឲ្យមានចលនាដោយអយ្យការ ដើមបណ្តឹងរដ្ឋប្បវេណី មន្ត្រីរាជការ ឬ ភ្នាក់ងារសាធារណៈ។

គួរឲ្យកត់សម្គាល់បណ្តឹងអាជ្ញាត្រូវបានទទួលព័ត៌មានតាមពីររូបភាពគឺ[41]:

- បណ្តឹងទាមទារដែលទទួលបានពីជនរងគ្រោះនៅក្នុងមាត្រា ៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។
- បណ្តឹងបរិហាដែលបានដឹងតាមរយៈតតិយជនក្រៅពីជនរងគ្រោះ ។ ហើយបណ្តឹងបរិហារនេះអាចកើតឡើងដោយការបំពេញកាតព្វកិច្ចដែលត្រូវប្តឹង ដូចជា អាជ្ញាធរសារធារណៈ ឬ មន្ត្រីគ្រប់រូបនៅពេល

---

[35] មាត្រា១៧នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[36] មាត្រា១៨នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[37] មាត្រា១៩នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[38] មាត្រា២១នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[39] មាត្រា៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧

[40] មាត្រា១៣៤នៃច្បាប់ស្តីពីសារពើពន្ធឆ្នាំ១៩៩៧

[41] ចក សម្បត្តិ អនុប្រធានសមាគមត្រាជូ , នីតិវិធីព្រហ្មទណ្ឌកម្ពុជា( សាលាត្រាជូ )

បំពេញមុខងាររបស់ខ្លួន ។[42] ហើយបណ្តឹងបរិហារនេះក៏អាចកើតចេញពីតតិយជនដែលមានដូចជា សារព័ត៌មាន ឬ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។[43]

### ៣. ២. ជម្រើសនៃការចោទប្រកាន់

ព្រះរាជអាជ្ញាមានជម្រើសមធ្យោបាយនៃការចោទប្រកាន់អាស្រ័យលើសំណុំរឿង នីតិវិធីដែលរួចរាល់ អាចបញ្ជូនទៅយុត្តាធិការជំនុំជម្រះ ឬ ផ្ទុយមកវិញអាចធ្វើការស៊ើបសួរយ៉ាងទូលំទូលាយពោល គឺ អាចប្តឹងទៅយុត្តាធិការជំនុំជម្រះ ឬ យុត្តាធិការស៊ើបសួរ ។ ការចោទប្រកាន់អាចធ្វើឡើងតាមមធ្យោបាយដូចជា[44]:

- ការបើកធ្វើការស៊ើបសួរ
- ការបញ្ជូនទៅជំនុំជម្រះផ្ទាល់
- តាមនីតិវិធីបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម។

### ៣.៣ ការបើកការស៊ើបសួរ

ក្នុងការវាយតម្លៃស្ថានភាពសំណុំរឿងនីតិវិធីធ្វើឲ្យព្រះរាជអាជ្ញាយល់ពីភាពចាំបាច់ក្នុងការស្រាវជ្រាវបន្ថែមដើម្បី ទទួលបានភស្តុតាងដែលអនុញ្ញាតឲ្យអនុវត្តបណ្តឹងអាជ្ញាឲ្យសមហេតុផល ។ ព្រះរាជអាជ្ញាមានជម្រើសពីរ គឺ បន្តធ្វើការស៊ើបអង្កេត ឬ ប្តឹងទៅចៅក្រមស៊ើបសួរតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ។ ព្រះរាជអាជ្ញាត្រូវតែបើកការស៊ើបសួរជាដាច់ខាតចំពោះបទឧក្រិដ្ឋ ។[45] ការបើកការស៊ើបសួរអាចបើកប្រឆាំងនឹងបុគ្គលម្នាក់ ឬ ច្រើននាក់ដោយមានចង្អុលប្រាប់ឈ្មោះ ឬ ប្រឆាំងទៅលើអញ្ញាតជន។

ក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររួមមាន សេចក្តីសង្ខេបនៃអង្គហេតុ ការកំណត់ឈ្មោះនៃបទល្មើស ការបង្ហាញពីអត្ថបទច្បាប់ដែលកំណត់ និង បង្ក្រាបបទល្មើសរួមទាំងឈ្មោះបុគ្គលដែលត្រូវរងការចោទប្រកាន់ ប្រសិនបើអាចកំណត់អត្តសញ្ញាណបាន ។ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរនោះត្រូវចុះកាលបរិច្ឆេទ និង ការចុះហត្ថលេខា។

ដូចនេះហើយព្រះរាជអាជ្ញាអាចធ្វើការស៊ើបសួរតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរទៅកាន់ចៅក្រមស៊ើបសួរ ឬ បន្តការស៊ើបអង្កេត។

---

[42] មាត្រា៤២នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[43] មាត្រា២៩នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[44] មាត្រា៤៣នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[45] មាត្រា៤៤នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

### ៣.៤ ការបញ្ជូនទៅជំនុំជម្រះផ្ទាល់

ព្រះរាជអាជ្ញាយល់ឃើញ ថា សំណុំរឿងអាចបញ្ជូនទៅតុលាការដោយពុំចាំបាច់មានការស្រាវជ្រាវផ្សេងទៀតឡើយ ។ គេសង្ស័យទៅលើបុគ្គលម្នាក់ដែលបានកំណត់នូវអត្តសញ្ញាណហើយបុគ្គលនោះត្រូវបានស្តីបន្ទោសពីបទល្មើសមួយ ឬ ច្រើនដែលជាបទមជ្ឈិម ឬ បទលហុ ។ ការប្តឹងទៅយុត្តាធិការជំនុំជម្រះព្រះរាជអាជ្ញាសម្រេចឲ្យបុគ្គលដែលពាក់ព័ន្ធមកបង្ហាញខ្លួនចំពោះមុខ ដើម្បី ធ្វើការចោទប្រកាន់ភ្លាម ៗ តាមរយៈមធ្យោបាយពីរ គឺ ការចូលបង្ហាញខ្លួនភ្លាម និង ដីកាបញ្ជូនទៅជំនុំជម្រះផ្ទាល់ប៉ុន្តែមិនត្រូវអនុវត្តចំពោះបទឧក្រិដ្ឋទេ ។[46] ការបញ្ជូនជនជាប់ចោទទៅជំនុំជម្រះផ្ទាល់នៅមុខតុលាការជាន់ដំបូងត្រូវធ្វើឡើងតាមរយៈ ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ។[47] ក្នុងដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ គឺជា បញ្ជាឲ្យជនជាប់ចោទចូលទៅបង្ហាញខ្លួននៅមុខតុលាការជាន់ដំបូង ។ ក្នុងដីកាកោះហៅបញ្ជូនជម្រះផ្ទាល់មានរួមបញ្ចូលដូចជា អត្តសញ្ញាណនៃជនជាប់ចោទ សេចក្តីសង្ខេបអង្គហេតុ ឈ្មោះនៃបទល្មើស អត្ថបទច្បាប់ដែលបានកំណត់ និង បង្ក្រាបបទល្មើស ។ ដីកានេះបង្ហាញប្រាប់ពី តុលាការ ទីកន្លែង កាលបរិច្ឆេទ និង ម៉ោងពេលសវនាការ ។ ជនជាប់ចោទអាចពឹងមេធាវីឲ្យអមខ្លួនបាន ។[48] ការកំណត់កាលបរិច្ឆេទនៃសវនាការត្រូវបានធ្វើឡើងដោយប្រធានតុលាការលើកលែងតែក្នុងករណីនៃនីតិវិធីចូលបង្ហាញខ្លួនភ្លាម ។[49] រយៈពេលដែលត្រូវគោរពរវាងការប្រគល់ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ឲ្យដល់ជនជាប់ចោទ និង ថ្ងៃកំណត់ឲ្យចូលបង្ហាញខ្លួននៅមុខតុលាការត្រូវមានកំណត់ដូចជា[50]:

- ១៥ ថ្ងៃប្រសិនបើជនជាប់ចោទរស់នៅក្នុងដែនដីនៃទីស្នាក់ការរបស់សាលាជាន់ដំបូង
- ២០ ថ្ងៃប្រសិនបើជនជាប់ចោទរស់នៅក្នុងទីកន្លែងមួយផ្សេងទៀតក្នុងដែនដីកម្ពុជា
- ២ ខែប្រសិនបើជនជាប់ចោទរស់នៅក្នុងរដ្ឋមួយជាប់ព្រំដែនព្រះរាជាណាចក្រកម្ពុជា។
- ៣ ខែប្រសិនបើជនជាប់ចោទនៅទីកន្លែងផ្សេងទៀត។

ការប្រគល់ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះអាចត្រូវបានប្រគល់ឡើងតាមមធ្យោបាយដូចជា:

- ការប្រគល់ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ដោយព្រះរាជអាជ្ញា[51]

---

[46] រៀបរៀងដោយលោកស្រី ឌី លីឡាទិងលោក ខាន់ សុខា , នីតិវិធីព្រហ្មទណ្ឌ

[47] មាត្រា៤៦នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[48] មាត្រា៤៧នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[49] មាត្រា២៩២នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[50] មាត្រា៤៥៦នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[51] មាត្រា៤៥៨នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

- ការប្រគល់ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ដោយអាជ្ញាសាលា[52]
- ការប្រគល់ចុងដីកាកោះហៅដោយអាជ្ញាសាលាដល់ជនជាប់ចោទ[53]
- ការប្រគល់ចុងដីកាកោះហៅដោយអាជ្ញាសាលាក្នុងករណីជនជាប់ចោទអវត្តមាន[54]
- ការប្រគល់ចុងដីកាកោះហៅដោយអាជ្ញាសាលាដល់មេឃុំ ឬ ចៅសង្កាត់[55]
- ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ក៏អាចត្រូវបានប្រគល់ដោយក្រឡាបញ្ជី ឬ តាមផ្លូវរដ្ឋបាល ឬ ដោយប្រធានពន្ធនាគារ ឬ មណ្ឌលឃុំខ្លួន ប្រសិនបើជនជាប់ចោទត្រូវឃុំខ្លួនពីបទល្មើសផ្សេងទៀត ឬ តាមរយៈអង្គការនរគបាល ឬ កងរាជអាវុធហត្ថ ។ [56]

ដូចនេះ ព្រះរាជអាជ្ញាអាចធ្វើការបញ្ជូនជនជាប់ចោទទៅជំនុំជម្រះផ្ទាល់នៅមុខតុលាការជាន់ដំបូងចំពោះបទមជ្ឈិម ឬ បទលហុតាមរយៈដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ។

## ៣.៥ នីតិវិធីចូលបង្ហាញខ្លួនភ្លាម

ការបង្ហាញខ្លួនភ្លាមត្រូវបានបង្គាប់ដោយ ព្រះរាជអាជ្ញាឲ្យនាំខ្លួនជនជាប់ចោទចូលបង្ហាញខ្លួនភ្លាមនៅចំពោះមុខតុលាការជាន់ដំបូងក្នុងករណីដែលមានគ្រប់លក្ខខណ្ឌដូចខាងក្រោម[57]:

- បទល្មើសជាក់ស្តែងដែលអាចជាបទឧក្រិដ្ឋ ឬ បទមជ្ឈិមជាក់ស្តែង និង បទល្មើសដែលចាត់ទុកដូចបទឧក្រិដ្ឋ ឬ បទល្មើសជាក់ស្តែង។
- បទល្មើសដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារយ៉ាងតិច ១ឆ្នាំ និង យ៉ាងច្រើន ៥ឆ្នាំ។
- ជនជាប់ចោទជានីតិជន
- រឿងក្តីមានលក្ខណៈគ្រប់គ្រាន់ល្មមជំនុំជម្រះបាន។

លក្ខខណ្ឌទម្រង់[58]

- ពិនិត្យអត្តសញ្ញាណបុគ្គលដែលគេបញ្ជូនមកឲ្យខ្លួន
- ប្រាប់ពីរឿងរ៉ាវដែលត្រូវចោទប្រកាន់ និង ឈ្មោះបទល្មើស

---

[52] មាត្រា៤៥៩នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[53] មាត្រា៤៦០នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[54] មាត្រា៤៦១នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[55] មាត្រា៤៦២នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[56] មាត្រា៤៦៣នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[57] មាត្រា៤៧នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[58] មាត្រា៤៨នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

- ទទួលចម្លើយរបស់បុគ្គលនោះប្រសិនបើសាមីខ្លួនចង់និយាយ
- ធ្វើកំណត់ហេតុស្តីពីការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម។
- ប្រាប់ជនជាប់ចោទពីសិទ្ធិពឹងមេធាវី
- ជនជាប់ចោទត្រូវបានបង្ខាំងខ្លួនទុកដោយកងកម្លាំងការពារ
- ជនជាប់ចោទមានរយៈពេលក្នុងការរៀបចំការពារខ្លួន
- សាលក្រមត្រូវប្រកាសក្នុងរយៈពេលដែលមិនអាចលើស២សប្តាហ៍។

ភាគីដែលកោះហៅក្នុងករណីចូលបង្ហាញខ្លួនភ្លាមព្រះរាជអាជ្ញាត្រូវកោះហៅឲ្យចូលក្នុងសវនាការមានដូចជា[59]:

- ជនរងគ្រោះ
- សាក្សី
- អ្នកបកប្រែ
- អ្នកទទួលខុសត្រូវរដ្ឋប្បវេណីតាមព័ត៌មានដែលផ្តល់ដោយជនជាប់ចោទ ឬ ដើមបណ្តឹងរដ្ឋប្បវេណី ។

ការកោះហៅឲ្យចូលរួមក្នុងពេលសវនាការត្រូវធ្វើដូចបានចែងក្នុងមាតិកាទី ១ គន្ថីទី ៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។ ប៉ុន្តែប្រសិនបើក្នុងករណីបន្ទាន់ព្រះរាជអាជ្ញាអាចកោះហៅ ជនរងគ្រោះ សាក្សី អ្នកបកប្រែ និង អ្នកទទួលខុសត្រូវរដ្ឋប្បវេណីតាមគ្រប់មធ្យោបាយទោះបីផ្ទាល់មាត់ក៏ដោយ។

ដូចនេះហើយ ព្រះរាជអាជ្ញាអាចបង្គាប់ឲ្យជនជាប់ចោទបង្ហាញខ្លួនភ្លាមចំពោះបទឧក្រិដ្ឋ ឬ បទមជ្ឈិមជាក់ស្តែង និង ការចាត់ទុកដូចជាបទឧក្រិដ្ឋ ឬ បទមជ្ឈិមជាក់ស្តែងចំពោះមុខតុលាការជាន់ដំបូងប្រសិនគ្រប់លក្ខខណ្ឌដែលមានចែងនៅក្នុងច្បាប់។

### ៣.៦. សេចក្តីសម្រេចព្រះរាជអាជ្ញានៃចំណាត់ការ( គោលការណ៍ភាពឆន្ទានុសិទ្ធិភាពនៃការចោទប្រកាន់ )

ក្រមនិតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ បានលើកឡើងពី គោលការណ៍នៃការចោទប្រកាន់មកអនុវត្ត ។ គោលការណ៍នេះត្រូវបានផ្តល់ឲ្យស្ថាប័នចោទប្រកាន់បទល្មើសព្រហ្មទណ្ឌត្រូវបានផ្តល់អំណាចក្នុងការជ្រើសរើសក្នុងការចោទប្រកាន់ ទោះបីជា អង្គហេតុនោះមានលក្ខណៈជាបទល្មើសព្រហ្មទណ្ឌក៏ដោយ ។[60] គោលការណ៍នេះខុសពីគោលការណ៍នីត្យានុកូលភាពនៃការចោទប្រកាន់ដែលស្ថាប័នទទួលបន្ទុកចោទប្រកាន់រឿងក្តីព្រហ្មទណ្ឌត្រង់ មិនចាប់បង្ខំដោយនីតិឲ្យធ្វើការចោទប្រកាន់គ្រប់រឿងក្តីនោះទេ ដែលបានគិត

[59] មាត្រា២៩៦នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[60] រៀបរៀងដោយលោកស្រី ឌី លីឡានិងលោក ខាន់ សុខា , នីតិវិធីព្រហ្មទណ្ឌ

ពីស្ថានភាពនៃបទល្មើស ឬ បរិបទសង្គម ឬ មនុស្សធម៌ ។ មាត្រា៤០ នៃក្រមនីតិវិធីព្រហ្មទណ្ឌបានចែងពីជម្រើសនៃការចោទប្រកាន់របស់ព្រះរាជអាជ្ញា ។ ចំពោះការពិនិត្យទៅលើកាលានុវត្តភាពនៃការចោទប្រកាន់ជាដំបូងព្រះរាជអាជ្ញាត្រូវពិនិត្យទៅលើធាតុផ្សំនៃបទល្មើស ដូចជា ធាតុផ្សំនីត្យានុកូល ធាតុផ្សំសត្យានុម័ត និង ធាតុផ្សំអត្តនោម័ត ហើយព្រះរាជអាជ្ញាត្រូវធ្វើការពិនិត្យលើករណីនៃបទល្មើសនោះមានអភ័យឯកសិទ្ធិដែរ ឬទេ ហើយត្រូវចោទក្នុងនាមអ្វី ។ ម្យ៉ាងទៀតព្រះរាជអាជ្ញាក៏ត្រូវពិនិត្យទៅលើទម្រង់ដូចជា ករណីរលត់នៃបណ្តឹងអាជ្ញា បញ្ហាសមត្ថកិច្ច និង ករណីនោះមានជនរងគ្រោះដែរឬទេ ។[61] ព្រះរាជអាជ្ញាត្រូវពិនិត្យមើលផងដែរ ចំពោះករណីជនល្មើសជា អនីតិជនដែរឬទេ ព្រោះ យោងតាមច្បាប់ស្តីពីយុត្តិធម៌អនីតិជនបានកំណត់ពីការទទួលខុសត្រូវព្រហ្មទណ្ឌត្រូវបានកំណត់ចាប់ពីអាយុ ១៨ឆ្នាំឡើងទៅ ។[62] ប៉ុន្តែអាចប្រកាសទណ្ឌកម្មទៅលើអនីតិជន ចាប់ពីអាយុ ១៤ឆ្នាំ ឡើងទៅប្រសិនបើកាលៈទេសៈនៃបទល្មើស ឬ បុគ្គលិកលក្ខណៈនៃអនីតិជននោះតម្រូវលើកលែងតែមានច្បាប់ពិសេសចែង ។

## ៣.៧. ការដាក់បណ្តឹងអាជ្ញាឲ្យមានចលនាដោយជនរងគ្រោះ

ការដាក់ពាក្យបណ្តឹងចំពោះមុខ ចៅក្រមស៊ើបសួរតាមមាត្រា ៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌដែលជាករណីអញ្ញត្រកម្ម ។ ការប្តឹងនេះជាសេរីភាពឆន្ទៈបុគ្គលឯកជន ។ ជនរងគ្រោះជានិច្ចកាលត្រូវពិចារណាឲ្យបានល្អិតល្អន់ ដោយហេតុថា បណ្តឹងនេះអាចត្រូវបានប្រតិកម្មតបត្រលប់មកវិញដោយអ្នកប្តឹងមានហានិភ័យក្នុងការប្រឈមមុខនឹងការពិន័យរដ្ឋប្បវេណី និងឲ្យជួសជុលការខូចខាតភាគីម្ខាងទៀតប្រសិនបើបណ្តឹងនោះជាបណ្តឹងរំលោភបំពាន ឬ អូសបន្លាយពេលវេលា ។[63] យោងតាមហេតុផលនេះគេយល់ឃើញថាបណ្តឹងនេះជាជម្រើសបណ្តឹងចុងក្រោយរបស់ជនរងគ្រោះ ឬ ភាគច្រើនជនរងគ្រោះធ្វើបណ្តឹងនេះក្រោយពីពេលដែលព្រះរាជអាជ្ញា ឬ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ សម្រេចសេចក្តីតម្កល់រឿងទុកឥតចាត់ការរបស់ព្រះរាជអាជ្ញាអមសាលាដំបូងហើយជនរងគ្រោះយល់ឃើញ ថា ខ្លួនទទួលរងការបំពានពីអំពើនោះហើយយល់ថា អំពើនោះមានចរិតលក្ខណៈជាបទល្មើសព្រហ្មទណ្ឌ ។[64] ក្រោយពីទទួលបានពាក្យបណ្តឹងនោះពីចៅក្រមស៊ើបសួររួចហើយព្រះរាជអាជ្ញាត្រូវធ្វើការប្តឹងទៅចៅក្រមស៊ើបសួរតាមរយៈដីកាបញ្ជូនរឿងឲ្យស៊ើបសួរ ។ ម្យ៉ាងទៀតព្រះរាជអាជ្ញាអាចស្នើ

---

[61] លោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និង លោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត, នីតិវិធីព្រហ្មទណ្ឌ , សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ចឆ្នាំសិក្សា២០១៣ដល់២០១៤ ទំព័រទី២៦

[62] មាត្រា៧នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជនឆ្នាំ២០១៦

[63] មាត្រា១៤២នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

រៀបរៀងដោយលោកស្រី ឌី លីឡា និង លោក ខាន់ សុខា , នីតិវិធីព្រហ្មទណ្ឌទំព័រទី៥៧

សុំចៅក្រមស៊ើបសួរមិនធ្វើការស៊ើបសួរ ក្នុង ករណីបណ្ដឹងអាជ្ញាត្រូវបានរលត់ និង មិនមែនជាបទល្មើសព្រហ្មទណ្ឌ ។

# ជំពូកទី២: មូលហេតុនៃការរលត់បណ្តឹងអាជ្ញា

## ផ្នែកទី១៖មូលហេតុនៃការរលត់បណ្តឹងអាជ្ញាទូទៅ

នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌបានចែងពីការចាប់ផ្តើមបណ្តឹងអាជ្ញា ហើយក៏មានចែងពីការរលត់នៃបណ្តឹងអាជ្ញាផងដែរ ។ បណ្តឹងអាជ្ញាអាចត្រូវបានរលត់នៅមុនពេលចាប់ផ្តើមនៃបណ្តឹងអាជ្ញា ឬ ស្ថិតនៅក្នុងដំណាក់កាលការពិនិត្យអត្ថិភាពនៃបទល្មើសរបស់តំណាងអយ្យការលើពាក្យបណ្តឹង ឬ ត្រូវបានរលត់បណ្តឹងអាជ្ញានៅក្នុងដំណាក់កាលការស៊ើបសួរ ឬ ដំណាក់កាលការជំនុំជម្រះដោយសារមូលហេតុនៃការរលត់បណ្តឹងអាជ្ញាក្នុងក្រមនីតិវិធីព្រហ្មទណ្ឌមាត្រា ៧ ។ ស្របតាមបញ្ញត្តិច្បាប់ព្រះរាជអាជ្ញាជាម្ចាស់នៃបណ្តឹងអាជ្ញា ។ ជាទូទៅបណ្តឹងអាជ្ញាត្រូវបានរលត់ដោយសារតែការអនុវត្តការតម្កល់រឿងទុកឥតចាត់ការ ដែលស្ថិត នៅក្នុងដំណាក់កាលអយ្យការដែលជាតួនាទីរបស់អយ្យការក្នុងការចោទប្រកាន់ ។ ការរលត់បណ្តឹងអាជ្ញាជាមូលហេតុមួយក្នុងចំណោមមូលហេតុផ្សេងទៀតដែលធ្វើឲ្យព្រះរាជអាជ្ញាសម្រេចតម្កល់រឿងទុកឥតចាត់ការ ។ ហើយមូលហេតុនៃការរលត់បណ្តឹងអាជ្ញាទូទៅមានចែងក្នុងមាត្រា ៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌដែលមានដូចជា មរណភាពនៃជនល្មើស ការផុតអាជ្ញាយុកាល ការលើកលែងទោសជាទូទៅ និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ អាជ្ញាអស់ជំនុំ ។

### ១.១. មរណភាពនៃជនល្មើស

តើអ្វីជានិយមន័យមរណភាព?

ពាក្យមរណភាពត្រូវបានត្រូវបានបើកចំហក្នុងការបកស្រាយតាមការអនុវត្តនៅកម្ពុជា ។ យោងតាមក្រមរដ្ឋប្បវេណីនៃប្រទេសជប៉ុនបានឲ្យន័យពាក្យមរណភាព គឺជា ពេលដែលសួត និង បេះដូង ខួរក្បាលឈប់មានដំណើរការហើយមានបញ្ជាក់មរណភាពដោយពិនិត្យលើការអស់ដង្ហើម បេះដូងបានឈប់លោត និង ការរីកប្រស្រីភ្នែកហើយព្រមទាំងមិនមានការប្រតិកម្មនៃពន្លឺ។[65]

មរណភាពនៃជនល្មើសជាមូលហេតុនៃការរលត់បណ្តឹងអាជ្ញាដោយហេតុថា មរណភាពរបស់ជនល្មើសប្រៀបបីដូចជាការរលត់នៃការទទួលខុសត្រូវរបស់ជនល្មើសក្នុងរឿងក្តីព្រហ្មទណ្ឌ ។ម្យ៉ាងទៀតតាមគោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌត្រូវបានមកអនុវត្តនៅក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌ ដែលមានចែងក្នុងមាត្រា ២៤ នៃក្រមព្រហ្មទណ្ឌ ។[66] បទល្មើសព្រហ្មទណ្ឌត្រូវបានទទួលខុសត្រូវនៅអំពើដែលខ្លួន

[65] សៀវភៅក្រមរដ្ឋប្បវេណីភាគ១បោះពុម្ពនៅក្នុងខែមីនាឆ្នាំ២០១២ទំព័រទី១៤

[66] មាត្រា២៤នៃក្រមព្រហ្មទណ្ឌ២០០៩

បានប្រព្រឹត្តផ្ទាល់ខ្លួនតែប៉ុណ្ណោះពោល គឺ សិទ្ធិវន្តរបស់ជនល្មើស ឬ បុគ្គលផ្សេងមិនអាចទទួលខុសត្រូវព្រហ្មទណ្ឌជំនួសជនល្មើសដែលទទួលមរណភាពក្នុងការផ្តន្ទាទោសព្រហ្មទណ្ឌឡើយ ។

ជាក់ស្តែងជនជាប់ចោទ លោក អៀង សារី បានទទួលមរណភាពនៅក្នុងកំឡុងពេលដំណើរការនីតិវិធីនៃរឿងក្តីនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) ។លោកស្រី ជា លាង ដែលជាសហព្រះរាជអាជ្ញាជាតិបានលើកឡើងក្នុងសន្និសីទកាសែតពីការផុតរលត់នៃបណ្តឹងអាជ្ញាដែលធ្វើឡើងប្រឆាំងនឹង លោក អៀង សារី ស្របតាមមាត្រា ៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌដែលចែងពីមូលហេតុនាំឲ្យរលត់នៃបណ្តឹងអាជ្ញា។[67]

នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ចែងពី ជនរងគ្រោះនៅតែអាចស្នើសុំឲ្យមានការជួសជុលព្យសនកម្មពីសិទ្ធិវន្តនៃជនជាប់ចោទបាន នៅពេលដែលជនជាប់ចោទបានទទួលមរណភាពក្នុងកំឡុងពេលដំណើរការរឿងក្តីព្រហ្មទណ្ឌ ហើយ តុលាការនៅតែមានសមត្ថកិច្ចក្នុងការសម្រេចលើបណ្តឹងរដ្ឋប្បវេណីដែលធ្វើឡើងក្នុងការប្រឆាំងសិទ្ធិវន្តរបស់ជនជាប់ចោទ ។[68]

ដូចនេះមរណភាពនៃជនល្មើសនាំឲ្យមានអានុភាពក្នុងការរលត់នៃបណ្តឹងអាជ្ញា ហើយ អានុភាពនោះមិននាំឲ្យរលត់បណ្តឹងរដ្ឋប្បវេណីនោះទេ។

### ១.២. ការផុតអាជ្ញាយុកាល

ការផុតអាជ្ញាយុកាលក៏ជា មូលហេតុនាំឲ្យរលត់បណ្តឹងអាជ្ញាផងដែរ ។ការផុតអាជ្ញាយុកាល គឺជា អវត្តមាននៃការដាក់បណ្តឹងអាជ្ញាឲ្យមានចលនាក្នុងអំឡុងពេលគិតចាប់ពីពេលប្រព្រឹត្តបទល្មើស ឬ អវត្តមាននៃការអនុវត្តបណ្តឹងអាជ្ញា។ [69]

#### ១.២.១ ប្រភេទនៃអាជ្ញាយុកាល

អាជ្ញាយុកាលមាន ២ គឺ អាជ្ញាយុកាលនៃបទល្មើស និង អាជ្ញាយុកាលនៃទោស ។ ហើយអាជ្ញាយុកាលទាំង ២ មានលក្ខណៈដូចខាងក្រោមៈ

##### ១.២.១.១.អាជ្ញាយុកាលនៃបទល្មើស

នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌមានចែងក្នុង មាត្រា ១០ ដែលមានថិរវេលានៃអាជ្ញាយុកាលនៃបណ្តឹងអាជ្ញាមានដូចជាៈ[70]

---

[67] គេហទំព័រ ជនជាប់ចោទអៀង សារីទទួលមរណភាព-បណ្តឹងអាជ្ញាត្រូវរលត់ (rfi.fr) ចូលទស្សនាថ្ងៃទី១១ខែមិថុនាឆ្នាំ២០២២

[68] មាត្រា២៨នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[69] ចក សម្បត្តិ អនុប្រធានសមាគមត្រាជូ , នីតិវិធីព្រហ្មទណ្ឌកម្ពុជា(សាលាត្រាជូ)

[70] មាត្រា១០នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

- បទឧក្រិដ្ឋមានរយៈពេល១៥ឆ្នាំ
- បទមជ្ឈិមមានរយៈពេល៥ឆ្នាំ។

ប៉ុន្តែក្នុងបទល្មើសបទប្តឹងបរិហារបង្កាច់កេរ្តិ៍ក្នុងមាត្រា ៣១១ នៃក្រមព្រហ្មទណ្ឌបាន ចែងពី បណ្តឹងអាជ្ញានៃបទល្មើសមានរយៈពេល ១ឆ្នាំ ។ ហើយចិរវេលានេះត្រូវចាប់ផ្តើមគិតពីថ្ងៃដែលបណ្តឹងបរិហារបានមកដល់ ឬ ថ្ងៃដែលពាក្យបណ្តឹងបានដាក់ដល់អាជ្ញាធរដែលមានសមត្ថកិច្ច។ [71]

- បទលហុរយៈពេល១ឆ្នាំ

ម៉្យាងទៀតចិរវេលាអាជ្ញាយុកាលនេះចាប់ផ្តើមគិតពីពេលប្រព្រឹត្តបទល្មើស ។ អាជ្ញាយុកាលនេះត្រូវបានផ្តាច់ដោយសារតែការចោទប្រកាន់ ឬ ដោយសារតែកិច្ចស៊ើបសួរ ។ ការបញ្ចប់កិច្ចស៊ើបសួរ ឬ កិច្ចចោទប្រកាន់នាំឲ្យចាប់ផ្តើមគិតចិរវេលានៃអាជ្ញាយុកាលសារជាថ្មី ហើយចិរវេលាថ្មីនេះអាចយកទៅជំទាស់បានចំពោះជនគ្រប់រូបដែលមានការទាក់ទងនៅក្នុងរឿងព្រហ្មទណ្ឌនេះ ។[72]

#### ១.២.១.២ អាជ្ញាយុកាលនៃទោស

អាជ្ញាយុកាលនៃទោស គឺជា ការមិនអាចអនុវត្តបានទៀតនោះឡើយ ។ ចិរវេលានៃអាជ្ញាយុកាលនៃទោសមានដូចជា[73]:

- បទឧក្រិដ្ឋមានរយៈពេល១៥ឆ្នាំ
- បទមជ្ឈិមមានរយៈពេល៥ឆ្នាំ។
- បទលហុរយៈពេល១ឆ្នាំ

អាជ្ញាយុកាលនៃទោសត្រូវបានគិតចិរវេលាចាប់ពីថ្ងៃដែលសេចក្តីសម្រេចផ្តន្ទាទោសបានក្លាយជាស្ថាពរ ។[74]

### ១.២.២ បទល្មើសដែលមិនអាចរួចផុតពីអាជ្ញាយុកាល

នៅក្នុង ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា បានចែងពី បទឧក្រិដ្ឋដែលគ្មានអាជ្ញាយុកាលកំណត់ដែលរួមមាន បទឧក្រិដ្ឋប្រល័យពូជសាសន៍ បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ បទឧក្រិដ្ឋសង្គ្រាម ដែលមិនអាចរួចផុតអាជ្ញាយុកាលបានទេ ។[75] ហើយនៅក្នុងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ក៏បានចែងពីភាព

---

[71] មាត្រា៣១២នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

[72] មាត្រា១១នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[73] មាត្រា ១៤៤ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ ២០០៩

[74] មាត្រា១៤៨នៃក្រមព្រហ្មទណ្ឌ ឆ្នាំ ២០០៩

[75] មាត្រា៩នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

មិនអាចផុតអាជ្ញាយុកាលនៃទោសមួយចំនួន ដូចជា បទឧក្រិដ្ឋដែលមានខាងលើក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ហើយ ច្បាប់ពិសេសក៏អាចធ្វើការកំណត់បទល្មើសផ្សេងទៀតភាពមិនអាចរលត់បណ្តឹងអាជ្ញានៃអាជ្ញាយុកាលផងដែរ[76]។

### ១.២.២.១ បទឧក្រិដ្ឋប្រល័យពូជសាសន៍

នៅក្នុងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាបាន ចែងពី បទឧក្រិដ្ឋប្រល័យពូជសាសន៍ គឺជា អំពើដែលមានគោលបំណងបំផ្លាញទាំងមូល ឬ ផ្នែកនៃក្រុមជាតិ ជាតិពន្ធុ ពូជសាសន៍ ឬ សាសនា តាមរយៈអំពើណាមួយដូចជាខាងក្រោមៈ[77]

១. ឃាតកម្មលើសមាជិកក្រុម

២. ការប៉ះពាល់យ៉ាងធ្ងន់ធ្ងរលើបូរណភាពខាងរូបកាយ ឬ សតិបញ្ញារបស់សមាជិកនៃក្រុម ។

៣. ការដាក់ឲ្យសមាជិកនៃក្រុមរស់នៅក្នុងលក្ខខណ្ឌ ដែលនាំឲ្យវិនាសអន្តរាយទាំងស្រុង ឬ មួយផ្នែកនៃក្រុម ។

៤. វិធានការដោយបង្ខំ ឬ មធ្យោបាយដោយមិនបង្ខំ សំដៅរារាំងកំណើតទារកនៅក្នុងក្រុម ។

៥. ជម្លៀសដោយបង្ខំនូវកុមារពីក្រុមមួយទៅក្រុមមួយផ្សេងទៀត ។

### ១.២.២.២ បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ

នៅក្នុងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាបានចែងពី បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ គឺជា អំពើត្រូវបានប្រព្រឹត្តនៅក្នុងក្របខ័ណ្ឌនៃការវាយលុកជាទូទៅ ឬ ជាប្រព័ន្ធសំដៅប្រឆាំងជនស៊ីវិលតាមរយៈអំពើណាមួយដូចជាខាងក្រោម[78]:

១. ឃាតកម្ម

២. ការសម្លាប់រង្គាល

៣. ការធ្វើឲ្យទៅជាទាសករ

៤. ការនិរទេស ឬ ជម្លៀសប្រជាជនដោយបង្ខំ

[76] មាត្រា១៨៣នៃក្រមព្រហ្មទណ្ឌ ឆ្នាំ ២០០៩

[77] មាត្រា១៨៣នៃក្រមព្រហ្មទណ្ឌ ឆ្នាំ ២០០៩

[78] មាត្រា១៨៨នៃក្រមព្រហ្មទណ្ឌ ឆ្នាំ ២០០៩

៥. ការដាក់ពន្ធនាគារ ឬ គ្រប់រូបភាពដទៃទៀតនៃការដកហូតយ៉ាងធ្ងន់ធ្ងរនូវសេរីភាពដោយបំពានទៅលើបទប្បញ្ញត្តិគ្រឹះនៃនីតិអន្តរជាតិ ។

៦. ការធ្វើទារុណកម្ម

៧. ការចាប់បង្ខំដោយសេពសន្ថវៈ ការធ្វើទាសកម្មតាមផ្លូវភេទ ពេស្យាដោយបង្ខំ ការមានគភ៌ដោយបង្ខំ វណ្ណកម្មដោយបង្ខំ និង គ្រប់រូបភាពផ្សេងទៀតនៃអំពើហិង្សាខាងផ្លូវភេទ ដែលមានទម្ងន់ប្រហាក់ប្រហែលគ្នា ។

៨. ការធ្វើទុកបុកម្នេញលើក្រុម ឬ សមូហភាពដោយមូលហេតុ នយោបាយ ពូជសាសន៍ ក្រុមជាតិពន្ធុ វប្បធម៌ សាសនា ឬ ភេទ។

៩. ការធ្វើឲ្យបាត់ខ្លួនដោយបង្ខំ

១០. ការអនុវត្តនយោបាយប្រកាន់ពូជសាសន៍ជាប្រព័ន្ធតាមបែបអាប៉ាថេដ ។

១១. គ្រប់អំពើមនុស្សធម៌ផ្សេងទៀត ដែលបង្កឲ្យមានការឈឺចាប់យ៉ាងខ្លាំង ឬ ការប៉ះពាល់យ៉ាងធ្ងន់ធ្ងរទៅលើបូរណភាពរូបកាយ ។

### **១.២.២.៣ បទឧក្រិដ្ឋសង្គ្រាម**

នៅក្នុងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាបានចែងពី បទឧក្រិដ្ឋសង្គ្រាម គឺជា អំពើដែលត្រូវបានប្រព្រឹត្តប្រឆាំងនឹងបុគ្គល ឬ ទ្រព្យសម្បត្តិដែលត្រូវបានការពារដោយអនុសញ្ញាក្រុងហ្សឺណែវចុះថ្ងៃទី ១២ ខែសីហា ឆ្នាំ ១៩៤៩ តាមរយៈអំពើណាមួយដូចជាខាងក្រោម[79]:

១. ឃាតកម្ម

២. ទារុណកម្ម ឬ គ្រប់អំពើអមនុស្សធម៌រួមទាំងការពិសោធន៍ជីវសាស្ត្រ។

៣. អំពើបង្កដោយចេតនានៃការឈឺចាប់ ឬ ប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់បូរណភាពខាងរូបកាយឬ សុខភាព។

៤. ការបំផ្លាញ ឬ ធ្វើឲ្យខូចខាតធ្ងន់ធ្ងរលើទ្រព្យសម្បត្តិដោយគ្មានហេតុផលចាំបាច់ខាងយោធា និង ក្នុងទ្រង់ទ្រាយធំដោយខុសច្បាប់និងតាមទំនើងចិត្ត។

៥. អំពើបង្ខំឈ្លើយសឹក ឬ ជនស៊ីវិលឲ្យបម្រើក្នុងកងប្រដាប់អាវុធរបស់សត្រូវ

៦. អំពើដកហូតសិទ្ធិរបស់ឈ្លើយសឹក ឬ ជនស៊ីវិល ក្នុងការទទួលការវិនិច្ឆ័យដោយត្រឹមត្រូវ និងឥតលំអៀង ។

---

[79] មាត្រា១៩៣នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

៧. ជម្លៀស ការជញ្ជូន ឬ ការឃុំឃាំងជនស៊ីវិលដោយខុសច្បាប់ ។

៨. ការចាប់ជនស៊ីវិលជាចំណាប់ខ្មាំង ។

### ១.២.៣ អាជ្ញាយុកាលនៃបណ្ដឹងរដ្ឋប្បវេណី

បណ្ដឹងរដ្ឋប្បវេណីដែលកើតឡើងពីការទាមទារឲ្យជួសជុលព្យសនកម្មពីបទល្មើសព្រហ្មទណ្ឌនោះមិនអាចធ្វើឡើងនៅចំពោះមុខតុលាការព្រហ្មទណ្ឌក្រោយផុតចិរវេលានៃអាជ្ញាយុកាលរបស់បណ្ដឹងអាជ្ញា ។ បណ្ដឹងរដ្ឋប្បវេណីនេះត្រូវផុតអាជ្ញាយុកាលតាមវិធាននៃក្រមរដ្ឋប្បវេណី។[80]

យោងតាមក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា បានចែងពី អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើការទាមទារសំណងនៃការខូតខាតដែលបណ្ដាលមកពី អំពើអនីត្យានុកូលត្រូវរលត់ដោយអាជ្ញាយុកាលកំឡុងពេល ៣ឆ្នាំ បានកន្លងហួសបន្ទាប់ពីពេលដែល ជនរងគ្រោះ ឬ តំណាងដែលច្បាប់បានកំណត់របស់ជនរងគ្រោះបានដឹងថា អាចទាមទារសំណងការខូតខាតចំពោះ អ្នកប្រព្រឹត្តអំពើបំពាន ឬ បើអំឡុងពេល ១០ឆ្នាំ បានកន្លងហួសបន្ទាប់ពីអំពើអនីត្យានុកូលនោះត្រូវបានប្រព្រឹត្តឡើង[81]។

ដូចនេះអាជ្ញាយុកាលនៃបណ្ដឹងរដ្ឋប្បវេណីត្រូវគិតតាមក្រមរដ្ឋប្បវេណី ប៉ុន្តែ ប្រសិនបើបណ្ដឹងអាជ្ញាបានរលត់រួចហើយបណ្ដឹងរដ្ឋប្បវេណីនោះមិនអាចធ្វើការទាមទារចំពោះមុខតុលាការព្រហ្មទណ្ឌឡើយ ។

## ១.៣ ការលើកលែងទោសជាទូទៅ

យោងតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបាន ចែងពី ព្រះមហាក្សត្រទ្រង់មានព្រះរាជសិទ្ធិក្នុងការបន្ធូរបន្ថយទោស និង លើកលែងទោស ។[82] នៅក្នុងមាត្រា ៩០ ( ពីរ) រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបានចែងពី រដ្ឋសភាអនុម័តច្បាប់ស្ដីពីការលើកលែងទោសជាទូទៅ ។[83] ការលើកលែងទោសជាទូទៅជាមូលហេតុមួយដែលនាំឲ្យរលត់បណ្ដឹងអាជ្ញា តែក្នុងករណីដែលការលើកលែងទោសធ្វើឡើងមុនការផ្ដន្ទាទោសជាស្ថាពរលើជនល្មើសតែប៉ុណ្ណោះ ប្រសិនបើការលើកលែងទោសជាទូទៅធ្វើឡើងក្រោយការផ្ដន្ទាទោសជាស្ថាពរ ឬ កំឡុងពេលអនុវត្តទោសនោះនាំឲ្យការលើកលែងទោសក្លាយជាមូលហេតុនៃការរលត់ទោសទៅវិញ[84] ។

[80] មាត្រា២៦នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[81] មាត្រា ៧៦៥ នៃ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[82] មាត្រា២៧រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣

[83] មាត្រា៩០(ពីរ)រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣

[84] រៀបរៀងដោយ លោក ហាក់ សៀកលីម , ការរំលត់បណ្ដឹងអាជ្ញា (ដំណាក់កាលស៊ើបអង្កេតព្រះរាជអាជ្ញា), ការផ្សាយរបស់សាលាត្រាជូ, ខែមិថុនាឆ្នាំ២០១៩

### ១.៣.១ និយមន័យនៃលើកលែងទោស

ការលើកលែងទោស គឺជា ការលើកចោលទាំងស្រុងឲ្យទៅទណ្ឌិតនូវសេរីភាពឡើងវិញហើយទណ្ឌកម្ម នោះមិនមានទណ្ឌកម្មតទៅទៀតនូវទោសនៃបទល្មើសដែលខ្លួនបានប្រព្រឹត្តតាម ព្រះរាជក្រឹត្យលើកលែងទោស របស់ព្រះមហាក្សត្រដូចមានចែងក្នុង មាត្រា២៧នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា។[85]

### ១.៣.២ លក្ខខណ្ឌនៃការលើកលែងទោសរបស់ទណ្ឌិត

ការទទួលបានការបន្ធូរបន្ថយទោស និង ការលើកលែងទោសមិនមែនជាសិទ្ធិរបស់ទណ្ឌិតនោះទេ ។ ហើយទណ្ឌិតដែលអាចបំពេញតាមលក្ខខណ្ឌនៃព្រះរាជក្រឹត្យ ស្តីពី ការបន្ធូរបន្ថយទោស និង ការលើកលែងទោសទើបអាចទទួលបានការអនុគ្រោះទោសជាការបន្ធូរបន្ថយទោស ឬ ជាការលើកលែងទោសបាន ។ ការបន្ធូរបន្ថយទោស ហើយនិង ការលើកលែងទោសអាចអនុវត្តបានតែចំពោះទណ្ឌិតដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារដោយសាលក្រម ឬ សាលដីកាស្ថាពរ។

#### ១.៣.២.១ លក្ខខណ្ឌទូទៅនៃការបន្ធូរបន្ថយទោសនិងការលើកលែងទោសចោល

ទណ្ឌិតដែលអាចទទួលបានការលើកលែងទោស និង បន្ធូរបន្ថយទោសទាល់តែទណ្ឌិតនោះអាចបំពេញតាមលក្ខខណ្ឌដូចខាងក្រោម[86]:

- ភ្ញាក់រលឹកខិតខំកែប្រែគំនិតមាយាទឲ្យក្លាយជាពលរដ្ឋសុចរិត ដើម្បី ចូលសមាហរកម្មចូលរួមរស់ក្នុងសង្គមវិញ
- គោរពប្រតិបត្តិបានយ៉ាងហ្មត់ចត់ និង ត្រឹមត្រូវតាមបទបញ្ជាផ្ទៃក្នុងរបស់ពន្ធនាគារ និង ក្លាយជាគំរូល្អដល់ទណ្ឌិត និង ជនជាប់ឃុំដទៃទៀត
- ចូលរួមអនុវត្តយ៉ាងសកម្ម និង ទៀងទាត់នូវកម្មវិធីអប់រំកែប្រែ កម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ និង សមាហរណកម្ម
- គោរពប្រតិបត្តិបានហ្មត់ចត់ និង ត្រឹមត្រូវតាមសេចក្តីណែនាំផ្សេងទៀតរបស់ពន្ធនាគារ។

ក្នុងនោះប្រធានពន្ធនាគារជាអ្នកវាយតម្លៃ និង បញ្ជាក់អំពីការបំពេញលក្ខខណ្ឌខាងលើរបស់ទណ្ឌិតដោយត្រូវបញ្ចូលឈ្មោះក្នុងបញ្ជីទណ្ឌិតដែលត្រូវសុំទៅគណៈកម្មាការរាជធានីខេត្ត និង គណកម្មការក្រសួងមហាផ្ទៃដើម្បីពិនិត្យ និង ការវាយតម្លៃពីកម្រិតនៃការកែប្រែរបស់ទណ្ឌិត។

[85] លោក សេង ស៊ីវុត្ថា (ចៅក្រមសាលាឧទ្ធរណ៍), ច្បាប់ព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

[86] មាត្រា៥ នៃព្រះរាជក្រឹត្យស្តីពីការបន្ធូរបន្ថយទោសនិងការលើកលែងទោសឆ្នាំ២០២១

#### ១.៣.២.២ ការបន្ធូរបន្ថយទោស និង ការលើកលែងទោសដោយសារតែហេតុផលមនុស្សធម៌

ចំពោះទណ្ឌិតដែលមាន វ័យចំណាស់ ស្ត្រីដែលមានគភ៌ ឬ មានជម្ងឺរ៉ាំរ៉ៃធ្ងន់ធ្ងរ វិបល្លាសស្មារតី ឬ ពិការភាព ដោយមាន លិខិតបញ្ជាក់ពីគ្រូពេទ្យដែលទទួលស្គាល់ពីក្រសួងមានសមត្ថកិច្ចអាចធ្វើការអនុវត្តការបន្ធូរបន្ថយទោស និង ការលើកលែងទោស[87] ។

ប្រធានពន្ធនាគារត្រូវធ្វើការបញ្ជាក់អំពីការបំពេញលក្ខខណ្ឌតាមស្ថានភាពនីមួយ ៗ របស់ទណ្ឌិត ដូចមានចែងក្នុងហេតុផលមនុស្សធម៌ខាងលើ ដើម្បី រៀបចំបញ្ជីឈ្មោះទណ្ឌិតដែលត្រូវស្នើសុំទៅគណៈកម្មាធិការរាជធានី ខេត្ត និង គណកម្មការក្រសួងមហាផ្ទៃ ។

#### ១.៣.២.៣ លក្ខខណ្ឌដោយឡែកនៃការលើកលែងទោសចោល

ចំពោះទណ្ឌិតដែលបានបំពេញលក្ខខណ្ឌតាមបញ្ញត្តិនៃ មាត្រា ៥ នៃព្រះរាជក្រឹត្យស្តីពីការបន្ធូរបន្ថយទោស និង ការលើកលែងទោសក្នុងករណីដែលទណ្ឌិតទទួលរងទោសដាក់ពន្ធនាគារ[88]:

- ចំនួនពីរភាគបីនៃទោស។
- ទណ្ឌិតដែលត្រូវទទួលទោស ដាក់ពន្ធនាគារអស់មួយជីវិតអាចទទួលបាន ការលើកលែងទោស ប្រសិនបើទណ្ឌិតអាចអនុវត្តទោសបានយ៉ាងតិចសាមសិបឆ្នាំ ឬ ២០ឆ្នាំ ក្នុងករណីដែលមានការបន្ធូរបន្ថយទោស។

### ១.៣.៣ ពិធីបុណ្យដែលអាចស្នើសុំការបន្ធូរបន្ថយទោសនិងការលើកលែងទោស

ពិធីបុណ្យដែលអាចធ្វើការស្នើសុំការបន្ធូរបន្ថយទោស និង ការលើកលែងទោសចំពោះទណ្ឌិតកំណត់ ៥ ដងក្នុងមួយឆ្នាំដែលមានដូចខាងក្រោម[89]:

- ទិវាជ័យជម្នះលើរបបប្រល័យពូជសាសន៍
- ពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ
- ពិធីបុណ្យពិសាខបូជា
- ពិធីបុណ្យឯករាជ្យជាតិ ។
- ព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និង សំពះខែ អកអំបុក។

[87] មាត្រា៦នៃព្រះរាជក្រឹត្យស្តីពីការបន្ធូរបន្ថយទោសនិងការលើកលែងទោសឆ្នាំ២០២១

[88] មាត្រា១០នៃព្រះរាជក្រឹត្យស្តីពីការបន្ធូរបន្ថយទោសនិងការលើកលែងទោសឆ្នាំ២០២១

[89] មាត្រា៣នៃព្រះរាជក្រឹត្យស្តីពីការបន្ធូរបន្ថយទោសនិងការលើកលែងទោសឆ្នាំ២០២១

ចំពោះការបន្ធូរបន្ថយទោស និង ការលើកលែងទោសក៏អាចធ្វើសម្រាប់ពិធីបុណ្យនីមួយៗខាងលើដាច់ដោយឡែកពីគ្នា ឬ រួមគ្នា ។ ការបន្ធូរបន្ថយទោស និង ការលើកលែងទោសក៏អាចធ្វើបានដែរក្នុងពិធីបុណ្យជាតិ ឬ ព្រឹត្តិការណ៍ធំ ៗ របស់ជាតិ។

### ១.៣.៤ អានុភាពនៃការលើកលែងទោសជាទូទៅ

អានុភាពនៃការលើកលែងទោសជាទូទៅ គឺជា ការបំបាត់ចោលនូវទណ្ឌកម្មដែលពាក់ព័ន្ធនៃច្បាប់ស្ដីពីការលើកលែងទោសជាទូទៅ ។ អានុភាពនៃការលើកលែងទោសជាទូទៅមានអានុភាព ដូចជា ទោសមិនអាចយកមកអនុវត្តទេ ។ ចំពោះទោសដែលកំពុងអនុវត្តត្រូវបានបញ្ចប់។

ចំពោះប្រាក់ពិន័យ និង ប្រាក់ប្រដាប់ក្ដីដែលបង់រួចហើយមិនអាច ទាមទារសំណងពីរដ្ឋវិញបានទេ [90] ។ ការលើកលែងទោសជាទូទៅ ក៏មានអានុភាពចំពោះ ករណីនៃការមិនរាលចាលដែលមិនត្រូវបានកត់ត្រាទុកនោះទេ ប្រសិនបើទោសដែលបានផ្ដន្ទាទោសជាស្ថាពរនោះត្រូវបានលើកលែងទៅតាមច្បាប់ស្ដីពីការលើកលែងទោសជាទូទៅដែលសភាបានអនុម័តនោះ ។

ដូចនេះហើយ ការលើកលែងទោសជាទូទៅអាចមានអនុភាពដល់បទល្មើសដែលមិនអាចយកអនុវត្តហើយមានអានុភាពបញ្ចប់ការផ្ដន្ទាទោសដាក់ពន្ធនាគារនៃ ជនល្មើសហើយក៏មានអានុភាពដល់ការមិនយកទៅអនុវត្តអំពីករណីនៃភាពមិនរាងចាល និង លុបចេញពីបញ្ជីថ្កោលទោសហើយក៏មានអានុភាពធ្វើឲ្យរលត់នៃបណ្ដឹងអាជ្ញា។

### ១.៣.៥ អានុភាពនៃការលើកលែងទោសជាទូទៅ ចំពោះ ការទាមទារសំណងរបស់ជនរងគ្រោះ

ការលើកលែងទោសជាទូទៅមិនមែនជាឧបសគ្គ ដល់ សិទ្ធិរបស់ជនរងគ្រោះក្នុងការទាមទារសំណងនៃការជួសជុលការខូតខាតដែលបណ្ដាលមកពីបទល្មើសនោះឡើយ។[91]

ដូចនេះហើយ ការលើកលែងទោសជាទូទៅមានអានុភាពក្នុងការរលត់បណ្ដឹងអាជ្ញា ប៉ុន្តែ មិនមែនជាឧបសគ្គរាំងនៃការទាមទារការខូតខាតរបស់ជនរងគ្រោះតាមរយៈបណ្ដឹងរដ្ឋប្បវេណី។

---

[90] មាត្រា១៩៣នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

[91] មាត្រា១៥១នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

## ១.៤ និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ

និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ គឺជា ការលុបចោលនៃអង្គហេតុល្មើសដែលបានប្រព្រឹត្តមុន និង ក្រោយការចូលជាធរមាននៃច្បាប់ដែលត្រូវបាននិរាករណ៍ ។ ការនិរាករណ៍នៃច្បាប់នេះមានអានុភាពនាំឲ្យរលត់នៃបណ្តឹងអាជ្ញាស្របតាមមាត្រា ៧ នៃច្បាប់នីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ។

នៅក្នុងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៩ ត្រង់មាត្រា ៦៧១ បានចែងពីនិរាករណ៍ និង អានុភាពនៃបទប្បញ្ញត្តិព្រហ្មទណ្ឌពីមុនដែលរួមមានដូចជា:

១. រាល់ប្បញ្ញត្តិព្រហ្មទណ្ឌមុនឆ្នាំ១៩៩២

២. បទប្បញ្ញត្តិព្រហ្មទណ្ឌនៃបទប្បញ្ញត្តិស្តីពីប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និង នីតិវិធីព្រហ្មទណ្ឌសម្រាប់អនុវត្តនៅប្រទេសកម្ពុជាក្នុងសម័យអន្តរកាលចុះថ្ងៃទី១០ខែកញ្ញាឆ្នាំ១៩៩២។

៣. ច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋដែលត្រូវបានប្រកាសឲ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/ ០១០២ / ០០៤ចុះថ្ងៃទី ៧ ខែ មករា ឆ្នាំ ២០០២។

ម្យ៉ាងទៀតចំពោះបទប្បញ្ញត្តិនៃច្បាប់ផ្សេងទៀតដែលមានអានុភាពនៅពេលក្រមនេះត្រូវបានអនុវត្តហើយផ្ទុយនឹងបទប្បញ្ញត្តិនៃក្រមនេះ ត្រូវចាត់ទុកថាគ្មានអានុភាពត្រឹមទំហំដែលផ្ទុយនឹងក្រមនេះចាប់ពីថ្ងៃដែលក្រមនេះត្រូវបានអនុវត្ត។

ជាក់ស្តែងនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ១៩៦៧ គឺ ចំពោះបទឧក្រិដ្ឋមានទោសប្រហារជីវិតដោយត្រូវពិឃាតដោយបាញ់នឹងកាំភ្លើងលុះត្រាដល់ស្លាប់[92]។ ប៉ុន្តែទោសប្រហារជីវិតនេះមិនត្រូវបានអនុវត្តទៀតនោះដោយហេតុក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ បានចែងពីទោសប្រហារជីវិតមិនត្រូវមានឡើយ[93]។ ហើយនៅក្នុងក្រមព្រហ្មទណ្ឌបានចែងពី ការនិរាករណ៍រាល់បទប្បញ្ញត្តិព្រហ្មទណ្ឌមុនឆ្នាំ ១៩៩២ នាំឲ្យក្រមព្រហ្មទណ្ឌឆ្នាំ ១៩៦៧ មិនអាចអនុវត្តបានទៀត ។ ហេតុនេះហើយទោសប្រហារជីវិតនៅកម្ពុជាមិនត្រូវបានអនុវត្តទៀតទេ។ ម្យ៉ាងក្នុងក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩ មានត្រឹមតែផ្តន្ទាទោសដាក់ពន្ធនាគារ និង ទោសពិន័យហើយទោសដាក់ពន្ធនាគារធ្ងន់ធ្ងរបំផុតគឺទោសដាក់ពន្ធនាគារអស់មួយជីវិត។

នៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ១៩៦៧ ចាត់ទុកថាអំពើមួយចំនួនដែលចាត់ទុកថាជាអំពើល្មើសប៉ុន្តែនៅក្នុងក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៩ មិនមានចែងពីអំពើនោះជាបទល្មើសហើយច្បាប់ព្រហ្មទណ្ឌចាស់ត្រូវបាន

[92] របស់លោក ធរត សុត ( សៀវភៅសិក្សាច្បាប់គ្រប់មាត្រាទាំងអស់ក្នុងក្រមព្រហ្មទណ្ឌ, ក្រសួងយុត្តិធម៌) មាត្រា២៤-ថ្មីនៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៦៧

[93] មាត្រា៣២កថាខណ្ឌទី២នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

និរាករណ៍នាំឲ្យមានអានុភាពរលត់បណ្តឹងអាជ្ញា ព្រោះថា អំពើនោះមិនមែនជាបទល្មើសនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ ជាហេតុនាំឲ្យព្រះរាជអាជ្ញាសម្រេចធ្វើការតម្កល់រឿងទុកឥតចាត់ការ ។ ឧទាហរណ៍ នៅក្នុងមាត្រា ៣៦៩-៩១ ក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ១៩៦៧ ចែងថាជាអំពើល្មើសប្រសិនបើបុគ្គលណាដែលមិនធ្វើការប្តឹងរាជការឃុំដែលខ្លួនលែងនៅពីការផ្លាស់លំនៅនោះនិងមិនប្តឹងរាជការឃុំក្នុងឃុំថ្មីដែលខ្លួនចូលទៅនៅនោះទេ[94] ។ ផ្ទុយមកវិញអំពើនេះមិនមែនជាបទល្មើសព្រហ្មទណ្ឌក្នុងក្រមព្រហ្មទណ្ឌក្នុង ឆ្នាំ២០០៩ នាំឲ្យអំពើនេះមិនត្រូវចាត់ទុកថាជាបទល្មើសព្រោះក្រមព្រហ្មទណ្ឌឆ្នាំ១៩៦៧ត្រូវបាននិរាករណ៍។

ដូចនេះហើយការនិរាករណ៍ច្បាប់ព្រហ្មទណ្ឌ គឺ មានន័យថា ជាការលុបចោលនៃអង្គហេតុល្មើសដែលបានប្រព្រឹត្តមុន និង ក្រោយការចូលជាធរមាននៃច្បាប់ដែលត្រូវបាននិរាករណ៍នាំឲ្យមានអានុភាពរលត់បណ្តឹងអាជ្ញាដោយព្រះរាជអាជ្ញាអាចធ្វើការសម្រេចតម្កល់រឿងទុកឥតចាត់ការបាន។

### ១.៥. អាជ្ញាអស់ជំនុំ

ជនណាដែលត្រូវបានតុលាការសម្រេចឲ្យរួចខ្លួនជាស្ថាពរហើយ ជននោះមិនអាចធ្វើការចោទប្រកាន់បានទៀតទេចំពោះអំពើដដែលទោះជាបានកំណត់ក្រោមឈ្មោះបទល្មើសថ្មីផ្សេងទៀតក៏ដោយ ព្រោះនេះជាគោលការណ៍អាជ្ញាអស់ជំនុំ ។[95] ម្យ៉ាងទៀតគេអាចហៅបានថា ជាគោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ ( ne bis indem)។ តាមគោលការណ៍នេះគ្មានជនណាម្នាក់អាចត្រូវបាន កាត់ទោសលើបទល្មើសដែលខ្លួនសម្រេចឲ្យជាប់ពិរុទ្ធភាព ឬ ត្រូវបានឲ្យរួចផុតពីការចោទប្រកាន់ហើយនោះទេ ។[96] អាជ្ញាអស់ជំនុំកើតមានតែចំពោះសាលក្រម ឬ សាលដីកាស្ថាពរដែលតុលាការជំនុំជម្រះសព្វគ្រប់ហើយនាំឲ្យអង្គហេតុនោះមិនត្រូវបានលើកយកមកជំនុំជម្រះសារជាថ្មីទៀតឡើយ ។ លើកលែងតែមានប្បញ្ញត្តិនៃច្បាប់ចែង ជាក់ស្តែងដូចជាបណ្តឹងសើរើជាដើម ។ [97] បណ្តឹងសើរើគឺជា បណ្តឹងដែលជាផ្លូវតវ៉ាមួយប្រឆាំងនឹងសាលក្រមនិងសាលដីកាជាស្ថាពរហើយមានអាជ្ញាអស់ជំនុំ [98]។

---

[94] របស់លោក ឆេត សុត ( សៀវភៅសិក្សាច្បាប់គ្រប់មាត្រាទាំងអស់ក្នុងក្រមព្រហ្មទណ្ឌ, ក្រសួងយុត្តិធម៌ ) មាត្រា៣៦៩-៩១ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៦៧

[95] មាត្រា១២នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[96] មាត្រា១២នៃសេចក្តីពន្យល់នៃនីតិវិធីក្រមព្រហ្មទណ្ឌកម្ពុជាចំពោះសេចក្តីពន្យល់ករណីយុត្តិសាស្ត្រអ.វ.ត.ក និងអន្តរជាតិសម្រាំង

[97] រៀបរៀងដោយ លោក ហាក់ សៀកលីម , ការរលត់បណ្តឹងអាជ្ញា(ដំណាក់កាលស៊ើបអង្កេតព្រះរាជអាជ្ញា), ការផ្សាយរបស់សាលាត្រាជូ, ខែមិថុនាឆ្នាំ២០១៩

[98] មាត្រា៤៤៣នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

ឧទាហរណ៍បុគ្គល ក ត្រូវ បានចោទប្រកាន់ពីបទឃាតកម្មតាមមាត្រា ១៩៩ នៃក្រមព្រហ្មទណ្ឌដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ឆ្នាំ ទៅ ១៥ឆ្នាំ ។ ដោយអំពើនេះតុលាការបានចេញសាលក្រមលើកលែងការចោទប្រកាន់រួចហើយនាំឲ្យអំពើនេះមានអាជ្ញាអស់ជំនុំដែលជាមូលហេតុរលត់បណ្តឹងអាជ្ញា។

### ១.៥.១ ប្រភេទនៃអាជ្ញាអស់ជំនុំ

អាជ្ញាអស់ជំនុំមានពីរបែបគឺអាជ្ញាអស់ជំនុំដាច់ខាតនិងអាជ្ញាអស់ជំនុំមិនដាច់ខាត។[99]

នៅអាជ្ញាអស់ជំនុំ ត្រង់មាត្រា ១២ ជាអាជ្ញាអស់ជំនុំដាច់ខាតមានន័យថា ប្រសិនបើមានសាលក្រមណាមួយសម្រេចឲ្យរួចខ្លួនជាស្ថាពររួចហើយ ទោះបី ការសម្រេចនោះខុសក៏ដោយបានន័យថារឿងនោះទទួលបានអាជ្ញាអស់ជំនុំដាច់ខាត ដោយយោងទៅលើសាលក្រមសាលក្រមស្ថាពរ ឬ សាលដីកាស្ថាពរ។ ទោះជាថ្ងៃក្រោយត្រូវបានគេយកអង្គហេតុនេះទៅចោទបទល្មើសផ្សេងទៀត ក៏ដោយក៏គេមិនអាចយករឿងនោះមកធ្វើការកាត់ក្តីម្តងទៀតបាននោះដែរ ។ ចំពោះអាជ្ញាអស់ជំនុំដាច់ខាតនេះមិនត្រូវបានកើតឡើង ចំពោះដីកាតម្កល់រឿងទុកឥតចាត់ការរបស់ព្រះរាជអាជ្ញានោះឡើយ ដរាបណាបណ្តឹងអាជ្ញាមិនទាន់ផុតនៅឡើយ បើសិនគេរកឃើញនៅភស្តុតាងដាក់បន្ទុកថ្មីនោះគេនឹងបើកការចោទប្រកាន់ និង ស៊ើបសួរសារជាថ្មីបានទៀត។

ដូចនេះអាជ្ញាអស់ជំនុំមានពីរគឺអាជ្ញាអស់ជំនុំដាច់ខាតនិងអាជ្ញាអស់ជំនុំមិនដាច់ខាត។

## ផ្នែកទី២៖ មូលហេតុផ្សេងទៀតនៃការរលត់បណ្តឹងអាជ្ញា

ក្រៅពីមូលហេតុដែលមានចែងនៅក្នុងមាត្រា ៧ ដែលធ្វើឲ្យរលត់បណ្តឹងអាជ្ញាខាងលើនេះ ។ ដោយឡែកក្នុងមាត្រា ៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌក៏មានចែងពីមូលហេតុផ្សេងទៀតដែលនាំឲ្យរលត់បណ្តឹងអាជ្ញាដែលរួមមានដូចជា ការសម្របសម្រួលជាមួយរដ្ឋ ការដកពាក្យបណ្តឹងនៅក្នុងករណីដែលពាក្យបណ្តឹងនេះជាលក្ខខណ្ឌចាំបាច់នៃការចោទប្រកាន់ជាបទល្មើសព្រហ្មទណ្ឌ ដោយការបង់ប្រាក់ពិន័យសរុប ឬ ប្រាក់ពិន័យសម្របសម្រួល ។ ដោយមូលហេតុនាំឲ្យរលត់បណ្តឹងអាជ្ញាទាំងនេះបានចែងនៅក្នុងច្បាប់ដោយឡែក។

### ២.១ ការសម្របសម្រួលជាមួយរដ្ឋ

ជាគោលការណ៍បទល្មើសព្រហ្មទណ្ឌមិនអាចធ្វើការសម្រុះសម្រួលបានឡើយ។ ប៉ុន្តែច្បាប់ពិសេស អាចអនុញ្ញាតឲ្យរលត់បណ្តឹងអាជ្ញាផងដែរ។ ខាងក្រោមនេះជាឧទាហរណ៍:

[99] ឯកឧត្តម កើត រិទ្ធ មេរៀនសង្ខេបស្តីពីនីតិវិធីព្រហ្មទណ្ឌ សម្រាប់បង្រៀននិស្សិតថ្នាក់ពិសេសនីតិសាស្ត្រភាសាបារាំងនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច អមដោយសាកលវិទ្យាល័យ លុយមីញ៉ៅលីយ៉ុង២(ប្រទេសបារាំង)

- ការពិន័យអន្តរកាល។
- បទល្មើសអំពើហិង្សាដែលមានចែងក្នុង មាត្រា២៦នៃច្បាប់ស្តីពី ការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និង កិច្ចការពារជនរងគ្រោះ ។[100]

នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌចែងអំពី លទ្ធភាពក្នុងការដាក់ពិន័យសម្របសម្រួលដោយមិនបានកំណត់អំពីការដាក់ពិន័យនេះដាក់លាក់ណាមួយឡើយ ប៉ុន្តែវិធានបែបនេះត្រូវបានអាស្រ័យលើការទទួលស្គាល់ជាមុនដោយជនសង្ស័យអំពីការចូលរួមប្រព្រឹត្តរបស់ខ្លួន ហើយការព្រមព្រៀងនេះធ្វើឲ្យរលត់បណ្តឹងអាជ្ញា ។ ការសម្របសម្រួលនោះរួមមាន[101]:

- ជនល្មើសបានទទួលស្គាល់នូវកំហុស
- ជនល្មើសសន្យាឈប់ប្រព្រឹត្តអំពើបែបនេះទៅទៀត
- ជនល្មើសបានធានាចូលរួមរស់នៅក្នុងសង្គមវិញ
- ជនល្មើសសុំពេលដើម្បីធ្វើការជួសជុលព្យសនកម្មដល់ជនរងគ្រោះ
- ការទទួលបានព្រមានរបស់ព្រះរាជអាជ្ញា
- ការសម្រុះសម្រួលព្រហ្មទណ្ឌដទៃទៀតករណីមានចែងក្នុងច្បាប់។

ការសម្របសម្រួលនាំឲ្យរលត់បណ្តឹងអាជ្ញានាំឲ្យបណ្តឹងរដ្ឋប្បវេណីក៏ត្រូវសម្របសម្រួលផងដែរ ។ ទោះបីយ៉ាងណាក៏ការរលត់បណ្តឹងអាជ្ញាតាមរូបភាពសម្របសម្រួល មិនមែនជាបញ្ហាចោទនោះទេ ចំពោះបណ្តឹងរដ្ឋប្បវេណីដោយហេតុជនរងគ្រោះគាត់អាចដាក់ពាក្យបណ្តឹងរដ្ឋប្បវេណី នៅ ចំពោះមុខតុលាការរដ្ឋប្បវេណីបានដដែល ។[102]

ដូចនេះហើយការសម្របសម្រួលជាមួយរដ្ឋ គឺជា មូលហេតុមួយដែលនាំឲ្យរលត់បណ្តឹងអាជ្ញាដែលមានចែងជាលក្ខខណ្ឌក្នុងច្បាប់ពិសេស ។ ប៉ុន្តែការសម្របសម្រួលនោះមិនមែនជាមូលហេតុដែលនាំឲ្យរលត់នៃបណ្តឹងរដ្ឋប្បវេណីនោះទេ។

---

[100] មាត្រា២៦នៃច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារនិងកិច្ចការពារជនរងគ្រោះឆ្នាំ២០០៥

[101] រៀបរៀងដោយ លោក ហាក់ សៀកលីម , ការរំលត់បណ្តឹងអាជ្ញា ( ដំណាក់កាលស៊ើបអង្កេតព្រះរាជអាជ្ញា ), ការផ្សាយរបស់សាលាត្រាជូ, ខែមិថុនាឆ្នាំ២០១៩ ទំព័រទី៨

[102] លោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធនិងលោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត, នីតិវិធីព្រហ្មទណ្ឌ , សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ចឆ្នាំសិក្សា២០១៣ដល់២០១៤

## ២.២ ការដកពាក្យបណ្តឹងដែលជាលក្ខខណ្ឌចាំបាច់ក្នុងការចោទប្រកាន់ជាបទព្រហ្មទណ្ឌ

នៅក្នុងមាត្រា ៨ បានចែងពីការដកពាក្យបណ្តឹងដែលជាលក្ខខណ្ឌចោទប្រកាន់ជា បទល្មើសព្រហ្មទណ្ឌ ដែលជាការដកពាក្យបណ្តឹងពីអ្នករងគ្រោះដែលទទួលរងនូវការខូតខាតពីបទល្មើសនោះ ។ ហើយបទល្មើសខាងក្រោមនេះជាឧទាហរណ៍:

- នៅក្នុងមាត្រា៣៦នៃច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និង កិច្ចការពារជនរងគ្រោះ បានចែងពីបទមជ្ឈិមស្រាលឬបទលហុមិនអាចធ្វើបានប្រសិនបើមានសំណើពីជនរងគ្រោះដែលជានីតិជន។[103]
- នៅក្នុងច្បាប់ស្តីពីឯកពន្ធភាព ឆ្នាំ២០០៦ ត្រង់មាត្រា ៨ បានចែងពី ព្រះរាជអាជ្ញាអាចសម្រេចមិនធ្វើបណ្តឹងអាជ្ញាបានប្រសិនបើ មានការស្នើសុំពីម្ចាស់បណ្តឹង ដែលជា សហព័ទ្ធម្ខាងទៀតកុំឲ្យធ្វើការចោទប្រកាន់ចំពោះការផិតដូចមានចែងក្នុងមាត្រា៧នៃច្បាប់នេះ។[104]
- នៅក្នុងមាត្រា ៣០៩ នៃក្រមព្រហ្មទណ្ឌបានចែងពី ពាក្យប្តឹងរបស់សាមីខ្លួន ឬ ប្រធានស្ថាប័នសាមីគឺជាលក្ខខណ្ឌចាំបាច់ក្នុង ការចោទប្រកាន់បទល្មើសព្រហ្មទណ្ឌ ចំពោះបទបរិហារ៍ និង បទជេរប្រមាថជាសាធារណៈ ដោយអយ្យការ ហើយ ការដកពាក្យប្តឹងវិញរបស់អ្នកប្តឹងនាំឲ្យបណ្តឹងអាជ្ញារលត់។[105]

ដូចនេះហើយបណ្តឹងអាជ្ញាត្រូវរលត់ដោយអ្នកទទួលរងការខូតខាតបាន ដកពាក្យបណ្តឹងចំពោះបទល្មើសមួយចំនួនដែលមានចែងក្នុងច្បាប់។

## ២.៣. ការបង់ប្រាក់ពិន័យសរុបឬប្រាក់ពិន័យសម្របសម្រួល

ការបង់ប្រាក់ពិន័យសរុប ឬ ប្រាក់ពិន័យសម្របសម្រួលក៏ជាលក្ខខណ្ឌមួយដែលនាំឲ្យរលត់បណ្តឹងអាជ្ញាផងដែរ។ ខាងក្រោមនេះជាឧទាហរណ៍:

- នៅក្នុងមាត្រា ៨៧ នៃ ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកឆ្នាំ ២០១៤ ចែងពីការបង់ប្រាក់ពិន័យសរុបចំពោះបទល្មើសចរាចរណ៍ដែលមានការបង់ប្រាក់ពិន័យអន្តរការណ៍នាំឲ្យរលត់បណ្តឹងអាជ្ញា។[106]

[103] មាត្រា៣៦នៃច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារនិងកិច្ចការពារជនរងគ្រោះឆ្នាំ២០០៥

[104] មាត្រា៨នៃច្បាប់ស្តីពីឯកពន្ធភាពឆ្នាំ២០០៦

[105] មាត្រា៣០៩នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

[106] មាត្រា៨៧នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកឆ្នាំ២០១៤

- នៅក្នុង មាត្រា ៧៧ នៃច្បាប់ពីស្តីគយ ឆ្នាំ២០០៧ បានចែងពីរដ្ឋបាលមានសិទ្ធិសម្រុះសម្រួលចំពោះបទល្មើសគយហើយ ការសម្របសម្រួលនេះប្រើប្រាស់ចំពោះការពិន័យជាប្រាក់ប៉ុណ្ណោះ ។ ម្យ៉ាងទៀតការសម្របសម្រួលអាចធ្វើទៅបាននៅមុនតុលាការមានសមត្ថកិច្ច។[107]

ដូចនេះហើយបទល្មើសមួយចំនួនត្រូវបានរលត់បណ្តឹងអាជ្ញាដោយសារតែការបង់ប្រាក់ពិន័យ ឬ ប្រាក់ពិន័យសម្របសម្រួលដោយដូចមានចែងក្នុងច្បាប់ពិសេស។

[107] មាត្រា៧៧នៃច្បាប់ស្តីគយឆ្នាំ២០០៧

# ជំពូកទី៣:អានុភាពនិងនីតិវិធីនៃការរលត់បណ្តឹងអាជ្ញា

មូលហេតុនៃការរលត់បណ្តឹងអាជ្ញាមានអានុភាពដល់ការតម្កល់រឿងទុកឥតចាត់ការដែលជាជម្រើសនៃការចោទប្រកាន់របស់ព្រះរាជអាជ្ញាក្នុងដំណាក់កាលអយ្យការ ។[108] ព្រះរាជអាជ្ញាអាចសម្រេចចោទប្រកាន់ ឬ តម្កល់រឿងទុកឥតចាត់ការដែលជាគោលការណ៍ជម្រើសនៃការចោទប្រកាន់ ។ ការសម្រេចតម្កល់រឿងទុកឥតចាត់ការមានការសម្រេចតម្កល់រឿងទុកឥតចាត់ការចំពោះអំពើមិនមែនជាបទល្មើស និង ការសម្រេចតម្កល់រឿងទុកឥតចាត់ការអំពើជាបទល្មើស ។ ការសិក្សាស្វែងយល់ពីការតម្កល់រឿងទុកឥតចាត់ការជាផ្នែកមួយនៃការសិក្សាពីអានុភាព និង នីតិវិធីនៃការរលត់បណ្តឹងអាជ្ញា។

ការស្វែងយល់ពីការតម្កល់រឿងទុកឥតចាត់ការគ្រាន់តែសិក្សាទៅលើដំណាក់កាលអយ្យការតែប៉ុណ្ណោះ ។ ហេតុនេះហើយក៏ត្រូវស្វែងយល់បន្ថែមលើនីតិវិធីនៅក្នុងដំណាក់កាលការស៊ើបសួរ និង ដំណាក់កាលការជំនុំជម្រះក្នុងករណីដែលបណ្តឹងអាជ្ញាត្រូវបានរលត់ក្នុងដំណាក់កាលទាំងនោះ ។

## ផ្នែកទី១៖ការតម្កល់រឿងទុកឥតចាត់ការ

### ១.១ សញ្ញាណទូទៅនៃការតម្កល់រឿងទុកឥតចាត់ការ

#### ១.១.១ អត្ថន័យនៃការតម្កល់រឿងទុកឥតចាត់ការ

នៅក្នុងដំណើរការរឿងព្រហ្មទណ្ឌត្រូវបានធ្វើឡើងដោយមានបួនដំណាក់កាល ។ ដំណាក់កាលចោទប្រកាន់ គឺជា ដំណាក់កាលមួយដែលស្ថិតនៅក្នុង សមត្ថកិច្ចស្ថាប័នអយ្យការដែលអាចសម្រេចចោទប្រកាន់ និង បញ្ជូនសំណុំរឿងទៅយុត្តាធិការស៊ើបសួរ និង យុត្តាធិការជំនុំជម្រះដើម្បីធ្វើចំណាត់ការបន្ត ។ ការផ្តល់អំណាចសម្រេចតម្កល់រឿងទុកឥតចាត់ការចំពោះអំពើដែលជា បទល្មើសដល់ព្រះរាជអាជ្ញា គឺហៅថា គោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់ ។[109] តាមរយៈគោលការណ៍នេះបានផ្តល់នូវអំណាចឆន្ទានុសិទ្ធិដល់ព្រះរាជអាជ្ញាក្នុងការថ្លឹងថ្លែងគួរចោទប្រកាន់ ឬ មិនចោទប្រកាន់ចំពោះអំពើដែលជាបទល្មើសព្រហ្មទណ្ឌ ។ នៅក្នុងមាត្រា ៤០ កថាខណ្ឌទី ២ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧ បានចែងពី ព្រះរាជអាជ្ញាអាចសម្រេចតម្កល់រឿងទុកឥតចាត់ការ ឬ ធ្វើការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ ។ មុននឹងសម្រេចព្រះរាជអាជ្ញាបើកការស៊ើប

[108] មាត្រា៤១នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[109] រៀបរៀងដោយ ន. ស. រ មេរៀនការតម្កល់រឿងទុកឥតចាត់ការ ខែ មករា ឆ្នាំ ២០១៨

អង្កេតបឋម ឬ បង្គាប់ឲ្យធ្វើការស្រាវជ្រាវបន្ថែម ។[110] តាមហេតុផលនេះសរបញ្ជាក់ឲ្យឃើញថា ព្រះរាជអាជ្ញាត្រូវតែធ្វើការសម្រេចដោយផ្អែកលើភស្តុតាងជាមូលដ្ឋានដែលទទួលបានមកពីការស៊ើបអង្កេតបឋម ឬ ការស្រាវជ្រាវដែលខ្លួនទទួលបាន ។ ក្នុងការអនុវត្តមុខងាររបស់ខ្លួនព្រះរាជអាជ្ញាមិនលំអៀង ជៀសវាងរាល់ការរើសអើង ភេទ វប្បធម៌ សាសនា សង្គម នយោបាយ ឬ ការរើសអើងណាមួយព្រោះព្រះរាជអាជ្ញាបំពេញមុខងារដើម្បីការពារផលប្រយោជន៍សាធារណៈ ។ តាមន័យនេះព្រះរាជអាជ្ញាមិនត្រូវផ្តើមគំនិត ឬ បន្តការចោទប្រកាន់ ឬ ក៏ខិតខំប្រឹងប្រែងគ្រប់បែបយ៉ាង ដើម្បី តម្កល់រឿងទុកឥតចាត់ការ ប្រសិនបើការស៊ើបអង្កេតដោយឥតលំអៀងមួយបង្ហាញឲ្យឃើញថាការចោទប្រកាន់នេះពុំមានមូលដ្ឋានទេ។[111]

ដូចនេះហើយការតម្កល់រឿងទុកឥតចាត់ការ គឺជា អំណាចឆន្ទានុសិទ្ធិរបស់ព្រះរាជអាជ្ញាដែលត្រូវធ្វើឡើងដោយឆ្លងកាត់នូវការស៊ើបអង្កេតដោយឥតលំអៀងមុននឹងធ្វើការសម្រេចតម្កល់រឿងទុកឥតចាត់ការ។

### ១.១.២ អាជ្ញាធរក្នុងការតម្កល់រឿងទុកឥតចាត់ការ

អាជ្ញាធរដែលទទួលបន្ទុកការតម្កល់រឿងទុកឥតចាត់ការ គឺ សំដៅដល់អ្នកមានសមត្ថកិច្ចអាចធ្វើការតម្កល់រឿងទុកឥតចាត់ការ ។ អ្នកដែលមានសមត្ថកិច្ចក្នុងការតម្កល់រឿងទុកឥតចាត់ការរួមមាន:

- ព្រះរាជអាជ្ញា[112] : ព្រះរាជអាជ្ញា គឺជា មន្ត្រីដែលស្ថិតនៅក្នុងស្ថាប័នអយ្យការជាអ្នកស្វែងរកបទល្មើសព្រហ្មទណ្ឌ ធ្វើការចោទប្រកាន់ និង សុំឲ្យអនុវត្តច្បាប់នៅចំពោះមុខយុត្តាធិការស៊ើបសួរ និង យុត្តាធិការជំនុំជម្រះធ្វើឡើងក្នុងនាមផលប្រយោជន៍សាធារណៈ ។
- ព្រះរាជអាជ្ញារង: ព្រះរាជអាជ្ញារង គឺ ស្ថិតនៅក្រោមអំណាចរបស់ព្រះរាជអាជ្ញា ប្រើប្រាស់អំណាចទាំងអស់ដែលព្រះរាជអាជ្ញាមានក្នុងការស្រាវជ្រាវ និង ចោទប្រកាន់បទល្មើសព្រហ្មទណ្ឌ។[113] ព្រះរាជអាជ្ញាមានអំណាចលើព្រះរាជអាជ្ញារងទាំងអស់នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។ ព្រះរាជអាជ្ញាចាត់តាំង និង បែងចែកការងារដល់ព្រះរាជអាជ្ញារងទាំងអស់បានដោយសារតែអង្គការអយ្យការ គឺជា អង្គការអវិភាគ ។[114] អង្គការអយ្យការ គឺជា អង្គអវិភាគ គឺ មានន័យថា ព្រះរាជអាជ្ញាត្រូវបំពេញមុខងារនៅអង្គការអយ្យការអមសាលាជម្រះក្តីមានសមត្ថកិច្ចរួមក្នុងមុខងារដូចគ្នា អាច ជំនួសគ្នាទៅវិញទៅ

[110] មាត្រា៤០កថាខណ្ឌ២នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[111] លិខិតគុបករណ៍អង្គការសហប្រជាជាតិស្តីពីចៅក្រម ព្រះរាជអាជ្ញានិងមេធាវី ( តួនាទីព្រះរាជអាជ្ញាក្នុងចំណាត់ការរឿងក្តីព្រហ្មទណ្ឌ ទំព័រទី២៤), ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា

[112] មាត្រា៤០កថាខណ្ឌ២នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[113] មាត្រា៣៨កថាខណ្ឌ២នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[114] មាត្រា៣០នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការឆ្នាំ២០១៤

មកបាន។ តាមគោលការណ៍នេះធ្វើឲ្យតំណាងអយ្យការច្រើនរូប អាចបន្តការងារពីគ្នាបានក្នុងសំណុំរឿងតែមួយតាមការចាត់តាំងរបស់នាយឋានានុក្រម ។[115]

ហេតុនេះហើយមានតែព្រះរាជអាជ្ញា និង ព្រះរាជអាជ្ញារងតែប៉ុណ្ណោះ ដែលមានអំណាចឆន្ទានុសិទ្ធិក្នុងការសម្រេចតម្កល់រឿងទុកឥតចាត់ការ ។ ជាក់ស្តែងនៅក្នុងមាត្រា ៧៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ បានចែងពី ការបំពានលើសកម្មភាពតុលាការដែលសំដៅដល់មន្ត្រីនគរបាលយុត្តិធម៌មិនអាចតម្កល់រឿងព្រហ្មទណ្ឌទុកឥតចាត់ការបានទេ ទោះបីជា ជនល្មើស និង ជនរងគ្រោះបានសម្រុះសម្រួលគ្នា ឬ ជនរងគ្រោះបានដកពាក្យប្តឹងក៏ដោយ។[116]

ដូចនេះហើយព្រះរាជអាជ្ញា និង ព្រះរាជអាជ្ញារង គឺជា អាជ្ញាធរដែលមានសមត្ថកិច្ចក្នុងការទទួលបន្ទុកតម្កល់រឿងទុកឥតចាត់ការ ។

## **១.២ មូលហេតុនៃការតម្កល់រឿងទុកឥតចាត់ការ**

តំណាងអយ្យការអាចធ្វើការតម្កល់រឿងទុកឥតចាត់ការពីរករណី:

- តម្កល់រឿងទុកឥតចាត់ការចំពោះអំពើមិនមែនជាបទល្មើស
- តម្កល់រឿងទុកឥតចាត់ការចំពោះអំពើដែលជាបទល្មើស

### **១.២.១ តម្កល់រឿងទុកឥតចាត់ការចំពោះអំពើមិនមែនជាបទល្មើស**

ប្រសិនបើព្រះរាជអាជ្ញាយល់ឃើញថា អំពើដែលគេប្តឹងមកមិនមែនជា បទល្មើសព្រហ្មទណ្ឌ ឬ គ្មានភស្តុតាងណាមួយឲ្យជឿថាពិតជាមានបទល្មើសកើតមែននោះគឺមានន័យ ថា អំពើនោះមិនមែនជាបទឧក្រិដ្ឋ ឬ បទមជ្ឈិម ឬ បទលហុ ដែលច្បាប់បានកំណត់ផ្តន្ទាទោស ឬ មិនមានពិរុទ្ធភាពគ្រប់គ្រាន់សម្រាប់ធ្វើការចោទប្រកាន់ ឬ គ្មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនត្រូវចោទ ។ ដូច្នោះ ព្រះរាជអាជ្ញានឹងចេញដីកាតម្កល់រឿងទុកឥតចាត់ការដោយមានសំអាងច្បាប់ និង សំអាងហេតុ។

តម្កល់រឿងទុកឥតចាត់ការចំពោះអំពើមិនមែនជាបទល្មើសមានពីរករណីគឺ:

- កង្វះធាតុផ្សំនៃបទល្មើស
- អវត្តមាននៃបទល្មើស

[115] មាត្រា៧៥កថាខណ្ឌ១ចំណុច២នៃច្បាប់ស្តីពីលក្ខន្តិកៈចៅក្រមនិងព្រះរាជអាជ្ញាឆ្នាំ២០១៤

[116] មាត្រា៧៥កថាខណ្ឌ១នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

### ១.២.១.១ ភាគធាតុផ្សំនៃបទល្មើស

អំពើដែលបង្កឡើងពីរូបវន្តបុគ្គល ឬ នីតិបុគ្គលដែលបង្កចលាចលដល់សង្គមជាបទល្មើស ។ លក្ខណៈនៃការវិនិច្ឆ័យអំពើបទល្មើសត្រូវពិចារណា ដូចជា ចរិតគ្រោះថ្នាក់ដល់សង្គម ចរិតមានកំហុសនៃអំពើ ចរិតផ្ទុយនឹងច្បាប់ព្រហ្មទណ្ឌ ចរិតទទួលទោសព្រហ្មទណ្ឌ ។[117] ចំណែកកត្តារួមផ្សំនៃបទល្មើសរួមមាន :

- ធាតុផ្សំនីត្យានុកូលៈ នៅក្នុងមាត្រា ៣ នៃក្រមព្រហ្មទណ្ឌដែលបានចែងពី គោលការណ៍នីត្យានុកូលភាពដែលបានចែងថា អំពើដែលបង្កើតបានជាបទល្មើសនៅពេលដែលអំពើនោះមានចែងក្នុងបញ្ញត្តិព្រហ្មទណ្ឌជាធរមានប៉ុណ្ណោះ។
- ធាតុផ្សំសត្យានុម័តៈ គឺជាផ្នែកខាងក្រៅនៃបទល្មើស រួមមាន បណ្តាសញ្ញាដែលជា និម្មិតរូបនៃបទល្មើស ហើយត្រូវបានស្តែងតាមរយៈលោកសម្ភារៈ ។ បណ្តាកត្តាដែលស្តែងចេញមកខាងក្រៅនៃបទល្មើសរួមមាន [118]:
  - ❖ អំពើបង្កគ្រោះថ្នាក់ដល់សង្គម ឬ អំពើសត្យានុម័ត
  - ❖ បច្ច័យគ្រោះថ្នាក់ដល់សង្គម ( ការអន្តរាយ )
  - ❖ ទំនាក់ទំនងហេតុផលរវាងអំពើនិងបច្ច័យ
  - ❖ បណ្តាសញ្ញាផ្សេង ៗ ដែលស្តែងចេញពី ការប្រព្រឹត្តអំពើ និង ផ្សារភ្ជាប់ជាមួយអំពើនោះដែលមានដូចជា ឧបករណ៍មធ្យោបាយ វិធីសាស្ត្រ ឧបាយកល ពេលវេលា ទីកន្លែង និង ទិដ្ឋភាពនៃបទល្មើស ។
- ធាតុផ្សំអត្តនោម័តៈ មិនមានចេតនាប្រព្រឹត្តពុំមានបទល្មើសទេ ប៉ុន្តែលើកលែងក្នុងករណីដែលច្បាប់បានចែងទុកជាមុនថា ជាបទល្មើសមួយប្រសិនបើអំពើនោះកើតចេញពីការមិនប្រុងប្រយ័ត្ន ការខ្ជីខ្ជា ការធ្វេសប្រហែស ឬ ការមិនគោរពកាតព្វកិច្ចដោយឡែកណាមួយ ។[119]ធាតុផ្សំនៃអត្តនោម័តគឺជា ផ្នែកខាងក្នុងនៃបទល្មើសដែលជា កិរិយាផ្លូវចិត្តរបស់ជនល្មើសចំពោះអំពើ បង្កគ្រោះថ្នាក់ដល់សង្គមដែលបានប្រព្រឹត្ត និង បច្ច័យដែលកើតឡើងពីអំពើនោះ។[120] ផ្នែកអត្តនោម័តនៃបទល្មើសរួមមានៈ

[117] លោកមេធាវី មួន សៀងលី, វិទ្យាសាស្ត្រគតិយុត្តក្នុងការកំណត់បទល្មើស, រាជធានីភ្នំពេញ, ចុះថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ២០១៥

[118] សៀវភៅនីតិព្រហ្មទណ្ឌ ឯកឧត្តម ហ៊ី សោភា ទំព័រទី៥៧

[119] មាត្រា៣នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

[120] លោកមេធាវី មួន សៀងលី, វិទ្យាសាស្ត្រគតិយុត្តក្នុងការកំណត់បទល្មើស, រាជធានីភ្នំពេញ, ចុះថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ២០១៥

- ❖ កំហុស: កំហុសរួមមានកំហុសដោយចេតនា និង កំហុសដោយអចេតនា ។ កំហុសដោយអចេតនា រួមមាន ចេតនាដោយចំពោះនិងចេតនាដោយមិនចំពោះ ។ ហើយក្នុងទ្រឹស្តីព្រហ្មទណ្ឌខ្លះទៀតបានបែងចែកកំហុសដោយចេតនា ជា ចេតនាទុច្ចរិតទូទៅ ចេតនាទុច្ចរិតមិនច្បាស់លាស់ និង ចេតនាទុច្ចរិតពិសេស ។ ចំណែកកំហុសដោយអចេតនា រួមមានអចេតនាដោយជឿជាក់ និង អចេតនាដោយធ្វេសប្រហែស។
- ❖ គំនិតផ្តួចផ្តើមប្រព្រឹត្តបទល្មើស: គឺជា មូលហេតុនៃកត្តាផ្លូវចិត្តដែលជំរុញឲ្យមនុស្សប្រព្រឹត្តបទល្មើស។
- ❖ គោលដៅនៃការប្រព្រឹត្តបទល្មើស : កើតមានឡើងតែចំពោះបទល្មើសដែលប្រព្រឹត្តឡើងដោយចេតនាចំពោះប៉ុណ្ណោះ ។ ក្នុងករណីនេះជនល្មើសបានយល់ដឹងពីចរិតគ្រោះថ្នាក់ដល់សង្គមនៃអំពើដែលបានប្រព្រឹត្ត មើលឃើញជាមុននូវបច្ច័យគ្រោះថ្នាក់ ដល់សង្គមហើយប៉ងឲ្យកើតមានឡើងជាក់ស្តែងតាមរយៈការប្រព្រឹត្តបទល្មើស ដើម្បី សម្រេចគោលដៅណាមួយជាកំណត់ ។

ព្រះរាជអាជ្ញា មិនអាចធ្វើការចោទប្រកាន់ជាបទល្មើសបានឡើយ ប្រសិនបើ ខ្វះធាតុផ្សំណាមួយដែលនាំឲ្យព្រះរាជអាជ្ញាសម្រេចតម្កល់រឿងទុកឥតចាត់ការ ។ ឧទាហរណ៍ នារី ក បានធ្វើឲ្យខូចនូវទូរស័ព្ទរបស់នារី ខ ដោយអចេតនាហើយព្រោះតែខ្វះធាតុផ្សំអត្តនោម័តនាំឲ្យនារី ខ មិនត្រូវបានចោទប្រកាន់ពីបទធ្វើឲ្យខូចខាតដោយចេតនាក្នុងមាត្រា ៤១០ នៃក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ ។ ហេតុនេះហើយនាំឲ្យនារី ខ មិនទទួលខុសត្រូវបទល្មើសព្រហ្មទណ្ឌក្នុងមាត្រា ៤១០ ប៉ុន្តែនារីខនៅតែត្រូវទទួលខុសត្រូវផ្នែករដ្ឋប្បវេណីដដែល។

ដូច្នេះហើយប្រសិនបើកង្វះធាតុផ្សំណាមួយ តំណាងអយ្យការនឹងសម្រេចតម្កល់រឿងទុកឥតចាត់ការ ។

### ១.២.១.២ អវត្តមាននៃបទល្មើស

រាល់អំពើដែលបង្កព្យសនកម្មទាំងអស់មិនមែនសុទ្ធតែជាបទល្មើសព្រហ្មទណ្ឌនោះទេ ។ រាល់បទល្មើសសុទ្ធតែជាអំពើល្មើសប៉ុន្តែរាល់អំពើល្មើសមិនសុទ្ធតែជាបទល្មើសនោះទេ ។ អវត្តមានបទល្មើសសំដៅដល់សំណុំរឿងទាំងឡាយដែលពុំមែនជាបទល្មើសព្រហ្មទណ្ឌហើយមិនមែនជារឿងក្តីព្រហ្មទណ្ឌ ដែលរឿងក្តីនោះអាចជារឿងក្តីរដ្ឋប្បវេណី ឬ រឿងក្តីពាណិជ្ជកម្ម ។ ខាងក្រោមនេះជាឧទាហរណ៍ដែលសំណុំរឿងមិនមែនជារឿងក្តីព្រហ្មទណ្ឌ:

- បណ្តឹងទាមទារឲ្យអ្នកលក់ផ្ទេរកម្មសិទ្ធិផ្ទះដោយផ្អែកលើកិច្ចសន្យាលក់ទិញជាដើម។
- វិវាទពាណិជ្ជកម្មបណ្តាលមកពីការប្រកួតប្រជែងមិនស្មោះត្រង់ក្នុងការធ្វើពាណិជ្ជកម្ម ដែលមានចែងក្នុងច្បាប់ស្តីពីការប្រកួតប្រជែងមិនស្មោះត្រង់ និង ការកំណត់ថ្លៃ។

- កិច្ចសន្យាខ្ចីបរិភោគដែលជា កិច្ចសន្យាមួយដែលអ្នកឲ្យខ្ចីនូវប្រាក់ ស្បៀងអាហារ ឬ វត្ថុជំនួសផ្សេងទៀត ឲ្យអ្នកខ្ចីយកទៅប្រើប្រាស់ដោយសេរី ។ កិច្ចសន្យាខ្ចីបរិភោគនេះ គឺជា រឿងក្តីរដ្ឋប្បវេណី ប៉ុន្តែ ប្រសិនបើពិចារណាមិនបានច្បាស់លាស់នោះទេ នឹងនាំឲ្យមានការភ័ន្តច្រឡំថាជាបទល្មើសព្រហ្មទណ្ឌ គឺ បទរំលោភលើទំនុកចិត្តដែលមានចែងក្នុងមាត្រា ៣៩១ នៃក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ នៅពេលដែល ភាគីអ្នកខ្ចីមិនធ្វើការសងប្រាក់ត្រឡប់មកឲ្យភាគីអ្នកឲ្យខ្ចីវិញ ។

ដូចនេះប្រសិនបើ រឿងក្តីមិនមែនជារឿងក្តីព្រហ្មទណ្ឌតំណាងអយ្យការ នឹង សម្រេចតម្កល់រឿងទុកឥត ចាត់ការ។

### ១.២.២ ការតម្កល់រឿងទុកឥតចាត់ការចំពោះអំពើជាបទល្មើស

មានអំពើមួយចំនួនមានចរិតលក្ខណៈ គឺជា បទល្មើសព្រហ្មទណ្ឌក៏ដោយ ប៉ុន្តែកាលៈទេសៈនៃការប្រព្រឹត្ត បទល្មើស ហេតុ និង បច្ច័យនៃការប្រព្រឹត្តបទល្មើសខ្លះមិនបានបង្កនូវព្យសនកម្មធ្ងន់ធ្ងរ ឬ រឹករវដល់សង្គមនោះ ទេ។ ដូច្នេះហើយ ប្រសិនបើធ្វើការចោទប្រកាន់មិនផ្តល់ផលប្រយោជន៍អ្វីដល់សង្គមហើយហាក់ដូចជាបន្ថែម បន្ទុកដល់សង្គមវិញ ។ ម្យ៉ាងទៀតអំពើខ្លះប្រសិនបើ ធ្វើការចោទប្រកាន់មានផលប៉ះពាល់ដល់សង្គមដូចជា [121]:

- កុមារក្លាយក្មេងជាកំព្រា
- ពុំមានអ្នកទំនុកបម្រុងក្នុងគ្រួសារ
- បង្កើនការកកស្ទះសំណុំរឿងនៅតុលាការ
- ចំណាយប្រាក់លើពន្ធនាគារច្រើនពេកនាំឲ្យប៉ះពាល់ដល់សេដ្ឋកិច្ចជាតិ។

មានកត្តាសំខាន់ ៗ មួយចំនួនដែលប្រទេសកម្ពុជាសម្រេចជ្រើសរើសយកប្រព័ន្ធកាលានុភាពមកអនុវត្ត ក្នុងវិស័យព្រហ្មទណ្ឌមានដូចជា[122]:

- កាត់បន្ថយការកកស្ទះសំណុំរឿង
- កម្រិតការយល់ដឹងរបស់ប្រជាពលរដ្ឋ
- ធានានូវសន្តិសុខនិងសុវត្ថិភាពនៃសង្គម
- ដើម្បីឲ្យព្រះរាជអាជ្ញាក្លាយជានិយ័តករនៃសង្គម

ដូចនេះហើយការតម្កល់រឿងទុកឥតចាត់ការគឺសមហេតុផលបំផុត។

---

[121] រៀបរៀងដោយ ន. ស. រ មេរៀនការតម្កល់រឿងទុកឥតចាត់ការ ខែ មករា ឆ្នាំ ២០១៨

[122] ឯកឧត្តម កើត រិទ្ធ, មេរៀនសង្ខេបស្តីពីនីតិវិធីព្រហ្មទណ្ឌ សម្រាប់បង្រៀននិស្សិតថ្នាក់ពិសេសនីតិសាស្ត្រភាសាបារាំងនៃសាកល វិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច អមដោយសាកលវិទ្យាល័យ លុយមីញ៉េលីយ៉ុង២ (ប្រទេសបារាំង)

ការតម្កល់រឿងទុកឥតចាត់ការចំពោះអំពើជាបទល្មើសអាចមានមូលហេតុពីរគឺ:

- មូលហេតុគតិយុត្ត
- ការចោទប្រកាន់មិនផ្តល់ផលប្រយោជន៍

### ១.២.២.១ មូលហេតុគតិយុត្ត

តាមគោលការណ៍កាលានុវត្តភាពព្រះរាជអាជ្ញាមានឆន្ទានុសិទ្ធិក្នុងការសម្រេចថា គួរចោទប្រកាន់ ឬ មិនចោទប្រកាន់ចំពោះអំពើល្មើសព្រហ្មទណ្ឌ។

មូលហេតុគតិយុត្ត គឺជា សំដៅដល់មូលហេតុដែលច្បាប់ទាំងឡាយបានបញ្ញត្តិរារាំងតំណាងអយ្យការមិនអាចធ្វើការចោទប្រកាន់បានចំពោះអំពើល្មើសនោះ។

#### ក. អភ័យឯកសិទ្ធិ

អភ័យឯកសិទ្ធិគឺជាសិទ្ធិឲ្យចាកផុតពីករណីយកិច្ច ឬ ពីការដាក់ទោស ។ ការចាកផុតពីករណីយកិច្ចដែលច្បាប់តម្រូវជាទូទៅ ។ អភ័យឯកសិទ្ធិត្រូវបែងចែកជាពីរគឺអភ័យឯកសិទ្ធិជាតិ និង អភ័យឯកសិទ្ធិអន្តរជាតិ។[123]

#### ក.១ អភ័យឯកសិទ្ធិជាតិ

អភ័យឯកសិទ្ធិជាតិ គឺជា ការរារាំងមិនឲ្យចៅក្រមជាតិមានសមត្ថកិច្ចជំនុំជម្រះ ឬ ចេញវិធានការណ៍បង្ខិតបង្ខំផ្សេងៗចំពោះរឿងក្តីណាមួយ។ អភ័យឯកសិទ្ធិជាតិកើតចេញពីបញ្ញត្តិនៃច្បាប់ជាតិ។ ច្បាប់ជាតិបានចែងពីអភ័យឯកសិទ្ធិដូចជា:

- អភ័យឯកសិទ្ធិរបស់អង្គព្រះមហាក្សត្រ: ព្រះមហាក្សត្រមិនអាចនរណារំលោភបំពានបានឡើយ។[124] ហេតុនេះហើយ ព្រះអង្គទ្រង់មានអភ័យឯកសិទ្ធិទាំងស្រុង ។
- អភ័យឯកសិទ្ធិសភា: តំណាងរាស្ត្រមានអភ័យឯកសិទ្ធិសភា ។[125] តំណាងរាស្ត្ររូបណាក៏ដោយ មិនត្រូវបានចោទប្រកាន់ ចាប់ខ្លួន ឃាត់ខ្លួន ឬ ឃុំខ្លួនដោយហេតុតែការបញ្ចេញមតិ ឬ សំដែងយោបល់ក្នុងការបំពេញមុខងារឡើយ។ ចំពោះករណីបទល្មើសព្រហ្មទណ្ឌជាក់ស្តែងក្រសួងមានសមត្ថកិច្ចត្រូវធ្វើសេចក្តីរាយការណ៍ជូនរដ្ឋសភា ឬ ជូនគណ:កម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភាជាបន្ទាន់ដើម្បីសម្រេច ។ ក្នុងករណីការឃុំខ្លួនការចោទប្រកាន់តំណាងរាស្ត្រណាមួយត្រូវបានផ្អាក ប្រសិនបើ

[123] របាយការណ៍តុលាការព្រហ្មទណ្ឌអន្តជាតិ , ការសម្របនីតិកម្មកម្ពុជាទៅនឹងលក្ខន្តិក:នៃតុលាការព្រហ្មទណ្ឌអន្តរជាតិ, International federation for human rights, ខែមីនាឆ្នាំ២០០៦លេខ៤៤៣

[124] មាត្រា៧កថាខណ្ឌ៣នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣

[125] មាត្រា៨០កថាខណ្ឌ១នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣

រដ្ឋសភាបានបញ្ចេញមតិឲ្យផ្អាកតាមមតិភាគច្រើនបីភាគបួននៃចំនួនសមាជិកសភាទាំងមូល ។ ចំណែកសមាជិកព្រឹទ្ធសភាមានអភ័យឯកសិទ្ធិសភា ។[126]

ដូចនេះហើយអភ័យឯកសិទ្ធិជាតិ គឺជា អភ័យឯកសិទ្ធិដែលមានចែងក្នុងច្បាប់ជាតិ ។ ហើយអភ័យឯកសិទ្ធិជាតិមាន អភ័យឯកសិទ្ធិអង្គព្រះមហាក្សត្រ អភ័យឯកសិទ្ធិសភា និង អភ័យឯកសិទ្ធិព្រឹទ្ធសភា ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ ។ ចំណែកសមាជិកនៃរាជរដ្ឋាភិបាលគឺ អវត្តមានអភ័យឯកសិទ្ធិនាំឲ្យត្រូវទទួលទណ្ឌកម្មពីបទឧក្រិដ្ឋ ឬ បទមជ្ឈិមដែលខ្លួនបានប្រព្រឹត្តក្នុងការបំពេញមុខងាររបស់ខ្លួន។

**ក.១ អភ័យឯកសិទ្ធិអន្តរជាតិ**

អភ័យឯកសិទ្ធិអន្តរជាតិ គឺ មានប្រភពចេញពីនីតិអន្តរជាតិ ។ ហេតុនេះត្រូវតម្រូវឲ្យប្រព័ន្ធគតិយុត្តជាតិទាំងមូលត្រូវគោរពតាម ។ អភ័យឯកសិទ្ធិអន្តរជាតិ គឺ ទាក់ទងនឹងអ្នកដឹកនាំនិងអ្នកការទូតបរទេសដែលត្រូវបានប្តឹងនៅប្រទេសកម្ពុជា ។ ឧទាហរណ៍មន្ត្រីកុងស៊ុលមិនត្រូវចាប់ខ្លួន ឬ ឃុំខ្លួនបណ្តោះអាសន្នរង់ចាំការកាត់ទោសបានឡើយ លើកលែងតែមានបទឧក្រិដ្ឋធ្ងន់ធ្ងរ និង បន្ទាប់ពីមានសេចក្តីសម្រេចណាមួយពីអាជ្ញាធរមានសមត្ថកិច្ចតុលាការ។[127]

ដូចនេះហើយ អភ័យឯកសិទ្ធិអន្តរជាតិមានចែងក្នុងច្បាប់អន្តរជាតិហើយតម្រូវឲ្យប្រព័ន្ធគតិយុត្តជាតិត្រូវគោរពតាម។

**ខ. អនិយ័តភាពនៃនីតិវិធី**

អនិយ័តភាពនៃនីតិវិធីគឺជាការអនុវត្តកិច្ចនីតិវិធីនៅក្នុងដំណាក់កាលមន្ត្រីនគបាលយុត្តិធម៌ ឬ ដំណាក់កាលអយ្យការដែលមិនបានអនុវត្តឲ្យបានត្រឹមត្រូវក្នុងច្បាប់ ។

**គ. ការផុតរលត់នៃបណ្តឹងអាជ្ញា**

ការផុតរលត់នៃបណ្តឹងអាជ្ញាដូចមានចែងក្នុង ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧មាត្រា៧និងមាត្រា៨។ ការផុតរលត់នៃបណ្តឹងអាជ្ញានាំឲ្យព្រះរាជអាជ្ញាសម្រេចតម្កល់រឿងទុកឥតចាត់ការ ឬ សម្រេចលើកលែងការចោទប្រកាន់ ។ មូលហេតុនៃការរលត់បណ្តឹងអាជ្ញាមានដូចជា :

- មរណភាពនៃជនល្មើស
- ការផុតអាជ្ញាយុកាល
- ការលើកលែងទោសជាទូទៅ

[126] មាត្រា១០៤កថាខណ្ឌ១នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣

[127] ប្រការ៤១នៃច្បាប់ស្តីពីការអនុម័តលើអនុសញ្ញាទីក្រុងវីយ៉ែនស្តីពីទំនាក់ទំនងកុងស៊ុលឆ្នាំ២០០៥

- និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ
- អាជ្ញាអស់ជំនុំ
- ការសម្របសម្រួលជាមួយរដ្ឋ
- ការដកពាក្យបណ្ដឹងដែលជាលក្ខខណ្ឌចាំបាច់នៃការចោទប្រកាន់ជាបទព្រហ្មទណ្ឌ
- ការបង់ប្រាក់ពិន័យសរុប ឬ ប្រាក់សម្របសម្រួល

**ឃ.ការរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ**

ការមិនទទួលខុសត្រូវព្រហ្មទណ្ឌដោយសារតែបុគ្គលមិនអាចទទួលខុសត្រូវព្រហ្មទណ្ឌ ឬ ដោយសារយុត្តិកម្មនៃបទល្មើស ឬ អំពើយុត្តាធិការ។ [128]

- ការមិនទទួលខុសត្រូវព្រហ្មទណ្ឌដោយសារតែបុគ្គលមិនអាចទទួលខុសត្រូវព្រហ្មទណ្ឌដែលរួមមាន:

**ឃ.១.អនីតិជន**

អនីតិជនដែលមានអាយុចាប់ពី ១៤ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ ដោយសារតែនីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌមានចាប់ពីអាយុ ១៨ឆ្នាំឡើង ។ ចំពោះវិធានការដែលអនុវត្ត ចំពោះ អនីតិជនដែលបានប្រព្រឹត្តបទល្មើស រួមមានកម្មវត្ថុ វិធានការតាមដាន វិធានការអប់រំ វិធានការការពារ និង វិធានការឧបត្ថម្ភ ។ ប៉ុន្តែក្នុងករណីពិសេសតុលាការអាចប្រកាសទណ្ឌកម្មទៅលើអនីតិជនដែលមានអាយុចាប់ពី ១៤ឆ្នាំ ឡើងទៅ ប្រសិនបើកាលៈទេសៈនៃបទល្មើស ឬ ដោយសារបុគ្គលិកលក្ខណៈរបស់អនីតិជនតម្រូវ។[129]

**ឃ.២ បុគ្គលដែលកើតវិបល្លាសស្មារតី**

បុគ្គលដែលកើតវិបល្លាសស្មារតី គឺជា បុគ្គលដែលបាត់បង់ទាំងស្រុងនូវការយល់ដឹងខុសត្រូវរបស់ខ្លួនជននោះមិនទទួលខុសត្រូវព្រហ្មទណ្ឌនោះទេ ។ ផ្ទុយមកវិញប្រសិនបើបុគ្គលនោះមាន ការបន្ថយនូវការយល់ដឹងខុសត្រូវរបស់ខ្លួនជននោះនៅតែទទួលខុសត្រូវព្រហ្មទណ្ឌដដែល ប៉ុន្តែ តុលាការនឹងពិចារណាលើការសម្រាលនូវការទទួលខុសត្រូវព្រហ្មទណ្ឌនៅពេលតុលាការកំណត់ទោស ។[130]

- ការមិនទទួលខុសត្រូវព្រហ្មទណ្ឌដោយសារតែយុត្តិកម្មនៃបទល្មើស ឬ អំពើយុត្តិការដែលរួមមាន:

**ឃ.៣.ការអនុញ្ញាតដោយច្បាប់ឬអាជ្ញាធរធម្មានុរូប**

[128] ឯកឧត្តម កើត រិទ្ធ បាឋកថាស្ដីពីគោលការណ៍គ្រឹះធំៗនៃក្រមព្រហ្មទណ្ឌនិងក្រមនីតិវិធីព្រហ្មទណ្ឌ

[129] មាត្រា៣៩នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

[130] មាត្រា៣១នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

ការអនុញ្ញាតដោយច្បាប់ ឬ អាជ្ញាធរធម្មានុរូប គឺបុគ្គលណាដែលប្រព្រឹត្តអំពើដែលបានបញ្ញត្តិ ឬ អនុញ្ញាតតាមច្បាប់បុគ្គលនោះមិនទទួលខុសត្រូវព្រហ្មទណ្ឌទេ ។ បុគ្គលណាដែលប្រព្រឹត្តអំពើតាមបញ្ជារបស់អាជ្ញាធរស្របច្បាប់លើកលែងអំពើនោះជាអំពើខុសច្បាប់ដោយជាក់លាក់ ។ ប៉ុន្តែចំពោះ បទឧក្រិដ្ឋប្រល័យពូជសាសន៍ បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ឬ បទឧក្រិដ្ឋសង្គ្រាមមិនអាចធ្វើការលើកលែងការចោទប្រកាន់បានទេ ។[131]

**ឃ.៤.ការការពារស្របច្បាប់**

ការការពារស្របច្បាប់ គឺជា បុគ្គលណាដែលប្រព្រឹត្តបទល្មើសក្នុងស្ថានភាព ដើម្បី ការពារស្របច្បាប់មិនទទួលខុសត្រូវព្រហ្មទណ្ឌទេ ។ ហើយការពារស្របច្បាប់មានលក្ខខណ្ឌ ដូចជា ប្រព្រឹត្តបទល្មើសដោយចាំបាច់ដើម្បី ការពារខ្លួន ការពារអ្នកដទៃ ឬ ការពារទ្រព្យសម្បត្តិដែលប្រឈមមុខនឹងការឈ្លានពានមួយដែលមិនត្រឹមត្រូវហើយបទល្មើសនោះ និង ការឈ្លានពាននោះត្រូវតែកើតឡើងក្នុងពេលជាមួយគ្នាហើយត្រូវគ្មានវិមាមាត្ររវាងមធ្យោបាយការពារដែលប្រើប្រាស់ និង ទម្ងន់នៃការឈ្លានពាននោះ ។[132]

**ឃ.៥.សច្ចធារណ៍នៃការការពារស្របច្បាប់**

សច្ចធារណ៍នៃការការពារស្របច្បាប់គឺ ជាការសន្មតថា ជាការពារស្របច្បាប់ចំពោះសច្ចធារណ៍នៃការការពារស្របច្បាប់ ។[133] បទល្មើសត្រូវបានប្រព្រឹត្ត ដើម្បី រុញច្រានចូលពេលយប់ដោយការកាប់គាស់ទម្លុះទម្លាយដោយហិង្សា ឬ ដោយកលល្បិចនៅក្នុងទីកន្លែងដែលមនុស្សនៅ ។ ហើយបទល្មើសនោះប្រព្រឹត្តឡើង ដើម្បីការពារខ្លួនពីការប្រឆាំងនឹងការលួច ឬ ប្លន់ដែលអនុវត្តដោយហិង្សា ។ ផ្ទុយមកវិញប្រសិនបើ រកឃើញភស្តុតាងផ្ទុយនាំឲ្យរំលាយសច្ចធារណ៍នៃការការពារស្របច្បាប់។

**ឃ៦. ស្ថានភាពចាំបាច់**

ស្ថានភាពចាំបាច់គឺសំដៅដល់បុគ្គលណាដែលប្រព្រឹត្តបទល្មើសដែលស្ថិតនៅក្នុងស្ថានភាពចាំបាច់មិនត្រូវទទួលខុសត្រូវព្រហ្មទណ្ឌទេ ។ ហើយអាចចាត់ទុកបានថាជា ស្ថានភាពចាំបាច់មានលក្ខខណ្ឌ ដូចជា បទល្មើសនោះប្រព្រឹត្តឡើង ដើម្បី ការពារខ្លួន ការពារអ្នកដទៃ ឬ ការពារទ្រព្យសម្បត្តិដើម្បីប្រឆាំងនឹងគ្រោះថ្នាក់ដែលកំពុងកើតមាន ឬដែលនឹងកើតមាន។ម្យ៉ាងទៀតត្រូវគ្មានវិសមាមាត្ររវាងមធ្យោបាយការពារ និងទម្ងន់គ្រោះថ្នាក់ ។[134]

**ឃ.៧. អានុភាពនៃកម្លាំងឬការបង្ខំ**

---

[131] មាត្រា៣៧នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

[132] មាត្រា៣៣នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

[133] មាត្រា៣៤នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

[134] មាត្រា៣៥នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

អានុភាពនៃកម្លាំង ឬ ការបង្ខំ គឺជាការប្រព្រឹត្តបទល្មើសក្រោមអានុភាពនៃកម្លាំង ឬ ការបង្ខំមិនទទួលខុសត្រូវព្រហ្មទណ្ឌឡើយ ។ ដែលលក្ខខណ្ឌនៃកម្លាំង ឬ ការបង្ខំនោះកើតឡើងក្រៅឆន្ទៈមនុស្សមិនអាចមើលឃើញទុកជាមុន ហើយកម្លាំង ឬ ការបង្ខំមិនអាចទប់ទល់ ឬ មិនអាចជៀសវាងបាន ។[135]

ដូច្នេះហើយ ព្រះរាជអាជ្ញានឹងធ្វើការតម្កល់រឿងទុកឥតចាត់ការចំពោះអំពើដែលជាបទល្មើសដោយសារមូលហេតុគតិយុត្ត ដែលរួមមាន អភ័យឯកសិទ្ធិ អនិយ័តភាពនៃនីតិវិធី ការរលត់បណ្តឹងអាជ្ញា ការរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ ។

### ១.២.២.២ ការចោទប្រកាន់មិនផ្តល់ផលប្រយោជន៍

ការចោទប្រកាន់មិនផ្តល់ផលប្រយោជន៍ គឺ ព្រះរាជអាជ្ញាបានថ្លឹមថ្លែងលើស្ថានភាពនានាដែលពាក់ព័ន្ធបទល្មើស ចារី ជនរងគ្រោះ ដោយរកឃើញថា ការចោទប្រកាន់មិនផ្តល់ផលអ្វីសោះដល់សង្គមហើយផ្ទុយនឹងគោលបំណងនៃបណ្តឹងអាជ្ញា។

ចំពោះមូលហេតុដែលការចោទប្រកាន់មិនផ្តល់ផលប្រយោជន៍ អាច បណ្តាលមកពីកត្តា ដូចជា កត្តាចំណាត់ការ កត្តាចារី កត្តាជនរងគ្រោះ កត្តាព្យសនកម្ម ។[136]

ការចោទប្រកាន់មិនផ្តល់ផលប្រយោជន៍រួមមានដូចជា:

- ការស្វែងរកមិនបានផល
- ដើមបណ្តឹងរដ្ឋប្បវេណីបានបោះបង់ពាក្យបណ្តឹង
- ស្ថានភាពវិបល្លាសស្មារតីដែលបន្តយនូវការយល់ដឹងខុសត្រូវ
- ការខកខានរបស់ដើមបណ្តឹង
- អាប្បកិរិយារបស់ជនរងគ្រោះ
- ជនរងគ្រោះមិនចាប់អារម្មណ៍បទល្មើស
- និយ័តកម្មដោយឯកឯង
- ព្យសនកម្ម ឬ ការរំខានតិចតួចបង្កដោយបទល្មើស។

ឧទាហរណ៍ ស្រ្តីមេម៉ាយម្នាក់បានលួចនំប៉័ងមួយដើមពីហាងលក់នំប៉័នដើម្បីយកទៅឲ្យកូនតូចបរិភោគ។ ហេតុនេះហើយព្រះរាជអាជ្ញាអាចយល់ឃើញថាការចោទប្រកាន់មិនផ្តល់ផលអ្វីដល់សង្គមដោយសារតែស្រ្តីនោះ

[135] មាត្រា៣៦នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

[136] រៀបរៀងដោយ ន. ស. រ មេរៀនការតម្កល់រឿងទុកឥតចាត់ការ ខែ មករា ឆ្នាំ ២០១៨

ប្រព្រឹត្តបទល្មើសលើកទីមួយហើយក៏ទទួលស្គាល់នៃកំហុសខ្លួន ស្ត្រីនោះមានបន្ទុកជាប់ខ្លួនក្នុងការចិញ្ចឹមបីបាច់ថែរក្សាកូនតូច ហើយអំពើនេះបង្កជាព្យសនកម្មតិចតួចដល់សង្គម ម្យ៉ាងជនរងគ្រោះដែលជាម្ចាស់ហាងក៏មិនបានខ្វល់ខ្វាយនៃការខូតខាតរបស់ខ្លួនឡើយ ។ ប្រសិនបើមានករណីនេះកើតឡើងព្រះរាជអាជ្ញានឹងតម្កល់រឿងទុកឥតចាត់ការ។

ដូចនេះហើយ ប្រសិនបើការចោទប្រកាន់មិនផ្តល់ផលប្រយោជន៍អ្វីដល់សង្គមហើយបទល្មើសនោះមានព្យសនកម្មតិចតួចការលើកលែងការចោទប្រកាន់គួរត្រូវបានអនុវត្តដោយតំណាងអយ្យការ។

## ១.៣ អានុភាពនិងនីតិវិធីនៃការតម្កល់រឿងទុកឥតចាត់ការ

### ១.៣.១ នីតិវិធីនៃការតម្កល់រឿងទុកឥតចាត់ការ

ការរលត់បណ្តឹងអាជ្ញាមានអានុភាពនាំឲ្យព្រះរាជអាជ្ញាសម្រេចតម្កល់រឿងទុកឥតចាត់ការ ។ ហើយការសម្រេចរឿងទុកឥតចាត់ការនោះមាននីតិវិធីបីដំណាក់កាលដែលរួមមាន ដូចជា:

#### ១.៣.១.១ ការស្រាវជ្រាវ

ក្រោយពីពេលដែលព្រះរាជអាជ្ញាបានទទួលពាក្យប្តឹងដោយទទួលបានដោយផ្ទាល់ ឬ ទទួលបានតាមរយៈមន្ត្រីនគរបាលយុត្តិធម៌បញ្ជូនមកព្រះរាជអាជ្ញាត្រូវតែថ្លឹងថ្លែងអំពីចំណាត់ការលើពាក្យប្តឹងនោះ ។ ព្រះរាជអាជ្ញាត្រូវតែបើកការស៊ើបអង្កេតបឋម ឬ បង្គាប់ធ្វើការស្រាវជ្រាវបន្ថែមលើករណីនោះ ។[137] ព្រះរាជអាជ្ញាអាចប្រើប្រាស់អំណាចទាំងអស់ដែលច្បាប់ទទួលស្គាល់ដើម្បីឲ្យមន្ត្រីនគរបាលយុត្តិធម៌ធ្វើការស៊ើបអង្កេត ។[138]

ដូចនេះហើយមុននឹងធ្វើចំណាត់ការលើពាក្យប្តឹងព្រះរាជអាជ្ញាត្រូវតែធ្វើការស៊ើបអង្កេតបឋម ឬ ធ្វើការបង្គាប់ឲ្យមន្ត្រីនគរបាលយុត្តិធម៌ធ្វើការស្រាវជ្រាវបន្ថែម។

#### ១.៣.១.២ ការសម្រេចតម្កល់រឿងទុកឥតចាត់ការ

ក្រោយពីការស៊ើបអង្កេតបឋម ឬ បង្គាប់រួចហើយព្រះរាជអាជ្ញានឹងធ្វើការសម្រេចចោទប្រកាន់ ឬ លើកលែងការចោទប្រកាន់ ។ ប្រសិនបើព្រះរាជអាជ្ញាសម្រេចតម្កល់រឿងទុកឥតចាត់ការព្រះរាជអាជ្ញាត្រូវចេញដីកាមួយគឺឈ្មោះថាដីកាសម្រេចតម្កល់រឿងទុកឥតចាត់ការ។

[137] មាត្រា៤០កថាខណ្ឌ២នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[138] មាត្រា៣៧កថាខណ្ឌ២នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

#### ១.៣.១.៣ ការជូនដំណឹង

កាលណាព្រះរាជអាជ្ញាសម្រេចតម្កល់រឿងទុកឥតចាត់ការ ព្រះរាជអាជ្ញាត្រូវជូនដំណឹងទៅអ្នកប្តឹង អំពីសេចក្តីសម្រេចរបស់ខ្លួនក្នុងរយៈពេលយ៉ាងខ្លីបំផុត គឺ យ៉ាងយូរបំផុតរយៈពេល ២ខែ គឺចាប់ពីថ្ងៃដែលពាក្យប្តឹងបានចុះក្នុងបញ្ជីនៃពាក្យប្តឹង ។[139] បញ្ជីនៃពាក្យប្តឹងត្រូវបានចែងក្នុងមាត្រា ៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

### ១.៣.២ អានុភាពនៃការតម្កល់រឿងទុកឥតចាត់ការ

ការតម្កល់រឿងទុកឥតចាត់ការត្រូវធ្វើឡើងដោយមានសំអាងហេតុ និង សំអាងច្បាប់។ ការតម្កល់រឿងទុកឥតចាត់ការនេះគ្មានអាជ្ញាអស់ជំនុំនោះទេ។[140]

ដូចនេះហើយការតម្កល់រឿងទុកឥតចាត់ការពុំបង្កើតអានុភាពអស់ជំនុំមានន័យថាព្រះរាជអាជ្ញាអាចធ្វើការចោទប្រកាន់ឡើងវិញនៅពេលក្រោយបាន ទោះបីជា បានតម្កល់រឿងទុកឥតចាត់ការក៏ដោយ។

### ១.៣.៣ យន្តការប្រឆាំងនឹងការតម្កល់រឿងទុកឥតចាត់ការ

នៅពេលដែលមានការសម្រេចតម្កល់រឿងទុកឥតចាត់ការនាំឲ្យភាគីអ្នកប្តឹងអាចនឹងសុខចិត្ត ឬ មិនសុខចិត្តនឹងការសម្រេចនេះ ។ ហេតុនេះហើយយន្តការប្រឆាំងនឹងការតម្កល់រឿងទុកឥតចាត់ការត្រូវបានលើកឡើងដើម្បី នាំឲ្យមានការចោទប្រកាន់ឡើងវិញបន្ទាប់ពីមានការតម្កល់រឿងទុកឥតចាត់ការ។

យន្តការប្រឆាំងនឹងការតម្កល់រឿងទុកឥតចាត់ការមានចំនួន៤គឺ[141]:

- ព្រះរាជអាជ្ញាអាចសើរើកែប្រែសេចក្តីសម្រេចរបស់ខ្លួន ប្រសិនបើ បណ្តឹងអាជ្ញាមិនទាន់ផុតរលត់នៅឡើយ។[142]
- ការប្តឹងតវ៉ាទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍[143]
- ការធ្វើអធិបញ្ញាតាមនាយឋានទុក្រមអង្គអយ្យការ
- ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី[144]

[139] មាត្រា៤១កថាខណ្ឌ១នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[140] មាត្រា៤១កថាខណ្ឌ២នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[141] រៀបរៀងដោយ ន. ស. រ មេរៀនការតម្កល់រឿងទុកឥតចាត់ការ ខែ មករា ឆ្នាំ ២០១៨

[142] មាត្រា៤១កថាខណ្ឌ៣នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[143] មាត្រា៤១កថាខណ្ឌ៤នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[144] មាត្រា៥នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

ដូចនេះហើយការតម្កល់រឿងទុកឥតចាត់ការត្រូវមានសំអាងហេតុ និង សំអាងច្បាប់ឲ្យបានត្រឹមត្រូវ ។ម្យ៉ាង ការតម្កល់រឿងទុកឥតចាត់ការនេះមិនមានអាជ្ញាអស់ជំនុំដែលអាចធ្វើការចោទប្រកាន់ឡើងវិញ តាមមធ្យោបាយណាមួយដូចមានក្នុងយន្តការប្រឆាំងនឹងការតម្កល់រឿងទុកឥតចាត់ការ។

## ផ្នែកទី២៖ នីតិវិធីនៃការរលត់បណ្តឹងអាជ្ញាក្នុងដំណាក់កាលការស៊ើបសួរ ឬ ដំណាក់កាលការជំនុំជម្រះ

ប្រសិនបើការរលត់បណ្តឹងអាជ្ញាត្រូវបានសម្រេចដោយ តំណាងអយ្យការ នៅក្នុងដំណាក់អយ្យការនាំឲ្យព្រះរាជអាជ្ញាអាចសម្រេចតម្កល់រឿងទុកឥតចាត់ការ ឬ លើកលែងការចោទប្រកាន់។ ប៉ុន្តែផ្ទុយមកវិញ បើព្រះរាជអាជ្ញាសម្រេចធ្វើការចោទប្រកាន់នោះ នាំឲ្យចៅក្រមស៊ើបសួរមានតួនាទីស្រាវជ្រាវសំណុំរឿងក្តី ដើម្បី ធ្វើការដោះបន្ទុក ឬ ដាក់បន្ទុកទៅដល់ជនជាប់ចោទចំពោះបទឧក្រិដ្ឋដាច់ខាត ឬ មិនដាច់ខាតចំពោះបទមជ្ឈិមដែលជាតួនាទីចៅក្រមស៊ើបសួរក្នុងដំណាក់កាលការស៊ើបសួរ ។ ចៅក្រមស៊ើបសួរនឹងចេញដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះ ដើម្បី កំណត់ពេលសវនាការជំនុំជម្រះ ។ ដំណាក់កាលរឿងក្តីព្រហ្មទណ្ឌមានលក្ខណៈស្មុគស្មាញបែបនេះមានន័យថា ដើម្បី ជំនុំជម្រះបុគ្គលម្នាក់ប្រព្រឹត្តបទល្មើស ឬ អត់ត្រូវឆ្លងកាត់ដំណាក់កាលនីមួយៗ ជាមុនសិន ។ នៅក្នុងដំណាក់កាលនៃការស៊ើបសួរ និង ដំណាក់កាលការជំនុំជម្រះអាចត្រូវបានចាប់ផ្តើម ឬ បន្តបានប្រសិនបើមិនមានការរលត់បណ្តឹងអាជ្ញាក្នុងដំណាក់កាលខាងលើទេ។

ដូច្នេះហើយការស្វែងយល់ពីនីតិវិធីនៃការរលត់បណ្តឹងអាជ្ញាក្នុងដំណាក់នៃការស៊ើបសួរ និង ដំណាក់កាលការជំនុំជម្រះជារឿងចាំបាច់។

### ២.១ សញ្ញាណទូទៅនៃដំណាក់កាលការស៊ើបសួរ

#### ២.១.១ យុត្តាធិការស៊ើបសួរ

ចៅក្រមស៊ើបសួរ មានតួនាទីក្នុងការស្រាវជ្រាវសំណុំរឿងក្តីដែលបានប្តឹងមកតាមរយៈដីកាបញ្ជូនរឿងឲ្យស៊ើបសួររបស់ព្រះរាជអាជ្ញា ។ ចៅក្រមស៊ើបសួរធ្វើការស្រាវជ្រាវក្នុងគោលបំណង ដើម្បី ធ្វើការស្វែងរកភស្តុតាងដាក់បន្ទុក ឬ ភស្តុតាងដោះបន្ទុកនៃសំណុំរឿងក្តីនោះ ។[145] ចៅក្រមស៊ើបសួរមានតួនាទីសម្រេចដោយដោះស្រាយការលំបាកខាងផ្នែកវិវាទដែលកើតមានឡើង ។ ចៅក្រមស៊ើបសួរអាចបំពេញកិច្ចស៊ើបសួរទាំងអស់ដែលចៅក្រមស៊ើបសួរយល់ឃើញថាមានប្រយោជន៍ដើម្បីឲ្យឃើញការពិតដោយអនុលោមតាមច្បាប់។

[145] មាត្រា១២៧កថាខណ្ឌ២នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

#### ២.១.១.១ ការបើកការស៊ើបសួរ

ការស៊ើបសួរត្រូវតែធ្វើដាច់ខាតចំពោះ បទឧក្រិដ្ឋ ចំណែកបទមជ្ឈិមចៅក្រមស៊ើបសួរអាចធ្វើការស៊ើបសួរក៏បាន ឬ អត់ក៏បាន។ ចៅក្រមស៊ើបសួរមិនអាចបំពេញកិច្ចស៊ើបសួរបានឡើយ ប្រសិនបើមិនមានដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់ព្រះរាជអាជ្ញា ។[146] ចៅក្រមស៊ើបសួរអាចបើកការស៊ើបសួររយៈមធ្យោបាយដូចខាងក្រោម[147]:

- តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់ព្រះរាជអាជ្ញា
- ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ជនរងគ្រោះតាមផ្លូវអន្តរាគមន៍
- ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ជនរងគ្រោះតាមផ្លូវបណ្តឹង

ប្រសិនបើចៅក្រមស៊ើបសួរទទួលបានពាក្យបណ្តឹងការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ជនរងគ្រោះរួចហើយចៅក្រមស៊ើបសួរត្រូវធ្វើការកត់សម្គាល់ដោយដីការួចបញ្ជូនពាក្យបណ្តឹងទៅតំណាងអយ្យការ ។ ក្នុងករណីនេះព្រះរាជអាជ្ញាអាចស្នើសុំមិនឲ្យធ្វើការស៊ើបសួរ ប្រសិនបើ បណ្តឹងអាជ្ញាត្រូវបានផុតរលត់ ឬ អំពើមិនមែនជាបទល្មើស។ ក្នុងករណីនេះចៅក្រមស៊ើបសួរមិនជាប់កាតព្វកិច្ចតាមការស្នើសុំរបស់ព្រះរាជអាជ្ញានោះទេ ។ ដូច្នេះហើយចៅក្រមស៊ើបសួរអាចសម្រេចធ្វើការស៊ើបសួរ ឬ មិនធ្វើការស៊ើបសួរបាន ។[148]

#### ២.១.១.២ កិច្ចស៊ើបសួរ

ចៅក្រមស៊ើបសួរអាចត្រូវបានស្នើសុំឲ្យបំពេញកិច្ចស៊ើបសួរគ្រប់ពេលវេលាដោយ ជនត្រូវចោទ ដោយព្រះរាជអាជ្ញា ឬ ដើមបណ្តឹងរដ្ឋប្បវេណី។ ចៅក្រមអាចធ្វើការស៊ើបសួរដោយឯកឯង ឬ តាមដីកាចាត់ឲ្យស៊ើបសួរជំនួសទៅចៅក្រមផ្សេងមន្ត្រីនគរបាលយុត្តិធម៌ ឬ អង្គការនគរបាលយុត្តិធម៌ ។[149] ព្រះរាជអាជ្ញាអាចពិនិត្យមើលសំណុំរឿងគ្រប់ពេលហើយអាចមានវត្តមាននៅគ្រប់កិច្ចបាន។ កិច្ចស៊ើបសួរមានដូចជា:

- ការសួរចម្លើយជនជាប់ចោទ
- ការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី
- ការស្តាប់ចម្លើយសាក្សី
- ការឆែកឆេរនិងការចាប់យកវត្ថុតាង

---

[146] មាត្រា១២៤កថាខណ្ឌ៣នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[147] មាត្រា១២៤នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[148] មាត្រា១៣៩នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[149] មាត្រា១៣១នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

- កោសលវិច័យ
- ការស្តាប់ទូរស័ព្ទនិងថតការសន្ទនា

**២.១.១.៣ អំណាចរបស់ចៅក្រមស៊ើបសួរ**

ដើម្បីឲ្យកិច្ចស៊ើបសួរប្រព្រឹត្តទៅដោយរលូនចៅក្រមស៊ើបសួរត្រូវមានអំណាចដូចខាងក្រោម[150]:

- ចៅក្រមស៊ើបសួរអាចចេញដីកាបង្គាប់ឲ្យចូលខ្លួន
- ចៅក្រមស៊ើបសួរអាចចេញដីកាបង្គាប់ឲ្យនាំខ្លួន
- ចៅក្រមស៊ើបសួរអាចចេញដីកាបង្គាប់ឲ្យចាប់ខ្លួន
- ចៅក្រមស៊ើបសួរអាចចេញដីកាសម្រេចឲ្យឃុំខ្លួនបណ្តោះអាសន្នចំពោះជនត្រូវចោទ
- ការត្រួតពិនិត្យតាមផ្លូវតុលាការចំពោះជនត្រូវចោទ
- ការបង្កកទ្រព្យសម្បត្តិ។

ដូចនេះ ហើយចៅក្រមស៊ើបសួរអាចប្រើប្រាស់អំណាចនូវ វិធានការនិរន្តរាយ ការដាក់ត្រួតពិនិត្យតាមផ្លូវតុលាការ និង ការបង្កកទ្រព្យសម្បត្តិដូចមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ឬ ច្បាប់ដោយឡែកមួយចំនួន។

**២.១.១.៤ ការបិទកិច្ចស៊ើបសួរ**

ចៅក្រមស៊ើបសួរត្រូវបិទបញ្ចប់ការស៊ើបសួររបស់ខ្លួនដោយត្រូវជូនព័ត៌មាននេះដល់ ព្រះរាជអាជ្ញា ជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី និង មេធាវី ។ ចៅក្រមស៊ើបសួរត្រូវបញ្ជូនសំណុំរឿងឲ្យព្រះរាជអាជ្ញាពិនិត្យ ពីរថ្ងៃក្រោយពីជូនដំណឹងពីការបិទស៊ើបសួរនោះ ។ ព្រះរាជអាជ្ញាអាចស្នើសុំឲ្យបំពេញកិច្ចដោយព្រះរាជអាជ្ញាទៅកាន់ចៅក្រមស៊ើបសួរឲ្យធ្វើកិច្ចស៊ើបសួរថ្មីប្រសិនបើយល់ឃើញថាចាំបាច់ ។ ហើយ ព្រះរាជអាជ្ញាត្រូវបញ្ជូនដីកាសន្និដ្ឋានស្ថាពរទៅចៅក្រមស៊ើបសួរវិញក្នុងរយៈពេល ១៥ថ្ងៃ ប្រសិនបើក្នុងករណីជនត្រូវចោទជាប់ឃុំខ្លួន និង ១ ខែបើជនត្រូវចោទនៅក្រៅឃុំ ។ ព្រះរាជអាជ្ញាអាចយល់ឃើញដូច ចៅក្រមស៊ើបសួរនាំឲ្យបញ្ចប់ការស៊ើបសួរព្រះរាជអាជ្ញានឹងត្រូវធ្វើសេចក្តីសន្និដ្ឋានស្ថាពរជាលាយលក្ខណ៍អក្សរនិងមានសំអាងហេតុ។ព្រះរាជអាជ្ញាអាចប្តឹងសុំឲ្យចៅក្រមស៊ើបសួរសម្រេចបញ្ជូនខ្លួនជនត្រូវចោទទៅកាន់តុលាការជំនុំជម្រះឬលើកលែងការចោទប្រកាន់។[151]

ចៅក្រមស៊ើបសួរបិទការស៊ើបសួររបស់ខ្លួនតាមរយៈដីកាដំណោះស្រាយដែលដីកាដំណោះស្រាយនេះអាចជាដីកាបញ្ជូនទៅជំនុំជម្រះឬដីកាលើកលែងការចោទប្រកាន់។[152]

---

[150] ចក សម្បត្តិ អនុប្រធានសមាគមត្រាជូ , នីតិវិធីព្រហ្មទណ្ឌកម្ពុជា(សាលាត្រាជូ)

[151] មាត្រា២៤៦នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[152] មាត្រា២៤៧នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

ដីកាដំណោះស្រាយត្រូវតែមានសំអាងហេតុ ហើយចៅក្រមស៊ើបសួរមិនត្រូវជាប់កាតព្វកិច្ចគោរពតាមដីកាសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញាទេ ។ ដីកាអាចជាដីកាបញ្ជូនទៅតុលាការជំនុំជម្រះអំពើមួយចំនួន និង អាចជាដីកាលើកលែងការចោទប្រកាន់ចំពោះអំពើមួយចំនួន ។ ដីកាដំណោះស្រាយត្រូវបញ្ជូនទៅរយៈពេលដ៏ខ្លីបំផុតដល់ ព្រះរាជអាជ្ញា ដើមបណ្តឹងរដ្ឋប្បវេណីនិងជនត្រូវចោទ។

ដូចនេះហើយចៅក្រមស៊ើបសួរអាចបិទការស៊ើបសួរដែលអាចជាដីកាបញ្ជូនទៅជំនុំជម្រះ ឬ ដីកាលើកលែងការចោទប្រកាន់។

## ២.២ សញ្ញាណទូទៅនៃដំណាក់កាលការជំនុំជម្រះ

### ២.២.១ យុត្តាធិការជំនុំជម្រះ

អំណាចតុលាការជា អំណាចឯករាជ្យដែលត្រូវបានចែងនៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣ ។ អំណាចតុលាការត្រូវតែធានារក្សានៃអនាគតិ និង ការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ ។ ការជំនុំជម្រះត្រូវតែធ្វើឡើងដោយយុត្តិធម៌ តាមនីតិវិធី និង ច្បាប់ជាធរមានព្រោះតែការជំនុំជម្រះក្តីនេះត្រូវធ្វើឡើងក្នុងនាមជាប្រជារាស្ត្រខ្មែរ ។[153]

សាលាដំបូងត្រូវបានជំនុំជម្រះចំពោះ បទឧក្រិដ្ឋ បទមជ្ឈិម និង បទលហុ។ ក្នុងការជំនុំជម្រះក្តីសាលាដំបូងត្រូវសម្រេចជាក្រុមសមូហភាពដែលមានចៅក្រមបីរូបរួមទាំងបទមជ្ឈិម និង បទលហុដែលជាប់ទាក់ទង ។ បទមជ្ឈិម និង បទលហុសាលាដំបូងសម្រេចជាចៅក្រមទោល។[154]

ចៅក្រមដែលបានបំពេញមុខងារជាក្នុងឋានៈជាព្រះរាជអាជ្ញាជាចៅក្រមស៊ើបសួរលើរឿងក្តីណាមួយគឺច្បាប់មិនអនុញ្ញាតឲ្យចូលរួមក្នុងការជំនុំជម្រះក្តីនោះបានទេបើមិនដូច្នេះទេ សាលក្រមគឺនឹងមោឃៈ។[155]

#### ២.២.១.១ របៀបប្តឹងទៅតុលាការ

នៅក្នុងរឿងក្តីព្រហ្មទណ្ឌសាលាដំបូងទទួលបានបណ្តឹងតាមមធ្យោបាយ ដូចជា ដីកាសន្និដ្ឋានរបស់ចៅក្រមស៊ើបសួរ ឬ សាលដីកាបញ្ជូនរបស់សភាស៊ើបសួរ ឬ តាមរយៈដីកាសន្និដ្ឋានបញ្ជូនទៅតុលាការជំនុំជម្រះដោយផ្ទាល់របស់ព្រះរាជអាជ្ញា ឬ តាមរយៈកំណត់ហេតុស្តីពីការចូលបង្ហាញខ្លួនភ្លាមដែលធ្វើឡើងដោយព្រះរាជអាជ្ញា។[156]

---

153 មាត្រា១២៨ថ្មី(មាត្រា១១០ចាស់)នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣

154 មាត្រា២៤៧នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

155 មាត្រា២៨៨នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

156 មាត្រា២៩១នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

បុគ្គលដែលបានបញ្ជូនទៅជំនុំជម្រះចំពោះមុខតុលាការមានឈ្មោះថាជាជនជាប់ចោទ ។ជនរងគ្រោះនៃបទល្មើសអាចធ្វើការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីបាន ប្រសិនបើ ពុំទាន់បានតាំងខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរ ។ ចំណែកអ្នកទទួលខុសត្រូវរដ្ឋប្បវេណី គឺជា បុគ្គលដែលត្រូវជួសជុលព្យសនកម្មដែលបណ្តាលឲ្យមានជនរងគ្រោះនៃបទល្មើស។

**២.២.១.២ សិទ្ធិអំណាចចៅក្រមជំនុំជម្រះ**

ការពិភាក្សាដេញដោលក្នុងសវនាការជាសាធារណៈចំពោះមុខចៅក្រមជំនុំជំម្រះ ដើម្បី ស្វែងរកការពិតណាមួយនោះ គឺជា នីតិវិធីជំនុំជម្រះ។ ចៅក្រមជំនុំជម្រះមានសិទ្ធិអំណាច ដូចជា[157]:

- កំណត់កាលបរិច្ឆេទសវនាការ
- ការបញ្ចូលនីតិវិធី
- សម្រេចទាក់ទងនឹងបញ្ហាឃុំខ្លួនជនជាប់ចោទ
- បង្គាប់ឲ្យនាំខ្លួនជនជាប់ចោទ
- បង្គាប់ឲ្យនាំខ្លួនសាក្សី
- ដឹកនាំសវនាការ
- សួរចម្លើយជនជាប់ចោទ
- ស្តាប់ចម្លើយរបស់ភាគី
- វាយតម្លៃដោយសេរីលើភស្តុតាង
- ចុះទៅកាន់គ្រប់ទីកន្លែងនៃដែនដីជាតិ
- បង្គាប់ឲ្យធ្វើការស៊ើបសួរបន្ថែម
- ការសម្រេចអំពីអញ្ញត្រកម្ម

ដូចនេះហើយ ចៅក្រមជំនុំជម្រះមានសិទ្ធិ និង អំណាចក្នុងដំណាក់កាលការជំនុំជម្រះ ដើម្បី ឲ្យការជំនុំជម្រះប្រកបដោយភាពរលូន និង អាចរកបានភាពយុត្តិធម៌ដល់ជនជាប់ចោទ និង ជនរងគ្រោះហើយជាពិសេសដល់សាធារណជនទាំងមូល។

[157] លោក អឿង សៀង, មេរៀននីតិវិធីជំនុំជម្រះរឿងក្តីព្រហ្មទណ្ឌនៅសាលាដំបូង, រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ

### ២.២.១.៣ ការពិភាក្សាដេញដោល

ការពិភាក្សាដេញដោលត្រូវធ្វើឡើងនៅក្នុងពេលសវនាការសាធារណៈ ។ សវនាការអាចប្រព្រឹត្តឡើងនៅអសាធារណៈនៅពេលដែលតុលាការ យល់ឃើញថា បង្កឲ្យមានគ្រោះថ្នាក់ ដល់ សណ្តាប់ធ្នាប់សាធារណៈ ឬ ប៉ះពាល់ដល់ទំនៀមទំលាប់នោះតុលាការអាចសម្រេចក្តីដោយមាន សំអាងហេតុអាចបង្គាប់ឲ្យការពិភាក្សាដេញដោលទាំងស្រុង ឬ ផ្នែកប្រព្រឹត្តទៅជាសម្ងាត់ ។ តុលាការអាចសម្រេចតាមសាលក្រមមួយដាច់ដោយឡែកពីសាលក្រមអង្គសេចក្តី ឬ តាមសេចក្តីសម្រេចពិសេសនៃសាលក្រមលើអង្គសេចក្តី។[158]

ប្រធានសវនាការគឺជាអ្នកដឹកនាំការពិភាក្សាដេញដោល ។ ប្រធានសវនាការគឺជាអ្នកធានារ៉ាប់រងឲ្យមានសណ្តាប់ធ្នាប់ល្អនៅពេលសវនាការ ។ ប្រធានសវនាការអាចហាមឃាត់អនីតិជនខ្លះ ឬ ទាំងអស់មិនឲ្យចូលក្នុងបន្ទប់សវនាការបាន ។ ក្នុងនោះដែលប្រធានសវនាការអាចបង្គាប់ឲ្យ បណ្តេញបុគ្គលណា ដែលបង្កឲ្យមានការច្របូកច្របល់រៀបរយនៃការពិភាក្សាដេញដោល ។ ប្រធានសវនាការក៏អាចប្រើប្រាស់កងកម្លាំងសាធារណៈផងដែរ។

ដូចនេះហើយការប្រកាសសាលក្រមត្រូវតែប្រកាសនៅពេលសវនាការជាសាធារណៈ ។

### ២.២.១.៤ ការប្រកាសសាលក្រម

ការប្រកាសសាលក្រមត្រូវធ្វើឡើងជាសាធារណៈ ។ សាលក្រមនោះអាចសម្រេចឲ្យរួចទោសកាលណាគ្មានបទល្មើសព្រោះ វិមតិសង្ស័យជាផលប្រយោជន៍របស់ជនជាប់ចោទ ។ ប្រសិនបើតុលាការពិនិត្យមើលថាអំពើនោះជា បទឧក្រិដ្ឋ ឬ បទមជ្ឈិម ឬ បទលហុ ហើយជនជាប់ចោទបានប្រព្រឹត្តអំពើលើខ្លួននោះតុលាការប្រកាសតាមច្បាប់កំណត់ ។ ក្នុងសាលក្រមតែមួយនោះត្រូវសម្រេចលើផលប្រយោជន៍រដ្ឋប្បវេណីដែលជនរងគ្រោះបានតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដើម្បី ទាមទារការជួសជុលព្យសនកម្មនៃបទល្មើសពីជនជាប់ចោទ ឬ ពីអ្នកទទួលខុសត្រូវរដ្ឋប្បវេណី។[159]

ម្យ៉ាងទៀតតុលាការនឹងសម្រេចបង្គាប់ឲ្យឃុំខ្លួន និង ចាប់ខ្លួនជនជាប់ចោទដូចមានចែងក្នុង មាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌប្រសិនបើតុលាការប្រកាសផ្តន្ទាទោសដាក់ពន្ធនាគារ ១ឆ្នាំ យ៉ាងតិចដោយគ្មានការព្យួរទោសទេ តុលាការសម្រេចសេចក្តីពិសេស និង មានសំអាងហេតុអាចចេញនៅក្នុងពេលសវនាការ ។ តុលាការក៏អាចសម្រេចធ្វើការប្រគល់វត្ថុដែលចាប់យកដូចមានចែងក្នុងមាត្រា ៣៥៤ នៃក្រមនីតិវិធិព្រហ្មទណ្ឌផងដែរ។

[158] មាត្រា៣១៦នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[159] មាត្រា៣៥៥នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

សាលក្រមព្រហ្មទណ្ឌអាចត្រូវបានប្រកាសចំពោះមុខ ឬ អាចត្រូវបានប្រកាសសាលក្រមកំបាំងមុខ ឬ សាលក្រមដែលត្រូវចាត់ទុកថាចំពោះមុខដែលត្រូវប្រកាសដែលសម្រេចសេចក្តីដល់ជនជាប់ចោទ ឬ ចំពោះដើមបណ្តឹងរដ្ឋប្បវេណី។

ដូចនេះ ហើយសាលក្រមត្រូវប្រកាសជាសាធារណៈគ្រប់ករណីទាំងអស់ ហើយសាលក្រមនោះអាចសម្រេចធ្វើការចោទប្រកាន់ ឬ សម្រេចឲ្យជនជាប់ចោទរួចពីបទចោទ សម្រេចបង្គាប់ឲ្យឃុំខ្លួន និង ចាប់ខ្លួនជនជាប់ចោទហើយនិងសម្រេចពីការប្រគល់វត្ថុដែលចាប់យក តាមរយៈការប្រកាសសាលក្រមនោះ។

## ២.៣.នីតិវិធីការរលត់បណ្តឹងអាជ្ញានៅក្នុងដំណាក់កាលការស៊ើបសួរឬដំណាក់កាលការជំនុំជម្រះដោយសារមរណភាពជនល្មើស

នៅពេលដែលជនត្រូវចោទបានស្លាប់ នៅក្នុង ដំណាក់កាលការស៊ើបសួរនាំឲ្យចៅក្រមស៊ើបសួរត្រូវតែបញ្ឈប់ការស៊ើបសួរដែលត្រូវផ្តល់ដំណឹងដល់ ព្រះរាជអាជ្ញា ដើមបណ្តឹងរដ្ឋប្បវេណី និង មេធាវីពីការបិទការស៊ើបសួរដោយសារតែមូលហេតុមរណភាពរបស់ជនត្រូវចោទ ។ ចៅក្រមស៊ើបសួរត្រូវតែបង្ហាញពីមូលហេតុដែលជនត្រូវចោទទទួលមរណភាពទៅកាន់ព្រះរាជអាជ្ញា ។ ព្រះរាជអាជ្ញានឹងធ្វើការពិនិត្យសំណុំរឿងនោះ ហើយ ពិនិត្យមូលហេតុនៃការស្លាប់របស់ជនត្រូវចោទក្រោយពី ទទួលដំណឹងពីការទទួលមរណភាពរបស់ជនត្រូវចោទ ។ ព្រះរាជអាជ្ញាអាចនឹងចេញដីកាសន្និដ្ឋានស្ថាពរជាលាយលក្ខណ៍អក្សរ និង មានសំអាងហេតុ។

ប្រសិនបើ ពិនិត្យទៅលើនីតិវិធីដែលត្រូវបានអនុវត្តនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាវិធានផ្ទៃក្នុង ( វិសោធនកម្មលើកទី៩ ) បានចែងឲ្យដឹងថា ប្រសិនបើជនសង្ស័យ ជនត្រូវចោទ ឬ ជនជាប់ចោទបានទទួលមរណភាព នៅក្នុង ឬ នៅក្រោមន្ទីរឃុំឃាំង អ.វ.ត.ក រួមទាំងនៅក្នុងមន្ទីរពេទ្យសហព្រះរាជអាជ្ញាត្រូវស្វែងរកមូលហេតុនៃការស្លាប់នេះ ។ ក្នុងការស្វែងរកមូលហេតុនៃការស្លាប់នេះ ព្រះរាជអាជ្ញា អាចបង្គាប់ឲ្យមានការពិនិត្យសាកសព និង មានការពិនិត្យរបាយការណ៍ជាតិពុលបន្ថែមលើការសាកសួរនានារបស់សហព្រះរាជអាជ្ញាដែលយល់ឃើញថា ដើម្បី កំណត់ពីមូលហេតុនៃការស្លាប់នោះ ។ ក្នុងករណី រកឃើញការស្លាប់មិនមែនជាមូលហេតុធម្មជាតិសហព្រះរាជអាជ្ញាត្រូវផ្ទេរសំណុំរឿងនេះទៅ ព្រះរាជអាជ្ញា ដែលមានសមត្ថកិច្ចក្នុងតុលាការជាតិ ។ [160] មរណភាពរបស់ជនត្រូវចោទ ឬ ជនជាប់ចោទនៅក្នុងដំណាក់កាលការស៊ើបសួរ ឬ ដំណាក់កាលការជំនុំជម្រះ គឺព្រះរាជអាជ្ញា គឺជា តួអង្គសំខាន់ក្នុងការស្វែងរក ឬ ពិនិត្យមើលមូលហេតុនៃការស្លាប់របស់ជនជាប់ចោទនោះ ។

[160] វិធាន៣២ស្ទួននៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាវិធានផ្ទៃក្នុង ( វិសោធនកម្មលើកទី៩ ), វិសោធនកម្មថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០១៥

ការអនុវត្តនីតិវិធីក្នុងករណីជនជាប់ចោទ ឬ ជនត្រូវចោទទទួលមរណភាពសង្កេតឃើញថា មានដីកាដែលចេញដោយព្រះរាជអាជ្ញានោះ គឺ ដីកាសម្រេចរំលត់បណ្តឹងអាជ្ញា ប្រសិនបើជនជាប់ចោទ ឬ ជនត្រូវចោទនោះទទួលមរណភាពក្នុងដំណាក់កាលណាមួយ ។ ចំណែកចៅក្រមស៊ើបសួរត្រូវចេញដីកាដំណោះស្រាយប្រសិនបើជនត្រូវចោទបានស្លាប់ក្នុងដំណាក់កាលដែលខ្លួនទទួលខុសត្រូវនោះគឺដីកាលើកលែងចោទប្រកាន់ ។ ដូចនេះដីកាដែលត្រូវចេញពេលដែលជនត្រូវចោទ ឬ ជនជាប់ចោទទទួលមរណភាពគឺ:

- ដីកាលើកលែងចោទប្រកាន់
- ដីកាសម្រេចរំលត់បណ្តឹងអាជ្ញា

### ២.៣.១ ដីកាលើកលែងចោទប្រកាន់

ប្រសិនបើ ជនត្រូវចោទត្រូវបានស្លាប់នៅក្នុងដំណាក់កាលការស៊ើបសួរ នាំឲ្យ ការចោទប្រកាន់ព្រហ្មទណ្ឌមិនអាចបានធ្វើទៀតទេ ។ តាមន័យនេះហើយនាំឲ្យចៅក្រមស៊ើបសួរត្រូវបិទការស៊ើបសួររបស់ខ្លួនដោយចេញដីកាដំណោះស្រាយមួយដែលជា ដីកាលើកលែងចោទប្រកាន់ ដោយត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញា និង ដើមបណ្តឹងរដ្ឋប្បវេណីពីមូលហេតុដែលលើកលែងចោទប្រកាន់ដោយសារមរណភាពរបស់ជនត្រូវចោទ ។ ដីកាលើកលែងចោទប្រកាន់នោះត្រូវតែមានសំអាងហេតុពីការសម្រេចនោះ ។ ចៅក្រមស៊ើបសួរត្រូវចេញដីកាលើកលែងចោទប្រកាន់នៅក្នុងករណីដូចខាងក្រោម[161]:

- អំពើប្រព្រឹត្តមិនមែនជាបទឧក្រិដ្ឋ បទមជ្ឈិម ឬ បទលហុ
- ជនដែលប្រព្រឹត្តអំពើនោះនៅតែគេមិនស្គាល់
- គ្មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនជាប់ចោទ
- ករណីដែលបណ្តឹងអាជ្ញារលត់។

ចៅក្រមស៊ើបសួរអាចប្តឹងសុំទៅតុលាការព្រហ្មទណ្ឌតាម ដីកាបញ្ជូនឲ្យសម្រេចរឹបអូសឧបករណ៍ សម្ភារៈ មូលនិធិ ផលទុន ឬ ទ្រព្យសម្បត្តិប្រសិនមានការសង្ស័យដោយសមហេតុផល ថា ឧបករណ៍ សម្ភារៈ មូលនិធិ ផលទុន ឬ ទ្រព្យសម្បត្តិទាំងនោះពាក់ព័ន្ធនឹងបទល្មើស ។ ក្នុងករណីនេះតុលាការព្រហ្មទណ្ឌត្រូវតែសម្រេចអំពីការរឹបអូសដោយសាលក្រមក្នុងសវនាការជាសាធារណៈ ដោយមានការចូលរួមពីតំណាងអយ្យការ និង បុគ្គល

[161] មាត្រា២៤៧ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មមាត្រា២៤៧ មាត្រា៣៦៨ មាត្រា៣៧២ មាត្រា៣៨២នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០១៣

ដែលបានពាក់ព័ន្ធ ប្រសិនបើសាលក្រមដែលសម្រេចអំពីការរឹបអូសត្រូវបិទផ្សាយនៅទីកន្លែងដែលតុលាការបានចេញសាលក្រម និង ផ្សាយជាសាធារណៈតាមសារព័ត៌មានឬមធ្យោបាយទូរគមនាគមន៍សោតទស្សន៍ ។[162]

បុគ្គលដែលមានផលប្រយោជន៍ពាក់ព័ន្ធនឹងការរឹបអូសនៃវត្ថុ ឬ ជាម្ចាស់នៃវត្ថុនៃការរឹបអូសនោះមានសិទ្ធិប្ដឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្ដីសម្រេចនោះបានក្នុងរយៈពេល ១ខែ គិតចាប់ពីថ្ងៃប្រកាសសាលក្រម ប្រសិនបើបុគ្គលនោះបានចូលរួមក្នុងនីតិវិធីនៃការជំនុំជម្រះរបស់តុលាការ ឬ មានរយៈពេល ២ខែ គិតពីថ្ងៃប្រកាសផ្សាយជាសាធារណៈតាមសារព័ត៌មាន ឬ មធ្យោបាយទូរគមនាគម៍សោតទស្សន៍ប្រសិនបើបុគ្គលនោះមិនបានចូលរួមក្នុងនីតិវិធីតុលាការ។

ដូចនេះហើយ ក្នុងករណីរលត់បណ្ដឹងអាជ្ញាក្នុងដំណាក់កាលការស៊ើបសួរចៅក្រមស៊ើបសួរត្រូវចេញដីកាលើកលែងការចោទប្រកាន់ក្នុងការបិទការស៊ើបសួររបស់ខ្លួនដោយត្រូវជូនដំណឹងដល់ ព្រះរាជអាជ្ញា និង ដើមបណ្ដឹងរដ្ឋប្បវេណី ហើយ ចៅក្រមស៊ើបសួរអាចប្ដឹងសុំទៅតុលាការព្រហ្មទណ្ឌតាមដីកាសម្រេចឲ្យរឹបអូសឧបករណ៍ សម្ភារៈ មូលនិធិផលទុន ឬ ទ្រព្យសម្បត្តិដែលពាក់ព័ន្ធនឹងបទល្មើស ។

### ២.៣.២ ដីកាសម្រេចរំលត់បណ្ដឹងអាជ្ញា

អង្គការអយ្យការ ជាម្ចាស់នៃបណ្ដឹងអាជ្ញា ។ អង្គការអយ្យការមានតួនាទីធ្វើការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ និង សន្និដ្ឋានឲ្យតុលាការអនុវត្តច្បាប់ ។ អង្គការអយ្យការត្រូវធានារ៉ាប់រងការអនុវត្តសេចក្ដីសម្រេចខាងព្រហ្មទណ្ឌព្រមទាំងយកចិត្តទុកដាក់លើការផ្សព្វផ្សាយដីកាបង្គាប់ឲ្យចាប់ខ្លួន ។[163] តាមគោលការណ៍ព្រះរាជអាជ្ញាជាម្ចាស់នៃបណ្ដឹងអាជ្ញាដែលជាតួអង្គសំខាន់ក្នុងដំណើរការនៃរឿងព្រហ្មទណ្ឌ។ ហេតុនេះព្រះរាជអាជ្ញាត្រូវទទួលបន្ទុកក្នុងការចេញដីកាសម្រេចរំលត់បណ្ដឹងអាជ្ញា ប្រសិនបើ ក្នុងករណីមានការរលត់បណ្ដឹងអាជ្ញាណាមួយក្នុងពេលដំណើរការរឿងក្ដីព្រហ្មទណ្ឌ ។ មរណភាពរបស់ជនជាប់ចោទធ្វើឲ្យតុលាការព្រហ្មទណ្ឌត្រូវតែបញ្ឈប់នីតិវិធីក្នុងការចោទប្រកាន់ព្រហ្មទណ្ឌ ។ ហេតុនេះហើយប្រសិនបើ ជនត្រូវចោទ ឬ ជនជាប់ចោទបានទទួលមរណភាពនៅក្នុងដំណាក់កាលការស៊ើបសួរ ឬ ដំណាក់កាលការជំនុំជម្រះព្រះរាជអាជ្ញាត្រូវចេញដីកាសម្រេចរំលត់បណ្ដឹងអាជ្ញាភ្លាម ដើម្បី ឲ្យភាគីដែលពាក់ព័ន្ធជាពិសេសដើមបណ្ដឹងរដ្ឋប្បវេណីបានដឹងពីការរលត់បណ្ដឹងអាជ្ញាស្របតាមមាត្រា ៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

[162] មាត្រា២៤៧ថ្មី នៃច្បាប់ស្ដីពីវិសោធនកម្មមាត្រា២៤៧ មាត្រា៣៦៨ មាត្រា៣៧២ មាត្រា៣៨២នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០១៣

[163] មាត្រា២៧នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

ដីកាសម្រេចរំលត់បណ្តឹងអាជ្ញាមានអានុភាពនាំឲ្យអាជ្ញាអស់ជំនុំដែលធ្វើឲ្យតុលាការព្រហ្មទណ្ឌមិនអាចធ្វើការចោទប្រកាន់ឡើងវិញ ឬ ត្រូវបញ្ឈប់ការចោទប្រកាន់ករណីមានការចោទប្រកាន់រួចហើយ ។ ម្យ៉ាងទៀតនាំឲ្យតុលាការបិទបញ្ចប់សំណុំរឿង ឬ ការចំណាយរឿងចេញពីបញ្ជីសំណុំរឿងដែលកំពុងចាត់ការ។

នៅក្នុងដីកាសម្រេចរំលត់បណ្តឹងអាជ្ញាក៏មានអានុភាពប្តឹងបញ្ជូនសំណុំរឿងនិងវត្ថុតាងព្រមទាំងភស្តុតាងនានាទៅយុត្តាធិការជំនុំជម្រះ ដើម្បី សម្រេចពីសំណងរដ្ឋប្បវេណី។

ដូចនេះប្រសិនបើជនល្មើសទទួលមរណភាពនោះនាំឲ្យព្រះរាជអាជ្ញាត្រូវចេញដីកាសម្រេចរំលត់បណ្តឹងអាជ្ញាភ្លាម។

## ២.៣.៣.សមត្ថកិច្ចរបស់តុលាការព្រហ្មទណ្ឌពីសេចក្តីសម្រេចដែលមិនអាចសម្រេចបានដោយសារតែមរណភាពជនជាប់ចោទ

នៅពេលដែលជនជាប់ចោទទទួលមរណភាពនាំឲ្យតុលាការព្រហ្មទណ្ឌត្រូវតែបញ្ឈប់នីតិវិធី ឬ មិនអាចបន្តទៀតបាន ។ ផ្ទុយមកវិញនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ និង ច្បាប់ដោយឡែកមួយចំនួនបានចែងពីការផ្តល់សមត្ថកិច្ចទៅកាន់តុលាការព្រហ្មទណ្ឌ ក្នុងការផ្តល់សេចក្តីសម្រេចទៅលើករណីមួយចំនួនដែលមិនអាចសម្រេចបានដោយសារមរណភាពរបស់ជនល្មើស ។ សេចក្តីសម្រេចនេះត្រូវបានធ្វើឡើងតាមរយៈការប្តឹងសុំទាមទាររបស់ដើមបណ្តឹងរដ្ឋប្បវេណី តាមរយៈការប្តឹងសុំឲ្យតុលាការព្រហ្មទណ្ឌសម្រេចសេចក្តីរបស់ចៅក្រមស៊ើបសួរ ឬ ការប្តឹងសុំឲ្យសម្រេចសេចក្តីពីព្រះរាជអាជ្ញា ។ សេចក្តីសម្រេចនោះនឹងអាចជួយសម្រេចពីការទាមទារឲ្យមានការជួសជុលព្យសនកម្ម របស់ ដើមបណ្តឹងរដ្ឋប្បវេណីដែលធ្វើឡើងដើម្បីប្រឆាំងនឹងសិទ្ធិវន្តរបស់ជនជាប់ចោទ តុលាការព្រហ្មទណ្ឌក៏សម្រេចពីឧបករណ៍ សម្ភារៈ មូលនិធិផលទុនឬទ្រព្យសម្បត្តិមួយចំនួនដែលពាក់ព័ន្ធនឹងបទល្មើស ។ ហើយតុលាការព្រហ្មទណ្ឌត្រូវធ្វើសេចក្តីសម្រេចក្នុងករណីដូចខាងក្រោម ប្រសិនបើ មានការប្តឹងសុំ:

- សេចក្តីសម្រេចពីការប្រគល់វត្ថុដែលចាប់យក: តុលាការព្រហ្មទណ្ឌមានសមត្ថកិច្ចសម្រេចអំពីការប្រគល់វត្ថុដែលចាប់យកដែលបានធ្វើការចោទប្រកាន់ចំពោះមុខយុត្តាធិការស៊ើបសួរ ឬ យុត្តាធិការជំនុំជម្រះ។
- សេចក្តីសម្រេចពីការរឹបអូសឧបករណ៍ សម្ភារៈ មូលនិធិផលទុន ឬ ទ្រព្យសម្បត្តិទាំងនោះពាក់ព័ន្ធនឹងបទល្មើស តាមការប្តឹងសុំពីចៅក្រមស៊ើបសួរទៅកាន់តុលាការព្រហ្មទណ្ឌ។[164]

[164] មាត្រា២៤៧ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មមាត្រា២៤៧ មាត្រា៣៦៨ មាត្រា៣៧២ មាត្រា៣៨២នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០១៣

- សេចក្តីសម្រេចពីរឹបអូសទ្រព្យសម្បត្តិក្នុងការចោទប្រកាន់មិនអាចធ្វើទៅបាន ដោយសារមរណភាពនៃជនល្មើសតាមការប្តឹងសុំរបស់ព្រះរាជអាជ្ញា ។ ឧទាហរណ៍នៅក្នុងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនបានចែងពី ព្រះរាជអាជ្ញាអាចប្តឹងសុំទៅតុលាការព្រហ្មទណ្ឌ ដើម្បី សម្រេចរឹបអូសឧបករណ៍ សម្ភារៈ មូលនិធិ ផលទុន ឬ ទ្រព្យសម្បត្តិទាំងនោះដែលពាក់ព័ន្ធនឹងបទល្មើសដែលមិនអាចធ្វើទៅបានដោយសារតែមរណភាពនៃជនល្មើស ។[165]
- ការសម្រេចអំពីប្រយោជន៍រដ្ឋប្បវេណីៈ ទោះបីជាបណ្តឹងអាជ្ញាត្រូវរលត់ក៏ដោយក៏តុលាការព្រហ្មទណ្ឌនៅតែមានសមត្ថកិច្ចសម្រេចអំពីប្រយោជន៍រដ្ឋប្បវេណីដដែល ប្រសិនបើ មានការប្តឹងសុំពីដើមបណ្តឹងរដ្ឋប្បវេណី ។ ថ្វីត្បិតតែជនជាប់ចោទស្លាប់ តុលាការនៅតែអាចសម្រេចសេចក្តីលើបណ្តឹងរដ្ឋប្បវេណីដែលធ្វើឡើង ដើម្បី ប្រឆាំងនឹងសិទ្ធិវន្តរបស់ជនជាប់ចោទ ។[166] ហេតុនេះមរណភាពរបស់ជនជាប់ចោទមិនមានអានុភាពនាំឲ្យរលត់នៃបណ្តឹងរដ្ឋប្បវេណីនោះទេ ព្រោះ មូលហេតុនៃការរលត់បណ្តឹងរដ្ឋប្បវេណីត្រូវអនុលោមតាមក្រមរដ្ឋប្បវេណី។

ដូច្នេះ មរណភាពរបស់ជនជាប់ចោទនាំឲ្យមិនអាចធ្វើការចោទប្រកាន់បទល្មើសព្រហ្មទណ្ឌនោះទេ ប៉ុន្តែតុលាការព្រហ្មទណ្ឌមានសមត្ថកិច្ចក្នុងការសម្រេចពីការប្រគល់វត្ថុដែលចាប់យក សេចក្តីសម្រេចពីការរឹបអូសឧបករណ៍ សម្ភារៈ មូលនិធិ ផលទុន ឬ ទ្រព្យសម្បត្តិទាំងនោះដែលពាក់ព័ន្ធនឹងបទល្មើស តាមការប្តឹងសុំពីចៅក្រមស៊ើបសួរ ឬ ព្រះរាជអាជ្ញាទៅកាន់តុលាការព្រហ្មទណ្ឌហើយតុលាការព្រហ្មទណ្ឌត្រូវសម្រេចពីប្រយោជន៍រដ្ឋប្បវេណីដល់ដើមបណ្តឹងរដ្ឋប្បវេណី ប្រសិនបើ មានការប្តឹងសុំដែលប្រឆាំងនឹងសិទ្ធិវន្តរបស់ជនជាប់ចោទផងដែរ។

[165] មាត្រា៩៦នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនឆ្នាំ២០១២

[166] មាត្រា២៤នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

# សេចក្តីសន្និដ្ឋាន

ឆ្លងតាមការបកស្រាយខាងលើបានឲ្យដឹងថាបណ្តឹងអាជ្ញាត្រូវបានដាក់ឲ្យមានចលនា ដោយ អយ្យការ ជនរងគ្រោះ ឬ ដោយមន្ត្រីរាជការ ឬ ភ្នាក់ងារសាធារណៈ ។ តំណាងអយ្យការជាម្ចាស់នៃបណ្តឹងអាជ្ញា ។ ក្នុងនោះដែរតួនាទីសំខាន់របស់ព្រះរាជអាជ្ញា គឺ ត្រូវធ្វើចំណាត់ការលើបណ្តឹងនោះថាគួរចោទប្រកាន់ ឬ មិនគួរចោទប្រកាន់ដែលជាអំណាចឆន្ទានុសិទ្ធិរបស់ព្រះរាជអាជ្ញាស្របតាមបញ្ញត្តិច្បាប់ជាធរមាន។

នៅក្នុងក្រមព្រហ្មទណ្ឌបានចែងពីការរលត់បណ្តឹងអាជ្ញាទូទៅដែលរួមមាន មរណភាពនៃជនល្មើស ការផុតអាជ្ញាយុកាល ការលើកលែងទោសជាទូទៅ និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ អាជ្ញាអស់ជំនុំ ។ ការរលត់បណ្តឹងអាជ្ញាទូទៅនេះត្រូវបានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ។ ដោយឡែកមានមូលហេតុផ្សេងទៀតដែលនាំឲ្យរលត់បណ្តឹងអាជ្ញា ប្រសិនបើ មានចែងក្នុងច្បាប់ដោយឡែកថាមូលហេតុទាំងនោះជាលក្ខខណ្ឌដែលនាំឲ្យរលត់បណ្តឹងអាជ្ញាដែលរួមមាន ដូចជា ការសម្របសម្រួលជាមួយរដ្ឋ ការដកពាក្យបណ្តឹងដែលជាលក្ខខណ្ឌចាំបាច់នៃការចោទប្រកាន់ជាបទព្រហ្មទណ្ឌ ការបង់ប្រាក់ពិន័យសរុប ឬ ប្រាក់សម្របសម្រួល ។ ការរលត់បណ្តឹងអាជ្ញាទូទៅ និង ការរលត់បណ្តឹងអាជ្ញាដោយមូលហេតុផ្សេងទៀតនោះជាកម្មវត្ថុនៃចំណាត់ការរបស់ព្រះរាជអាជ្ញាក្នុងការសម្រេចលើកលែងចោទប្រកាន់ ឬ តម្កល់រឿងទុកឥតចាត់ការនៅក្នុងដំណាក់កាលអយ្យការ ។ ការតម្កល់រឿងទុកឥតចាត់ការត្រូវបានធ្វើឡើងចំពោះអំពើមិនមែនជាបទល្មើស និង អំពើដែលជាបទល្មើស ។ ការតម្កល់រឿងទុកឥតចាត់ការ គឺជា អាជ្ញាមិនអស់ជំនុំ ។ ជនរងគ្រោះអាចធ្វើការប្តឹងតវ៉ាពីសេចក្តីសម្រេចការតម្កល់រឿងទុកឥតចាត់របស់តំណាងអយ្យការសាលាដំបូងតាមរយៈយន្តការប្រឆាំងការតម្កល់រឿងទុកឥតចាត់ការ ។ ការតម្កល់រឿងទុកឥតការសំដៅដល់ការរលត់បណ្តឹងអាជ្ញាដែលស្ថិតនៅដំណាក់ការអយ្យការ ប៉ុន្តែក៏មានមូលហេតុរលត់បណ្តឹងមួយដែលអាចធ្វើឲ្យរលត់បណ្តឹងអាជ្ញាក្នុងដំណាក់កាលការស៊ើបសួរ ឬ ដំណាក់កាលការជំនុំជម្រះនោះគឺមរណភាពរបស់ជនល្មើស ។ មរណភាពរបស់ជនត្រូវចោទគឺជា មូលហេតុមួយដែលនាំឲ្យលត់បណ្តឹងអាជ្ញាក្នុងដំណាក់កាលការស៊ើបសួរ ដែលនាំឲ្យ ចៅក្រមស៊ើបសួរត្រូវបញ្ឈប់ការស៊ើបសួររបស់ខ្លួនដោយត្រូវចេញដីកាដំណោះស្រាយក្នុងការបិទការស៊ើបសួរ ។ ដីកាដំណោះស្រាយនោះ គឺជា ដីកាលើកលែងចោទប្រកាន់ដល់ជនត្រូវចោទដោយសារមរណភាពរបស់ជនត្រូវចោទ ។ម្យ៉ាងទៀតប្រសិនបើ ការរលត់បណ្តឹងអាជ្ញានៅក្នុងដំណាក់ការការជំនុំជម្រះតុលាការត្រូវតែបញ្ឈប់នីតិវិធីក្នុងការជំនុំជម្រះរបស់ខ្លួន ។ ព្រះរាជអាជ្ញាក៏ត្រូវចេញដីកាសម្រេចរលត់បណ្តឹងអាជ្ញាផងដែរ ប្រសិនបើជនត្រូវចោទ ឬ ជនជាប់ចោទបានស្លាប់នៅក្នុងដំណាក់កាលការស៊ើបសួរ ឬ ដំណាក់កាលការជំនុំជម្រះ ។ ការរលត់បណ្តឹងអាជ្ញាដោយសារមរណភាពរបស់ជនជាប់ចោទនាំឲ្យមានបញ្ហាចម្រូងចម្រាស់មួយចំនួនដែលបានបន្សល់ទុកចំពោះសំណុំរឿងក្តីព្រហ្មទណ្ឌនោះ ។ ហើយបញ្ហាទាំង

នោះ គឺជា សមត្ថកិច្ច របស់តុលាការព្រហ្មទណ្ឌតាមរយៈការប្តឹងសុំពីចៅក្រមស៊ើបសួរ ឬ ព្រះរាជអាជ្ញា ឬ ដើមបណ្តឹងរដ្ឋប្បវេណីដែលការសម្រេចនោះ រួមមាន ការសម្រេចពីការប្រគល់ ឬ រឹបអូសឧបករណ៍ សម្ភារៈ មូលនិធិ ផលទុន ឬ ទ្រព្យសម្បត្តិមួយចំនួនដែលពាក់ព័ន្ធនឹងបទល្មើស និង សេចក្តីសម្រេចលើការទាមទារផលប្រយោជន៍រដ្ឋប្បវេណីរបស់ដើមបណ្តឹងរដ្ឋប្បវេណីប្រឆាំងនឹងសិទ្ធិវន្តរបស់ជនជាប់ចោទ។

ការរលត់បណ្តឹងអាជ្ញានាំឲ្យតុលាការព្រហ្មទណ្ឌមិនអាចធ្វើការចោទប្រកាន់បទល្មើសព្រហ្មទណ្ឌចំពោះជនល្មើសបាននោះទេ ដូចមានចែងក្នុងក្រមព្រហ្មទណ្ឌ ។ ប៉ុន្តែការដែលមិនអាចចោទប្រកាន់បទល្មើសព្រហ្មទណ្ឌនេះមិនបង្កជាកត្តា ឬ ឧបសគ្គរារាំងដល់ការទាមទារសំណងរបស់ជនរងគ្រោះក្នុងការទទួលបានសំណងរដ្ឋប្បវេណីដោយសារតែការមូលហេតុរលត់បណ្តឹងរដ្ឋប្បវេណីត្រូវអនុលោមតាមក្រមរដ្ឋប្បវេណី។

សរុបជារួមមកការរលត់បណ្តឹងអាជ្ញាគឺមិនឲ្យរលត់បណ្តឹងរដ្ឋប្បវេណីនោះទេ ។ ដើមបណ្តឹងរដ្ឋប្បវេណីនៅតែអាចទាមទារសំណងពីការខូចខាតដែលបណ្តាលមកពី បទល្មើសព្រហ្មទណ្ឌដដែល ឲ្យ តែព្យសនកម្មនោះជាផលវិបាកនៃបទល្មើសផ្ទាល់ ជាព្យសនកម្មផ្ទាល់ខ្លួន បានកើតឡើងនិងនៅក្នុងពេលបច្ចុប្បន្ន។

# អនុសាសន៍

ឆ្លងកាត់តាមការបកស្រាយប្រធានបទការរលត់នៃបណ្តឹងអាជ្ញានេះធ្វើឲ្យបានសិក្សាស្រាវជ្រាវពាក់ព័ន្ធនឹងដំណើរការរឿងក្តីព្រហ្មទណ្ឌដែលមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ។ នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧ បានចែងពីមូលហេតុនៃការរលត់បណ្តឹងអាជ្ញាដែលបានបែងចែងពីមូលហេតុទូទៅ និង មូលហេតុផ្សេងទៀតដែលនាំឲ្យមានការរលត់បណ្តឹងអាជ្ញា ។ មូលហេតុទាំងពីរនេះត្រូវបានសង្កេតឃើញថាត្រូវបានដាក់បញ្ចូលទៅក្នុងការតម្កល់រឿងទុកឥតចាត់ការផងដែរ ។ ការរួមបញ្ចូលនេះនាំឲ្យមានការផលវិបាកចំពោះអ្នកសិក្សា អ្នកអនុវត្តច្បាប់ព្រហ្មទណ្ឌនៅក្នុងប្រទេសកម្ពុជាដែលអាចមានការភ័ន្តច្រឡំ ពី ការរលត់បណ្តឹងអាជ្ញា និង ការតម្កល់រឿងទុកឥតចាត់ការជាពិសេសទៅដល់ ជនរងគ្រោះដែលជា ម្ចាស់បណ្តឹងរដ្ឋប្បវេណី ។ ម្យ៉ាងទៀតអានុភាពរវាងដីកាតម្កល់រឿងទុកឥតចាត់ការ និង អានុភាពនៃដីកាសម្រេចរំលត់បណ្តឹងអាជ្ញាមានលក្ខណៈខុសគ្នាពោល គឺអានុភាពនៃការតម្កល់រឿងទុកឥតចាត់ការមានអានុភាពនាំឲ្យមិនមានអាជ្ញាអស់ជំនុំ ចំណែកអានុភាពនៃដីកាសម្រេចរំលត់បណ្តឹងអាជ្ញា ក្នុង មាត្រា៧ មានអានុភាពអាជ្ញាអស់ជំនុំ ។ ហេតុនេះហើយក៏គួរតែមានការបកស្រាយណាមួយឲ្យបានច្បាស់លាស់ពីនីតិវិធីនៃការប្រើប្រាស់ដីកាទាំងពីរឲ្យបានច្បាស់លាស់ ជៀសវាងការភ័ន្តច្រឡំនៃការប្រើប្រាស់ដីកាទាំងពីរ ដើម្បី ជាភាពងាយស្រួលដល់អ្នកអនុវត្តច្បាប់ អ្នកសិក្សាច្បាប់ឲ្យយល់ច្បាស់ពីចំណុចខាងលើទាំងការអនុវត្ត និង ទ្រឹស្តី ។ ការបែងចែកច្បាស់លាស់នាំឲ្យដើមបណ្តឹងរដ្ឋប្បវេណីងាយស្រួលក្នុងការទាមទារសំណងរដ្ឋប្បវេណី និង ស្វែងរកដំណោះស្រាយ ឬ ធ្វើការតវ៉ានឹងការសម្រេចរបស់ព្រះរាជអាជ្ញា ដើម្បី ធានាបាននៃភាពយុត្តិធម៌ដល់ជនរងគ្រោះ។

ព្រះរាជអាជ្ញាមានអំណាចឆន្ទានុសិទ្ធិយ៉ាងធំធេងក្នុងដំណើរការរឿងក្តីព្រហ្មទណ្ឌហេតុនេះហើយ ព្រះរាជអាជ្ញាក៏ត្រូវធានាផងដែរថាការអនុវត្តការតម្កល់រឿងទុកឥតចាត់ការរបស់ខ្លួនធ្វើឡើងដោយមានសំអាងហេតុ និង សំអាងច្បាប់ឲ្យបានច្បាស់លាស់ និង ឆ្លងកាត់ស៊ើបអង្កេត ឬ ការស្រាវជ្រាវយ៉ាងម៉ត់ចត់ ។ ព្រះរាជអាជ្ញាត្រូវប្រកាន់ខ្ជាប់នៅគោលការណ៍ស្មើភាពគ្នា សមធម៌ និង សមភាពចំពោះចំណាត់ការការតម្កល់រឿងទុកឥតចាត់ការ ជៀសវាងប្រើប្រាស់នូវអំណាចឆន្ទានុសិទ្ធិនេះដោយខុសគោលដៅ ដែលជា ម្ចាស់បណ្តឹងអាជ្ញាក្នុងនាមតំណាងផលប្រយោជន៍សាធារណៈ ។ ព្រះរាជអាជ្ញាមិនត្រូវផ្តើមគំនិត ឬ បន្តការចោទប្រកាន់ ឬ ក៏ខិតខំប្រឹងប្រែងគ្រប់បែបយ៉ាង ដើម្បី តម្កល់រឿងទុកឥតចាត់ការ ប្រសិនបើការស៊ើបអង្កេតដោយឥតលំអៀងមួយបង្ហាញឲ្យឃើញថាការចោទប្រកាន់នេះពុំមានមូលដ្ឋានទេ ។ លើសពីនេះព្រះរាជអាជ្ញាត្រូវខិតខំប្រឹងប្រែងធ្វើយ៉ាងណាធានាថា ជនរងគ្រោះគួរតែទទួលបានភាពយុត្តិធម៌ក្នុងការទទួលបានសំណង ដើម្បី ជួសជុលព្យសនកម្មរបស់ខ្លួនយ៉ាងសមស្របតាមការខូចខាតមកពីបទល្មើសទោះបីជាបណ្តឹងអាជ្ញាត្រូវបានរលត់ក៏ដោយ ។ មូលហេតុរលត់បណ្តឹង

អាជ្ញានៅក្នុងមាត្រា ៨ គួរតែមានការពិនិត្យឲ្យបានម៉ត់ចត់មុននឹងសម្រេចឲ្យរលត់បណ្តឹងអាជ្ញា ពីព្រោះថា ការសម្របសម្រួលក្រៅប្រព័ន្ធតុលាការដែលមិនបានថ្លឹងថ្លែង ពី គុណវិបត្តិនៃការសម្រេចតម្កល់រឿងទុកឥតចាត់ការ ឬ រលត់បណ្តឹងអាជ្ញានោះនឹងនាំឲ្យមានផលប៉ះពាល់ដល់ការអនុវត្តច្បាប់នៅកម្ពុជា និង ផលប្រយោជន៍សាធារណជន។ ហេតុនេះហើយព្រះរាជអាជ្ញាគួរតែធ្វើការពិនិត្យ ឬ បែងចែកឲ្យច្បាស់លាស់រាល់រឿងក្តីដែលអាចសម្របសម្រួលបាន និង រឿងក្តីដែលមិនអាចសម្របសម្រួលនៅក្រៅប្រព័ន្ធតុលាការបាន ដើម្បី ជៀសវាងភាពធ្ងន់ធ្ងរដល់ សង្គមនៅថ្ងៃអនាគត ។

# គន្ថនិទ្ទេស

## I. លិខិតបទដ្ឋានគតិយុត្ត

១. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣

២. ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៩

៣. ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

៤. សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ឆ្នាំ១៩៤៨

៥. ច្បាប់ស្តីពីសារពើពន្ធនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៧

៦. ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

៧. ព្រះរាជក្រឹត្យស្តីពីការបន្ធូរបន្ថយទោសនិងការលើកលែងទោសឆ្នាំ២០២១

៨. ច្បាប់ស្តីពីយុត្តិធម៌អនីតិជនឆ្នាំ២០១៦

៩. ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារនិងកិច្ចការពារជនរងគ្រោះឆ្នាំ២០០៥

១០. ច្បាប់ស្តីពីឯកពន្ធភាពឆ្នាំ២០០៦

១១. ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកឆ្នាំ២០១៤

១២. ច្បាប់ស្តីពីគយឆ្នាំ២០០៧

១៣. លិខិតតុបករណ៍អង្គការសហប្រជាជាតិស្តីពីចៅក្រម ព្រះរាជអាជ្ញានិងមេធាវី , ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា(បោះពុម្ពផ្សាយដោយការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិនៅកម្ពុជាខែមករាឆ្នាំ២០០៧)

១៥. ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រមនិងព្រះរាជអាជ្ញាឆ្នាំ២០១៤

១៦. ច្បាប់ស្តីពីការអនុម័តលើអនុសញ្ញាទីក្រុងវីយ៉ែនស្តីពីទំនាក់ទំនងកុងស៊ុលឆ្នាំ២០០៥

១៧. ច្បាប់ស្តីពីវិសោធនកម្មមាត្រា២៤៧ មាត្រា៣៦៨ មាត្រា៣៧២ មាត្រា៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០១៣

១៨. ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនឆ្នាំ២០១២

១៩. ច្បាប់ស្តីពីពន្ធនាគារឆ្នាំ២០១១

២០. អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាវិធានផ្ទៃក្នុង ( វិសោធនកម្មលើកទី៩ ), វិសោធនកម្មថ្ងៃទី ១៦ ខែមករា ឆ្នាំ២០១៥

## II. សៀវភៅនិងឯកសារផ្សេងៗ

១.សៀវភៅវាក្យសព្ទគតិយុត្តក្នុងនីតិព្រហ្មទណ្ឌ ( ដកស្រង់ចេញពីនីតិព្រហ្មទណ្ឌនិងនីតិគ្រួសារ ) រៀបរៀងដោយលោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធនិងលោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត , ឆ្នាំ២០១៧

២. សៀវភៅនីតិរដ្ឋប្បវេណីនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច រៀបរៀងដោយ លោកសាស្ត្រាចារ្យ អម សុផាណារ៉ាត ឆ្នាំសិក្សា២០១៨ ដល់ ២០១៩

៣.វិទ្យាសាស្ត្រគតិយុត្តក្នុងការកំណត់បទល្មើស រៀបរៀងដោយលោកមេធាវី មួន សៀងលី, រាជធានីភ្នំពេញ, ចុះថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ២០១៥

៤. សៀវភៅនីតិវិធីព្រហ្មទណ្ឌនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ចរៀបរៀងដោយលោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និង លោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត ឆ្នាំសិក្សា២០១៣ដល់២០១៤

៥. ឯកសារសិក្ខាសាលាស្ដីពីការផ្សព្វផ្សាយក្រមព្រហ្មទណ្ឌប្រធានបទគោលការណ៍ទូទៅទាក់ទងនឹងការទទួលខុសត្រូវព្រហ្មទណ្ឌរៀបរៀងដោយ ឯកឧត្ដម កើត រិទ្ធ

៦. សៀវភៅនីតិព្រហ្មទណ្ឌ រៀបរៀងដោយ ឯកឧត្ដម ហ៊ី សោភា

៧.ឯកសារនីតិវិធីព្រហ្មទណ្ឌស្ដីពីការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីតាមផ្លូវអន្ដរាគមន៍ ( ការផ្សព្វផ្សាយរបស់សមាគមត្រាជូ ) រៀបរៀងដោយអ៊ីណូម៉ាកា ខែសីហា២០១៦

៨. នីតិវិធីព្រហ្មទណ្ឌកម្ពុជារៀបរៀងដោយលោក ចក សម្បត្តិ អនុប្រធានសមាគមត្រា(គេហទំព័រសាលាត្រាជូចេញផ្សាយនៅថ្ងៃទី១៣-វិច្ឆិកា-២០២០)

៩. សៀវភៅក្រមរដ្ឋប្បវេណីភាគ១ រៀបរៀងដោយសមាជិកក្រុមការងារអនាគតគ្រូបណ្ដុះបណ្ដាលភូមិន្ទចៅក្រមឧបត្ថម្ភគាំទ្រពីទីភ្នាក់ងារសហប្រតិបត្តិការអន្ដរជាតិនៃប្រទេសជប៉ុន (JICA) និង នាយកដ្ឋានសហប្រតិបត្តិការអន្ដរជាតិនៃវិទ្យាស្ថានស្រាវជ្រាវនិងបណ្ដុះបណ្ដាលនៃប្រសួងយុត្តិធម៌នៃប្រទេសជប៉ុន (JCD ) បោះពុម្ពនៅក្នុងខែមីនាឆ្នាំ២០១២

១០ . សៀវភៅនីតិវិធីព្រហ្មទណ្ឌរៀបរៀងដោយលោកស្រី ឌី លីឡានិងលោក ខាន់ សុខា

១១ . សារណាបញ្ចប់ការសិក្សាលំហូរនីតិវិធីនៃបណ្ដឹងព្រហ្មទណ្ឌ រៀបរៀងដោយនិស្សិត ឃន ប៉េងឡុង និង ឈឺន សុវណ្ណនរាជ សាស្ត្រាចារ្យណែនាំ លោកជួន ប៊ុនធី ឆ្នាំ២០២១

១២. ការរំលត់បណ្ដឹងអាជ្ញា ( ដំណាក់កាលស៊ើបអង្កេតព្រះរាជអាជ្ញា ), ការផ្សាយរបស់សាលាត្រាជូ, រៀបរៀងដោយ លោក ហាក់ សៀកលីម, ខែមិថុនា ឆ្នាំ២០១៩

១៣. ក្រមព្រហ្មទណ្ឌឆ្នាំ១៩៦៧ក្នុងសៀវភៅសិក្សាច្បាប់គ្រប់មាត្រាទាំងអស់ក្នុងក្រមព្រហ្មទណ្ឌ, របស់លោក អេត សុត ក្រសួងយុត្តិធម៌

១៤. សេចក្តីពន្យល់នៃនីតិវិធីក្រមព្រហ្មទណ្ឌកម្ពុជាចំពោះសេចក្តីពន្យល់ករណីយុត្តិសាស្ត្រ អ.វ.ត.ក និង អន្តរជាតិសម្រាំង បោះពុម្ពផ្សាយលើកទី១នៅខែមិនាឆ្នាំ២០១៤

១៥. មេរៀនសង្ខេបស្តីពីនីតិវិធីព្រហ្មទណ្ឌ សម្រាប់បង្រៀននិស្សិតថ្នាក់ពិសេសនីតិសាស្ត្រភាសាបារាំងនៃ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច អមដោយសាកលវិទ្យាល័យ លុយមីញ៉ែលីយ៉ុង២ ( ប្រទេសបារាំង ), ឯកឧត្តម កើត រិទ្ធ ឆ្នាំ២០១៦

១៦. មេរៀនការតម្កល់រឿងទុកឥតចាត់ការ រៀបរៀងដោយ ន. ស. រ , ខែ មករា ឆ្នាំ ២០១៨

១៧. ឯកសារស្រាវជ្រាវស្តីអំពីតួនាទីនិងភារកិច្ចរបស់ព្រះរាជអាជ្ញា, តួនាទីនិងភារកិច្ចរបស់ចៅក្រមស៊ើបសួរ , តួនាទី និង ភារកិច្ចរបស់ចៅក្រមជំនុំជម្រះ, ស៊ន បញ្ញា , រាជធានីភ្នំពេញថ្ងៃទី២៦ខែកក្កដាឆ្នាំ២០២២

២០. របាយការណ៍តុលាការព្រហ្មទណ្ឌអន្តជាតិ , ការសម្រេចនីតិកម្មកម្ពុជាទៅនឹងលក្ខន្តិកៈនៃតុលាការ ព្រហ្មទណ្ឌអន្តរជាតិ, International Federation For Human Rights, ខែមីនាឆ្នាំ២០០៦លេខ៤៤៣

២១. បាឋកថាស្តីពីគោលការណ៍គ្រឹះធំៗនៃក្រមព្រហ្មទណ្ឌនិងក្រមនីតិវិធីព្រហ្មទណ្ឌ,ឯកឧត្តម កើត រិទ្ធ

២២. ឯកសារដំណាក់កាលក្នុងរឿងក្តីព្រហ្មទណ្ឌសម្រាប់មន្ត្រីអនុវត្តច្បាប់នៅកម្ពុជា, នាយកដ្ឋានស្រាវជ្រាវ ផ្សព្វផ្សាយ និង បណ្តុះបណ្តាលច្បាប់ក្នុងវិស័យព្រហ្មទណ្ឌនៃក្រសួងយុត្តិធម៌ឆ្នាំ២០១៩

២៣. មេរៀននីតិវិធីជំនុំជម្រះរឿងក្តីព្រហ្មទណ្ឌនៅសាលាដំបូង, រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ រៀបរៀងដោយ លោក អឿង សៀង

## III. **គេហទំព័រ**

១. គេហទំព័រវិទ្យុបារាំងអន្តរជាតិRFI, ជនជាប់ចោទអៀង សារីទទួលមរណភាព-បណ្តឹងអាជ្ញាត្រូវរលត់ (rfi.fr)

# បញ្ជីឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី១៖ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

ឧបសម្ព័ន្ធទី២៖ ច្បាប់ស្តីពីវិសោធនកម្ម មាត្រា២៤៧ មាត្រា៣៦៨ មាត្រា៣៧២ មាត្រា៣៨២ នៃ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០១៣

ឧបសម្ព័ន្ធទី៣៖ ពាក្យបណ្ដឹង

ឧបសម្ព័ន្ធទី៤៖ ដីកាលើកលែងចោទប្រកាន់

ឧបសម្ព័ន្ធទី៥៖ ដីកាសន្និដ្ឋានស្ថាពរ

ឧបសម្ព័ន្ធទី៦៖ ដីកាបញ្ជាឲ្យចូលខ្លួន

ឧបសម្ព័ន្ធទី៧៖ ដីកាបង្គាប់ឲ្យចាប់ខ្លួន

ឧបសម្ព័ន្ធទី៨៖ ដីកាបង្គាប់ឲ្យឃុំខ្លួន

ឧបសម្ព័ន្ធទី៩៖ ពាក្យសុំដកពាក្យបណ្ដឹង

ឧបសម្ព័ន្ធទី១០៖ ដីកាសម្រេចរំលត់បណ្ដឹងអាជ្ញា

ឧបសម្ព័ន្ធទី១១៖ ដីកាតម្កល់រឿងទុកឥតចាត់ការ